# សៀវភៅណែនាំអំពី






# យុទ្ធនាការតស៊ូមតិ



## ដើម្បីពង្រីកបរិយាកាស
## ប្រជាធិបតេយ្យនៅកម្ពុជា







# មាតិកា


ទំព័រ

- ❖ សៀវភៅណែនាំអំពីការរៀបចំយុទ្ធនាការតស៊ូមតិដើម្បីពង្រីក បរិយាកាសប្រជាធិបតេយ្យនៅកម្ពុជា........................................................................... ១
- ❖ សេចក្ដីណែនាំអំពីការតស៊ូមតិ........................................................................... ៣
- ❖ ការរៀបចំយុទ្ធសាស្ត្រនៃការតស៊ូមតិ........................................................................... ១៣
- ❖ ការរៀបចំនិងអនុវត្តន៍នៃយុទ្ធនាការតស៊ូមតិ........................................................................... ១៦
- ❖ ពិនិត្យមើលឡើងវិញ និង ការកែប្រែយុទ្ធនាការ........................................................................... ២៥
- ❖ ការទំនាក់ទំនងជាមួយតួអង្គសំខាន់ៗ : រដ្ឋាភិបាល និង ប្រព័ន្ធឃោសនា..................................... ២៦
- ❖ សមិទ្ធិផលសម្រេចបាន, ការលំបាកប្រឈមមុខនិងមេរៀនសំរាប់អនាគត..................................... ៣១
- ❖ ករណីសិក្សា
  - សហគមន៍នេសាទ និងការធ្វើឱ្យចេញជាលទ្ធផលលើយុទ្ធនាការតស៊ូមតិ..................................... ៣៥
  - ភាពក្រីក្រនៅតាមទីក្រុង........................................................................... ៤២
- ❖ ឧបសម្ព័ន្ធ
  - ឧបសម្ព័ន្ធ ក : សេចក្ដីប្រកាសពតិមាន........................................................................... ៤៨
  - ឧបសម្ព័ន្ធ ខ : ដំណើរការតាក់តែងច្បាប់........................................................................... ៥៤
  - ឧបសម្ព័ន្ធ គ : ញត្តិ និង លិខិតគាំទ្រ........................................................................... ៥៧
  - ឧបសម្ព័ន្ធ ឃ : ប្រភពផ្សព្វផ្សាយពតិមាន និង អ៊ិនធឺណែត..................................... ៥៩


## ពាក្យបំព្រួញ

| | |
|---|---|
| **ACHR** | សម្ព័ន្ធអាស៊ីសំរាប់សិទ្ធិសង់ទីលំនៅ |
| **ADB** | ធនាគារអភិវឌ្ឍន៍អាស៊ី |
| **CDMC** | ក្រុមប្រឹក្សាគ្រប់គ្រងការអភិវឌ្ឍន៍សហគមន៍ |
| **CSARO** | ក្រុមកែច្នៃនិងអនាម័យសហគមន៍ |
| **DOF** | នាយកដ្ឋានជលផល |
| **FACT** | សម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល |
| **MAFF** | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| **MOWA** | ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន |
| **Oxfam/GB** | អុកហ្វាម ចក្រភពអង់គ្លេស |
| **PADEK** | សហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍នៅកម្ពុជា |
| **PLWHA** | អ្នកផ្ទុកមេរោគហ៊ីវ និងជម្ងឺអេដស៍ |
| **SUPF** | សាមគ្គីភាព និងសេរីភាពនៃជនក្រីក្រនៅទីក្រុង |
| **UNDP** | កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ |
| **UN-Habitat** | កម្មវិធីតាំងទីលំនៅប្រជាជនរបស់អង្គការសហប្រជាជាតិ |
| **UPDF** | អភិឌ្ឍន៍កាត់បន្ថយភាពក្រីក្រនៅទីក្រុង |
| **UPRS** | យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រនៅទីក្រុង |
| **UPWD** | អភិវឌ្ឍន៍ស្ត្រីក្រីក្រនៅទីក្រុង |
| **URC** | មជ្ឈមណ្ឌលធនធានសំរាប់ទីក្រុង |
| **USG** | គណៈកម្មការសំរបសំរួលអភិវឌ្ឍន៍ទីក្រុង |


**សេចក្ដីថ្លែងអំណរគុណ :**

នេះជាសមិទ្ធិផលដែលប្រសូត្រចេញពីកិច្ចខំប្រឹងប្រែងរួមគ្នារបស់អង្គការទាំងឡាយដែលមានការចាប់អារម្មណ៍លើការលើកតំកើងនូវសមត្ថភាពតស៊ូមតិនៃអង្គការមិនមែនរដ្ឋាភិបាលខ្មែរ ។ អង្គការទាំងនោះរួមមាន ADHOC, ACILS, មជ្ឈមណ្ឌលស្ត្រីមានវិបត្តិ (CWCC) ជំនួយព្រះវិហារដាណាម៉ាក (DCA), Forum Syd, Oxfam អង់គ្លេស, Pact, គំរោងប្រឆាំងនិងអំពើហិង្សាក្នុងគ្រួសារនិងអង្គការស្តារកម្ពុជា។ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះអង្គការ លោក-លោកស្រីទាំងឡាយដែលបានចូលរួមវិភាគទានជាពេលវេលា រូបថត និងពតិមានសំរាប់ការបោះពុម្ពនេះ ។ សូមកត់សំគាល់ថា អត្ថបទខ្មែរត្រូវបានប្រែសម្រួលពីភាសាអង់គ្លេសដោយផ្អែកទៅលើអត្ថន័យជាគោល គឺមិនមែនផ្អែកទៅលើពាក្យនិមួយៗឡើយ ។



**និពន្ធដោយ :**

ក. គ្រីស្ទីនណា មែនហ្វីល លោក ឃឹត ម៉ាកឡៅដ៏
ក. ម៉ារ៉ន គ្រីនលីហ្វ និង ក. ប៉ប់ពី អាលិចស៍សានឌ័រ

**កែសម្រួល និងរៀបរៀងអត្ថបទដោយ :**

ក. អេនី ប៊ីកហ្វូដ លោក រស់ សុដ្ឋា
លោក សេង សុផល លោក ផាន ភ័ក្ត បារមី
លោក លី មុនីរិទ្ធិ និងលោក យៀង វីរបុត្រ

# សៀវភៅណែនាំអំពី ៖

# ការរៀបចំយុទ្ធនាការតស៊ូមតិដើម្បីពង្រីក បរិយាកាសប្រជាធិបតេយ្យនៅកម្ពុជា

## សេចក្តីណែនាំ

សៀវភៅណែនាំនេះត្រូវបានគ្រោងរៀបចំឡើងសម្រាប់អ្នកទទួលខុសត្រូវលើកម្មវិធី និងអ្នកឯកទេសលើការអភិវឌ្ឍន៍ដទៃទៀតដែលមានការចាប់អារម្មណ៍ឬចូលរួមនៅក្នុងបញ្ហាតស៊ូមតិនៅកម្ពុជា ។ ឯកសារនេះត្រូវបានបោះពុម្ពបន្ទាប់ពីការបោះពុម្ពសៀវភៅដែលមានចំណងជើងថា ***ការតស៊ូមតិនៅកម្ពុជា***[១] ដែលវិភាគទៅលើបទពិសោធន៍ល្អ និង មិនល្អនៃយុទ្ធនាការតស៊ូមតិនៅកម្ពុជាតាមរយៈវិស័យចំនួន៨ខុសៗគ្នា ។ ទិសដៅនៃគោលការណ៍ណែនាំនេះគឺផ្តល់យុទ្ធសាស្ត្រ និងបច្ចេកទេសដែលជាបទពិសោធន៍ជាក់ស្តែងសម្រាប់អ្នកតស៊ូមតិយកទៅអនុវត្តក្នុងពេលបច្ចុប្បន្ននិងទៅអនាគត ។

ការតស៊ូមតិមានសារៈសំខាន់សម្រាប់លើកកម្ពស់គោលនយោបាយជាសកលឆ្ពោះទៅរកសមធម៌ និង សមភាព។ អ្នកតស៊ូមតិជួយក្រុមពង្រីកវិសាលភាពនានាដើម្បីនិយាយប្រឆាំងនឹងច្បាប់ទម្លាប់ដែលមិនត្រឹមត្រូវ ហើយផ្តល់អំណាចដល់សហគមន៍នៅក្នុងការបង្កើតយុទ្ធនាការតស៊ូមតិហ្មត់ចត់មួយរបស់គេផ្ទាល់ប្រកបដោយនិរន្តរភាព។ យុទ្ធនាការតស៊ូមតិដែលត្រូវបានគ្រោងផែនការបានត្រឹមត្រូវ គឺមានការចូលរួមពីសហគមន៍ដែលមានការប៉ះពាល់ អាជ្ញាធរ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដោយជំរុញឱ្យមានការសហការគ្នារវាងភាគីទាំងសងខាងតាមលក្ខណៈសមស្រប នៅទីបំផុតឈានទៅដល់ដំណោះស្រាយដែលនាំមកនូវផលចំណេញសម្រាប់ទាំងសងខាង។ ទិសដៅរបស់អ្នកតស៊ូមតិគឺឈ្វេងយល់ពីវិធីដែលអង្គការសង្គមស៊ីវិល សហគមន៍មូលដ្ឋាន មន្ត្រីដែលជាប់ឆ្នោត និងអ្នកពាក់ព័ន្ធទាំងអស់អាចលើកកម្ពស់ដំណើរការប្រជាធិតេយ្យ និងលើកកម្ពស់គុណភាពនៃការរស់នៅរបស់ប្រជាជនកម្ពុជាទាំងមូល។

សៀវភៅណែនាំយុទ្ធនាការតស៊ូមតិ ជាជំនួយសម្រាប់អ្នកតស៊ូមតិអាចយកជាមូលដ្ឋាននៅពេលធ្វើយុទ្ធនាការ។ ទោះជាយ៉ាងនេះក្តី យើងមិនមែនកំណត់ឱ្យអ្នកតស៊ូមតិត្រូវអនុវត្តតាមឯកសារនេះទាំងស្រុង ដោយមិនបង្កើតយុទ្ធសាស្ត្រផ្ទាល់ខ្លួននោះទេ។ យើងខិតខំចងក្រងគំនិតល្អៗបំផុតមួយចំនួនសម្រាប់ជួយដល់អ្នកតស៊ូមតិ ដើម្បីអនុវត្តយុទ្ធសាស្ត្ររបស់គេ។ ដូច្នេះឯកសានេះមិនមែនជាការបង្គាប់បញ្ជាដែលតម្រូវថាត្រូវតែធ្វើតាមនោះឡើយ ។

[១] ការតស៊ូមតិនៅក្នុងប្រទេសកម្ពុជា៖ ការពង្រីកបរិយាកាសប្រជាធិបតេយ្យ ដោយ គ្រីស្ទីណា.មែនហ្សៀល និង លោក ឃីត ម៉ាកឡាវដឺ ។
Pact ខែ ឧសភា ឆ្នាំ ២០០២ ។ មានផ្សាយនៅក្នុង Website របស់ Pact : www.pactworld.org

សៀវភៅណែនាំនេះមានគំនិតទាក់ទងនឹងយុទ្ធសាស្ត្រដែលមានប្រយោជន៍សម្រាប់អ្នកប្រើប្រាស់នៅក្នុងការពិនិត្យពិច័យមើលការអនុវត្តន៍យុទ្ធសាស្ត្រមុនពេល ក្នុងកំឡុងពេល និង ក្រោយពេលយុទ្ធនាការ ។ ផ្នែកទី ១ គឺពិនិត្យលើន័យនៃការតស៊ូមតិដោយផ្តោតជាពិសេសទៅលើបរិបទនៅក្នុងប្រទេសកម្ពុជា ។ បន្ទាប់មកសៀវភៅណែនាំនេះពន្យល់ពីរបៀបធ្វើផែនការនិងសកម្មភាពយុទ្ធនាការតស៊ូមតិតាមដំណាក់កាលនីមួយៗ ។ ផ្នែកនីមួយៗនៃដំណើរការនេះត្រូវបានបកស្រាយហើយផ្តល់ជូននូវបទពិសោធន៍ល្អៗសម្រាប់អ្នកតស៊ូមតិ ។ សៀវភៅណែនាំនេះក៏មាននិយាយអំពីរបៀបទំនាក់ទំនងជាមួយរដ្ឋាភិបាល និងប្រព័ន្ធឃោសនាដើម្បីទទួលបានការគាំទ្រនិងចូលរួមក្នុងយុទ្ធនាការ ។ មានករណីសិក្សាពីរៈ ១-ការតស៊ូមតិនៅតាមតំបន់ទីក្រុង និង ២-តំបន់ជនបទក្នុងប្រទេសកម្ពុជាត្រូវបានលើកយកមកបង្ហាញ ដើម្បីផ្តល់ការវិភាគឱ្យស៊ីជំរៅទៅលើអ្វីដែលអាចធ្វើទៅបាននិងអ្វីដែលមិនអាចធ្វើទៅបាននៅក្នុងពេលកន្លងមក ។ នៅចុងបញ្ចប់មានឧបសម្ព័ន្ធសម្រាប់ជួយដល់ផ្នែកយុទ្ធនាការតាមប្រព័ន្ធឃោសនា ដំណើរការបង្កើតច្បាប់ និងកិច្ចខិតខំបញ្ចុះបញ្ចូល ។

# សេចក្តីណែនាំអំពី

# ការតស៊ូមតិ

## ១ និយមន័យនៃការតស៊ូមតិ ~ តើពាក្យនេះមានន័យយ៉ាងណា?

ខាងក្រោមនេះគឺជានិយមន័យរបស់ពាក្យតស៊ូមតិ ដែលធ្លាប់បានប្រើប្រាស់កន្លងមកដោយស្ថាប័នតស៊ូមតិនានាក្នុងប្រទេសកម្ពុជា ៖

> ការតស៊ូមតិ គឺជាការរៀបចំនូវសកម្មភាពជាបន្តបន្ទាប់ដើម្បីបញ្ចុះបញ្ចូលនិងធ្វើឱ្យមានឥទ្ធិពលដល់បុគ្គលទាំងឡាយដែលមានតួនាទីសំខាន់នៅក្នុងជួររដ្ឋាភិបាល នយោបាយ ឬ អ្នកមានឥទ្ធិពលខាងសេដ្ឋកិច្ច ដើម្បីអោយពួកគេអនុវត្តន៍តាមគោលនយោបាយជាសាធារណៈក្នុងគោលបំណងផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋដែលគ្មានអំណាចផ្នែកនយោបាយនិងមានធនធានសេដ្ឋកិច្ចតិចតួច ។

គេមានមធ្យោបាយបីយ៉ាងសម្រាប់ការផ្លាស់ប្តូរឥរិយាបទរបស់បុគ្គល ក្រុម ឬ ស្ថាប័ននានា ដែលប្រើអំណាចរបស់ខ្លួនរំលោភលើអ្នកឯទៀតគឺ ៖

១. **ធ្វើការដោយផ្ទាល់** ជាមួយនិងអ្នកមានអំណាចទាំងនោះដើម្បីបង្ខិតបង្ខំឬបញ្ចុះបញ្ចូលគេឱ្យធ្វើការកែសម្រួលនូវគោលនយោបាយសាធារណៈដើម្បីផ្តល់ជាប្រយោជន៍ដល់អ្នកទន់ខ្សោយ ។

២. **ប្រើឥទ្ធិពលទៅលើអ្នកមានអំណាច** តាមរយៈការធ្វើការដោយផ្ទាល់ជាមួយនិងអ្នកទន់ខ្សោយ ហើយជួយណែនាំអប់រំដល់ពួកគេឱ្យបានយល់ដឹងពីរបៀបធ្វើការតស៊ូមតិសម្រាប់យកទៅប្រើប្រាស់នៅក្នុងការប្រើឥទ្ធិពលលើអ្នកមាន អំណាចដើម្បីឱ្យពួកគេសម្រួលដល់គោលនយោបាយនានាកាន់តែប្រសើរឡើង ។

៣. **ផ្សព្វផ្សាយពត៌មាន** តាមរយៈបណ្តាញឃោសនានិងប្រព័ន្ធផ្សព្វផ្សាយដទៃទៀត ដើម្បីធ្វើឱ្យសាធារណជនបានយល់ដឹងអំពីបញ្ហាការតស៊ូមតិដែលជាមធ្យោបាយសម្រាប់ការគាបសង្កត់ជាសាធារណៈលើអ្នកមានអំណាច ។

យុទ្ធនាការតស៊ូមតិដែលទទួលបានជោគជ័យច្រើនគឺអាស្រ័យដោយមានការរួមផ្សំពីកត្តាទាំងបីនេះ ។ ប្រសិនបើបុគ្គល ក្រុម ឬស្ថាប័នមិនយល់ពីភាពគ្រោះថ្នាក់ដែលពួកគេកំពុងតែបង្កឡើង ពតិមានចាំបាច់ណាស់សំរាប់ឱ្យមានការផ្លាស់ប្តូរអាកប្បកិរិយា ឬ គោលនយោបាយនានារបស់គេឱ្យបានសមស្រប ។ បើបុគ្គល ក្រុម ឬស្ថាប័នមានការយល់ដឹងទៅលើបញ្ហានេះប៉ុន្តែនៅតែមិនមានវិធានការដើម្បីធ្វើការកែប្រែ នោះការគាបសង្កត់ប្រហែលគួរត្រូវអនុវត្តន៍ ។

ជនណាដែលមានការចាប់អារម្មណ៍ដោយផ្ទាល់នូវការចំណាយទៅលើស្ថានការណ៍គឺជាអ្នកដែលជាប់ពាក់ព័ន្ធ ។ អ្នកដែលជាប់ពាក់ព័ន្ធជាទូទៅរាប់បញ្ចូលទាំងសហគមន៍ បុគ្គលទូទៅ អង្គការក្រៅរដ្ឋាភិបាល អង្គការមហាជននៅក្នុង សហគមន៍ រដ្ឋាភិបាល និង ក្រុមហ៊ុនអាជីវកម្មដែលទទួលផលប៉ះពាល់ ។

អ្នកតស៊ូមតិធ្វើការដើម្បីលើកកម្ពស់ការយល់ដឹងអំពីបញ្ហាអ្វីមួយនៅក្នុងចំណោមក្រុមមនុស្សជាច្រើន (សាធារណជន) ដើម្បីទទួលបានការគាំទ្រពីពួកគេ ។ វិធីសាស្ត្រនេះគេហៅថា **ការប្រើការគាបសង្កត់ជាសាធារណៈ** ។ ការកែសម្រួលគោលការណ៍និងការអនុវត្តដែលធ្វើឡើងដោយអ្នកពាក់ព័ន្ធតែម្នាក់ ជាញឹកញាប់កាន់តែមានប្រសិទ្ធភាពនៅពេលដែលមានការបញ្ចូលការគាបសង្កត់ជាសាធារណៈផង ។ បើការគាបសង្កត់ជាសាធារណៈ និង យុទ្ធនាការបញ្ចុះបញ្ចូលត្រូវបានឃ្លាតឆ្ងាយ ធ្វើឱ្យបុគ្គល ក្រុម ឬស្ថាប័ន ផ្តួចផ្តើមដោះស្រាយបញ្ហាមានភាពកក់ក្តៅហើយមានផលប៉ះពាល់អវិជ្ជមានទៀតផងក្នុងការបន្តសកម្មភាពរបស់ខ្លួន ។

ការតស៊ូមតិដែលផ្តោតលើគោលនយោបាយសាធារណៈ ជាការធ្វើការគាបសង្កត់លើអ្នកសម្រេចលើគោលនយោបាយ គឺជាវិធីដ៏មានប្រសិទ្ធភាពឈានទៅធ្វើការកែប្រែឬបង្កើតច្បាប់នានា ។ ការតស៊ូមតិបែបនេះមានប្រសិទ្ធភាពបំផុត នៅពេលដែលគោលនយោបាយសាធារណៈត្រូវបានគេបង្កើតឡើងតាមរយៈដំណើរការពិគ្រោះយោបល់ ហើយមានយន្តការដែលអនុញ្ញាតឱ្យមានការចូលរួមនៅក្នុងការបញ្ចេញមតិ ដើម្បីសុំឱ្យមានការកែប្រែ ឬធ្វើគោលនយោបាយបែបណាមួយនោះ ។ នៅពេលដែលផ្នែកនីតិបញ្ញត្តិអនុម័តលើគោលនយោបាយសាធារណៈរួចហើយ ចាំបាច់ត្រូវតែមានរដ្ឋាភិបាលនិងប្រព័ន្ធតុលាការមួយត្រឹមត្រូវសម្រាប់កែប្រែអ្វីដែលបានសរសេរនៅលើក្រដាសឱ្យទៅជាការអនុវត្តជាក់ស្តែង និង ធ្វើឱ្យច្បាប់មានសុពលភាព ។

អ្នកតស៊ូមតិនៅប្រទេសកម្ពុជាត្រូវស្គាល់ការលំបាកនានាក្នុងការប្រឈមមុខចំពោះបរិយាកាសនយោបាយក្នុងស្រុក ។ ដោយឡែកការខ្វះគណនេយ្យភាពឬការទទួលខុសត្រូវផ្ទាល់ខ្លួននិងភាពមិនគ្រប់គ្រាន់នៃយន្តការ និងសុពលភាពនៃច្បាប់ បង្កបានជាការលំបាកប្រឈមមុខចំពោះកិច្ចខិតខំប្រឹងប្រែងនៃការតស៊ូមតិ ។ អ្នកពាក់ព័ន្ធត្រូវចងចាំពីការលំបាកប្រឈមទាំងនេះនៅពេលធ្វើផែនការដឹកនាំ និង យុទ្ធនាការតស៊ូមតិរបស់លោកអ្នក ។

## ២ តើយុទ្ធនាការតស៊ូមតិមានលក្ខណៈបែបណា?

**ទីមួយ : ការតស៊ូមតិ ខិតខំស្វែងរកការកែប្រែលើគោលនយោបាយសាធារណៈ ដើម្បីលើកកម្ពស់គុណភាពនៃការរស់នៅរបស់ក្រុមមនុស្សដែលខ្សត់ខ្សោយ ឬដែលងាយរងគ្រោះ ។** ក្រុមទាំងនេះច្រើនតែមិនមានសមត្ថភាព ឬ ធនធានដើម្បីចងក្រងគ្នាឬដើម្បីសម្តែងមតិតំណាងឱ្យក្រុមខ្លួន ។ អ្នកតស៊ូមតិគឺជាបុគ្គលឬអង្គការ(អង្គការមិនមែនរដ្ឋាភិបាល ឬស្ថាប័នរដ្ឋ)ដែលចងក្រងឡើង ឬឡើងសម្តែងមតិជំនួសមុខឱ្យក្រុមមនុស្សដែលមិនអាចតស៊ូមតិដោយខ្លួនឯងបាន ។ គួរសង្កត់ធ្ងន់ថាគោលបំណងចុងក្រោយរបស់អ្នកតស៊ូមតិ គឺជានិច្ចកាលតែងតែផ្តល់សិទ្ធអំណាចដល់ក្រុមមនុស្សឱ្យចេះធ្វើសកម្មភាពដោយខ្លួនឯង ។ ដូច្នេះកិច្ចខិតខំប្រឹងប្រែងរបស់ អ្នកត្រូវតែមានការចូលរួមខ្ពស់ពីអ្នកដែលទទួលរងគ្រោះ ឬប៉ះពាល់ ។

**ទីពីរ ៖ ការតស៊ូមតិត្រូវការព័ត៌មាននៃបញ្ហាច្បាស់លាស់ និងអាចទុកចិត្តបាន** ពីព្រោះយុទ្ធនាការតស៊ូមតិជាការខិតខំដើម្បីបញ្ចុះបញ្ចូលអ្នកមានឥទ្ធិពលដោយសំអាងលើពត៌មានជាក់ស្តែង ។ អ្នកត្រូវស្វែងយល់បញ្ហាដែលនៅជុំវិញឱ្យបានសព្វគ្រប់ល្អិតល្អន់ ដើម្បីទាក់ទាញអ្នកដែលមិនគាំទ្រដល់ផលប៉ះពាល់របស់អ្នក ។ ការចងក្រងឯកសារស្រាវជ្រាវហើយចែកចាយទៅដល់អ្នកពាក់ព័ន្ធដូចជាអ្នកធ្វើច្បាប់ អ្នកកាសែត និង សាធារណជន គឺជាផ្នែកសំខាន់សម្រាប់ការងារតស៊ូមតិ ។ អ្នកដែលបានបង្កើតបូកែប្រែគោលនយោបាយគឺចង់បានដំណោះស្រាយ មិនមែនចង់បានតែបញ្ហាពីអ្នកតស៊ូមតិប៉ុណ្ណោះទេ ។ នៅក្នុងប្រទេសកម្ពុជាពត៌មានទាំងអស់ត្រូវតែមានជាភាសាខ្មែរ និងភាសាអង់គ្លេស ។

**ទីបី ៖ ការតស៊ូមតិជាការងារដែលត្រូវតែធ្វើឡើងជាសកម្មភាពបន្តបន្ទាប់** សកម្មភាពមួយ ឬពីរ ដែលដាច់ៗពីគ្នាមិនមែនជាយុទ្ធនាការតស៊ូមតិទេ ។ អ្នកមិនអាចរំពឹងថានឹងមានការកែប្រែបានស្ថិតស្ថេរមួយកើតមានពិតប្រាកដបានឡើយ ប្រសិនបើអ្នកមិនធ្វើទៅតាមផែនការជាយុទ្ធសាស្ត្រ ឬមានការជួយពង្រឹងពីគ្នាទៅវិញទៅមកក្នុងរយៈពេលវែង ។ អាស្រ័យហេតុនេះគេត្រូវយល់ថាការតស៊ូមតិគឺជា **យុទ្ធសាស្ត្រ** និង **យុទ្ធនាការ** ជាជាងសកម្មភាពទីមួយៗ ។

**ចំណុចចុងក្រោយ ៖ ការតស៊ូមតិស្វះស្វែងរកការកែប្រែលើតុល្យភាពនៃអំណាច ដើម្បីឱ្យក្រុមដែលងាយរងគ្រោះអាចគ្រប់គ្រងបានកាន់តែច្រើនលើជីវិតរបស់គេ ។** ទោះជាយ៉ាងណាក៏ដោយស្ថាប័ននិងមនុស្សដែលមានអំណាចជាធម្មតាមិនងាយបោះបង់ចោលអំណាចរបស់គេទេ ។ ការប៉ុនប៉ងដើម្បីធ្វើការផ្លាស់ប្តូរអតុល្យភាពនៃអំណាច ពិតជាធ្វើឱ្យអ្នកកាន់អំណាចគិតថាគេកំពុងស្ថិតនៅក្រោមការគំរាមកំហែង ឬមានអារម្មណ៍មិនល្អ ។ ដោយសារហេតុនេះអ្នកតស៊ូមតិត្រូវប្រមើលមើលនូវស្ថានភាពដែលមិនល្អ និងត្រៀមខ្លួនជាស្រេចដើម្បីដោះស្រាយឱ្យមានប្រសិទ្ធភាព ។ នៅពេលជាមួយគ្នានោះ ដំណោះស្រាយដែលអ្នកលើកឡើងគួរតែមានភាពសមល្មមចំពោះអ្នកដែលពាក់ព័ន្ធ និងដំណោះស្រាយទាំងនោះ ។ អ្នកមិនគួរបង្កភាពអមិត្តជាមួយនិងក្រុមមនុស្សដែលអ្នកត្រូវការធ្វើការជាមួយ ដោយធ្វើការទាមទារណាមួយដែលមិនសមស្របនោះទេ ។ បើទិសដៅរបស់អ្នកធ្វើហួសប្រមាណអ្នកនឹងមិនអាចសម្រេចបានអ្វីទាំងអស់ ។ ពេលខ្លះត្រូវចាប់ផ្តើមពីទិសដៅតស៊ូមតិតូចៗល្មម រួចហើយឈានទៅរកទិសដៅធំៗបន្ទាប់ពីធ្វើបានសម្រេចជ័យជំនះលើទិសដៅតូចៗទាំងនោះហើយ ។

ជាញឹកញាប់ណាស់ដំណោះស្រាយមួយ អាចប្រើប្រាស់សម្រាប់បញ្ហាមួយ ។ ដំណោះស្រាយគួរកែតម្រូវ ឬដោះស្រាយបញ្ហាបានក្នុងរយៈពេលយូរ និងមាន*និរន្តរភាព* ។

## ៣ បញ្ហានៃការតស៊ូមតិ ៖ តើយុទ្ធនាការតស៊ូមតិមួយធ្វើឡើងដើម្បីទទួលបានសមិទ្ធផលអ្វី?

គេអាចរៀបចំបង្កើតយុទ្ធនាការនៃការតស៊ូមតិឡើងដោយហេតុផលច្រើនយ៉ាង ។ ជារឿយៗគេចាប់ផ្តើមយុទ្ធនាការនៃការស៊ូមតិនៅពេលណាដែលមានក្រុមណាមួយដឹងថាស្ថានការណ៍មិនមានលក្ខណៈល្អប្រសើរ ក្នុងករណីគ្មានបំលាស់ប្តូរកម្រិតតាក់តែងគោលនយោបាយទាំងនៅថ្នាក់មូលដ្ឋាន ឬថ្នាក់ជាតិណានោះ ។ ឧទាហរណ៍ ក្រុមការងារដើម្បីសិទ្ធិនេសាទក្នុងតំបន់ បានទទួលស្គាល់ថាគោលនយោបាយរបស់

រាជរដ្ឋាភិបាលចាំបាច់ត្រូវតែផ្លាស់ប្តូរ ដើម្បីឱ្យសហគមន៍បានទទួលនូវសិទ្ធិបន្ថែមទៀតទៅលើផ្នែកជលផល (សូមពិនិត្យមើលករណីសិក្សាដែលបានភ្ជាប់មកជាមួយសម្រាប់ធ្វើការពិភាក្សាបន្ថែមទៀតចំពោះបញ្ហាជលផល) ។

ការតស៊ូមតិអាចតម្រង់ទិសដៅឆ្ពោះទៅរកគោលនយោបាយ និងការអនុវត្តន៍នានាចំពោះស្ថាប័នផ្សេងៗដូចជា បណ្តាក្រុមហ៊ុន ធនាគារ ពហុភាគី ឬសាកលវិទ្យាល័យនានា ។ ដោយសារតែច្បាប់ ឬគោលនយោបាយមួយចំនួន ហួសសម័យ ឬមិនមានលក្ខណៈគ្រប់គ្រាន់ ដូច្នេះអ្នកធ្វើច្បាប់ទាំងឡាយគឺជាមុខព្រួញចម្បងសម្រាប់ការខិតខំប្រឹងប្រែងក្នុងការតស៊ូមតិ ។ យុទ្ធនាការតស៊ូមតិដែលតម្រង់ទិសដៅទៅរកគោលនយោបាយសាធារណៈពោលគឺផ្តោតការយកចិត្តទុកដាក់ទៅលើការកែតម្រូវគោលនយោបាយដែលមិនពេញចិត្ត (តួយ៉ាងដូចជាច្បាប់ចាស់ដែលទាក់ទងរឿងដីធ្លី) ឬការផ្តោតអារម្មណ៍ទៅលើការបង្កើតឱ្យមាននូវគោលនយោបាយថ្មីមួយដែលមិនត្រូវបានគេលើកឡើង (ឧទាហរណ៍ ដូចជាអំពើហិង្សាក្នុងគ្រួសារនាទសវត្សឆ្នាំ ៩០) ។

វាជាការចាំបាច់ណាស់សម្រាប់អ្នកតស៊ូមតិក្នុងការផ្តោតការយកចិត្តទុកដាក់របស់ខ្លួនលើសកម្មភាពបង្កើត និងធ្វើឱ្យច្បាប់មានសុពលភាពប៉ុណ្ណោះទេ គឺត្រូវយកចិត្តទុកដាក់លើសកម្មភាពការពារផងដែរ ។ ឧទាហរណ៍ អង្គការនានាដែលធ្វើការផ្នែកអំពើហិង្សាក្នុងគ្រួសារដែលកំពុងធ្វើការជាមួយក្រសួងកិច្ចការនារី និងអតីតយុទ្ធជន(MOWA) បានខិតខំដើម្បីធ្វើឱ្យប្រាកដថា ពង្រាងច្បាប់អំពើហិង្សាក្នុងគ្រួសារជួយការពារស្ត្រីទាំងឡាយដែលរងនូវការរំលោភលើសិទ្ធិនៃអំពើរំលោភទាំងឡាយដែលនឹងកើតមាននៅថ្ងៃខាងមុខទៀត ។ ទោះជាយ៉ាងណាក៏ដោយការអប់រំ និងការបង្កើនការយល់ដឹងអំពីអំពើហឹង្សានិងសិទ្ធិស្ត្រីជាសកម្មភាព ការពារបានផ្តល់នូវអំណាចដល់ស្ត្រីទាំងឡាយនេះជាគោលបំណងចុងក្រោយបង្អស់នៃការតស៊ូមតិ និងក៏ជាយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពមួយផងដែរ ។ ការតភ្ជាប់ទង្វើស្របច្បាប់និងកម្មវិធីអប់រំនានា ជាការចាំបាច់ដើម្បីធ្វើឱ្យចលនាតស៊ូមតិមានប្រសិទ្ធភាពកាន់តែច្រើនថែមទៀត ។

លោកអ្នកអាចបង្កើតយុទ្ធនាការតស៊ូមតិរបស់ខ្លួនដែលលើកឡើងពី បញ្ហាសង្គម បញ្ហានយោបាយ និងបញ្ហាសេដ្ឋកិច្ច ។ ឧទាហរណ៍ដូចជា :

- **បញ្ហាសង្គម :** រួមមានផ្នែកសុខភាព សិក្សាធិការ វប្បធម៌សិល្បៈ ការជួញដូរមនុស្ស បរិស្ថាន សមភាពរវាងបុរសនិងស្ត្រី(យេនឌ័រ) និងការមិនសូវឱ្យតំលៃដល់ក្រុមមនុស្សដូចជា ក្រុមជនពិការ ចាស់ ជរា និងក្មេងកំព្រាជាដើម ។ រាល់បញ្ហាសង្គមទាំងអស់មានពាក់ព័ន្ធនូវបញ្ហាសេដ្ឋកិច្ច និងទិដ្ឋភាពនយោបាយចូលជាមួយផងដែរ ។ ជាទូទៅមានការជួយជ្រោមជ្រែងចំពោះការតស៊ូមតិជុំវិញបញ្ហាសង្គមច្រើនជាងការគាំទ្រទៅលើបញ្ហាសេដ្ឋកិច្ច និង នយោបាយ ។ នេះក៏ដោយសារតែ ម្យ៉ាងគឺភ្នាក់ងារផ្តល់ជំនួយជារឿយៗយកចិត្តទុកដាក់ជួយដល់ក្រុមជនដែលគេមិនសូវឱ្យតំលៃថាមានសារៈសំខាន់ ហើយម្យ៉ាងវិញទៀតគឺដោយសារបញ្ហាសង្គមមើលទៅដូចជាមានការគំរាមកំហែងតិចតួចណាស់ទៅលើអ្នកកំពុងកាន់អំណាច ។ ដូច្នេះហើយការផ្លាស់ប្តូរបែបនេះទំនងជាបានទទួលផ្លែផ្កាច្រើនជាង ។

ការអនុវត្តន៍សង្គមស៊ីវិលមានដូចជា : សេរីភាពក្នុងការ និយាយស្តី បោះឆ្នោត សេរីភាពខាងសារពត៌មាន សេរីភាពបង្កើតសមាគម៍ និងសិទ្ធិក្នុងការចូលរួមជាមួយមន្ត្រីដែលបានជ្រើសតាំងក្នុងបរិយាយកាសប្រជាធិបតេយ្យ ។

បរិយាកាសនេះគឺជាកន្លែងមួយដែលអ្នកណាម្នាក់អនុវត្តសេរីភាពរបស់ខ្លួនដោយគ្មានការភ័យខ្លាច ហើយត្រូវបានធានាដោយរដ្ឋធម្មនុញ្ញ។

- **បញ្ហានយោបាយៈ** រួមមានសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការបញ្ចេញមតិចូលជាសមាគមបោះឆ្នោតជ្រើសរើសមេដឹកនាំ សិទ្ធិក្នុងការផ្តល់នូវយោបល់ដើម្បីដាក់បញ្ចូលក្នុងគោល-ការណ៍ និងសិទ្ធិទាមទារឱ្យមាននូវការទទួលខុសត្រូវពីសំណាក់រាជរដ្ឋាភិបាល ។ ការតស៊ូមតិចំពោះរឿងនយោបាយមានបំណងពង្រីកវិសាលភាពប្រជាធិបតេយ្យដែលប្រព្រឹត្តទៅដោយមានការសន្ទនាគ្នារវាងរដ្ឋាភិបាល និងសង្គមស៊ីវិល ច្បាប់បោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងប្រទេសកម្ពុជា គឺជាឧទាហរណ៍មួយនៃការតស៊ូមតិដែលទាក់ទិនទៅនឹងបញ្ហានយោបាយ ។
- **បញ្ហាសេដ្ឋកិច្ច ៈ** ទាក់ទងទៅនឹងការរស់រានមានជីវិតរបស់ប្រជាពលរដ្ឋរួមបញ្ចូលទាំងការបានប្រើប្រាស់ទ្រព្យសម្បត្តិឬធនធានកត្តាប្រកួតប្រជែងទីផ្សារនិងគោលការណ៍ពាណិជ្ជកម្មទីផ្សារសេរី ។ នៅក្នុងប្រទេសកម្ពុជា ច្បាប់ដីធ្លីសិទ្ធិផ្នែកនេសាទនិងការងារកាត់ដេរ គឺជាឧទាហរណ៍នៃបញ្ហាសេដ្ឋកិច្ចដែលធ្វើឱ្យមានការបង្កើតឡើងនូវយុទ្ធនាការនៃការតស៊ូមតិ ។ តាមបែបផែនតូចមួយ អាជីវករនៅទីផ្សារមួយចំនួនអាចរៀបចំនូវយុទ្ធនាការនៃការតស៊ូមតិមួយបាន ឧទាហរណ៍ដូចជានៅពេលដែលពួកគាត់មានការមិនពេញចិត្តចំពោះតំលៃស្តង់លក់ទំនិញដែលថ្លៃហួសហេតុពេក ។ ទោះជាយ៉ាងនេះក្តី ជាទូទៅបញ្ហាសេដ្ឋកិច្ចមិនសូវបានទទួលការយកចិត្តទុកដាក់ពីសំណាក់អ្នកតស៊ូមតិនៅក្នុងប្រទេសកម្ពុជាប៉ុន្មានឡើយ ។

ក្នុងនាមជាអ្នកតស៊ូមតិត្រូវសិក្សានូវវិស័យទាំងបី នេះព្រោះវាអាចជួយលោកអ្នកដើម្បីជួយដល់ក្រុមទាំងឡាយដែលត្រូវបានគេដកហូតយកសិទ្ធិអំណាចហើយប្រែក្លាយពួកគេឱ្យមានសម្លេងឡើងវិញ ។ ជាលទ្ធផលចលនាទៅកាន់សិទ្ធិមនុស្សជាសកលនឹងត្រូវបានធ្វើឡើង ។

## ៤. ការកំណត់រៀបចំលើយុទ្ធនាការរបស់អ្នក. តើខ្ញុំគួរតែប្រើប្រាស់យុទ្ធនាការតស៊ូមតិប្រភេទណា?

មុននឹងចាប់ផ្តើមរៀបគំរោងយុទ្ធនាការតស៊ូមតិមួយ លោកអ្នកគួរតែគិតពិចារណាឱ្យបានល្អិតល្អន់អំពីបញ្ហាដែលលោកអ្នកចង់លើកឡើង ហើយនិងសហគមន៍ដែលលោកអ្នកចង់ធ្វើការតស៊ូមតិជាមួយ ។ ការពិចារណាទៅលើបញ្ហាទាំងប៉ុន្មានខាងក្រោមនេះ ពិតជារួមចំណែកជួយលោកអ្នកបង្កើតនូវយុទ្ធសាស្ត្រនៃការតស៊ូមតិមួយដែលមានប្រសិទ្ធភាព ។

**អ្នកដែលទទួលផលយុទ្ធនាការ ៈ**

**សំណួរ ៈ** អ្នកណាខ្លះដែលទទួលផលពីយុទ្ធនាការរបស់អ្នក ?

ការតស៊ូមតិអាចត្រូវបានរៀបចំបង្កើតឡើងជំនួសមុខឱ្យបុគ្គល ឬពលរដ្ឋជាច្រើន ។ ឧទាហរណ៍មួយនៃការតស៊ូមតិដែលជំនួសមុខឱ្យបុគ្គល គឺយុទ្ធនាការដើម្បីឱ្យមានការដោះលែងអ្នកទោសនយោបាយ ។ ការតស៊ូមតិជាមួយប្រជាជនដែលរងគ្រោះរួមមាន ប្រជាជនផ្ទុកមេរោគហ៊ីវ ឬជំងឺអេដស៍ (PLWHA's) ហើយការតស៊ូមតិគឺត្រូវបញ្ចុះបញ្ចូលរដ្ឋាភិបាល ដើម្បីឱ្យលោកផ្តល់នូវសេវាថែរក្សាសុខភាព និង ថ្នាំពេទ្យ ។ ការតស៊ូមតិអាចតម្រង់ទិសដៅទៅរកក្រុមមនុស្សមួយក្រុមដែលជួបបញ្ហា ឬមានចរិតលក្ខណៈដូចៗគ្នាដែលគេស្គាល់ថាជា ***ក្រុមចាប់អារម្មណ៍*** ។ ឧទាហរណ៍ការតស៊ូមតិដើម្បីក្រុមចាប់អារម្មណ៍អាចមានដូចជាការគាំទ្រ កម្មករពិការ ឬ កសិករ ។

**អ្នករៀបចំយុទ្ធនាការ :**

**សំនួរ** : អ្នកណាជាអ្នកផ្តួចផ្តើមយុទ្ធនាការ ? នរណាខ្លះនឹងប្រឡូកនៅក្នុងយុទ្ធនាការនេះហើយស្ថិតនៅក្នុងសមត្ថភាពប៉ុណ្ណា? តើសហគមន៍រងគ្រោះនឹងត្រូវបានដាក់បញ្ចូលហើយផ្តល់សិទ្ធិអំណាចឱ្យយុទ្ធនាការដោយរបៀបណា ?

ការតស៊ូមតិ អាចរៀបចំដោយជនទាំងឡាយណាដែលកំពុងជួបបញ្ហាដោយខ្លួនពួកគេផ្ទាល់ ឬក៏អាចរៀបចំឡើងដោយបុគ្គលមួយក្រុម ឬទីភ្នាក់ងារណាមួយដែលមានការព្រួយបារម្ភចំពោះស្ថានការណ៍ណាមួយ ។ បុគ្គល ឬសហគមន៍ដែលងាយរងគ្រោះកាន់តែទំនងជាអ្នករៀបចំការតស៊ូមតិដោយខ្លួនពួកគេផ្ទាល់ ប្រសិនជាមានការពង្រឹងអំណាចដល់ពួកគេ។ ក្រុមអ្នកភូមិដែលធ្វើការតវ៉ាប្រឆាំងនឹងរឿងទំនាស់ដីធ្លីហើយពុំទាន់មានដំណោះស្រាយកម្មកររោងចក្រកាត់ដេរដែលចូលរួមធ្វើកូដកម្មទាំងនេះសុទ្ធតែជាឧទាហរណ៍នៃការតស៊ូមតិដែលរៀបចំឡើងដោយជនដែលកំពុងជួបបញ្ហាដោយផ្ទាល់ខ្លួនរបស់ពួកគេ។ ការផ្តល់សិទ្ធិអំណាចតិចតួចតែងតែនាំឱ្យបុគ្គល ឬ ភ្នាក់ងារខាងក្រៅមានការព្រួយបារម្ភណ៍ ហើយផ្តួចផ្តើមសកម្មភាពតស៊ូមតិឡើង។ ទោះជាយ៉ាងនេះក៏ដោយ ប្រសិនបើពួកគេចង់ឱ្យសកម្មភាពរបស់ខ្លួននៅតែដំណើរការទៅមុខបានក្រុមជនដែលរងការប៉ះពាល់បញ្ហាទាំងនោះចាំបាច់ត្រូវមានជំនាញនៃការតស៊ូមតិដ៏មាំមួនមួយហើយបញ្ចូលយុទ្ធនាការរបស់ខ្លួនទៅក្នុងការខិតខំប្រឹងប្រែងបង្កើតឱ្យមានការតស៊ូមតិរបស់អង្គការក្រៅរដ្ឋាភិបាល និងអង្គការសហគមន៍ (CBOs) ចាប់តាំងពីដំបូងមក ។ ឧទាហរណ៍ដ៏សមរម្យមួយដែលទាក់ទងក្នុងរឿងនេះ គឺករណីបុគ្គលដែលផ្ទុកមេរោគហ៊ីវ (HIV+)បើទោះជាអង្គការសុខភាពអាចផ្តួចផ្តើមការតស៊ូមតិជំនួសពួកគេក៏ដោយតែយុទ្ធនាការមួយដែលមានប្រសិទ្ធភាពជាងនេះទៅទៀតនោះគឺ ត្រូវតែផ្តោតអារម្មណ៍លើការចូលរួមពីសំណាក់អ្នកផ្ទុកមេរោគហ៊ីវ(HIV)ឱ្យពួកគេធ្វើការប្រយុទ្ធប្រឆាំងនឹងការរើសអើងនិង ការតស៊ូមតិអោយមានការព្យាបាលនិងថែរទាំសុខភាពផងដែរ ។

**ការបែងចែកភូមិសាស្ត្រ :**

**សំណួរ** : ក្រុមដែលរងគ្រោះស្ថិតនៅឯណា ? ប្រសិនបើបុគ្គលទាំងឡាយក្នុងក្រុមនេះស្ថិតនៅរាយប៉ាយពីគ្នា តើពួកគេដឹងថាមានបញ្ហារួមគ្នាដែរឬទេ ?

សហគមន៍ទាំងឡាយដែលទទួលរងគ្រោះនូវបញ្ហាមួយដូចជា ភូមិ ឃុំ ខេត្ត ។ល។ ឬក៏ពួកគេនៅរាយប៉ាយក្នុងចំណោមប្រជាពលរដ្ឋទូទៅ ។ ឧទាហរណ៍ កម្មកររោងចក្រពួកគេរស់នៅក្នុងតំបន់ប្រមូលផ្តុំ ចំណែកឯជនពិការដោយសារគ្រាប់មីនវិញរស់នៅពាសពេញប្រទេស ។ អ្នកតស៊ូមតិដើម្បីក្រុមទាំងពីរនេះ គេប្រើប្រាស់យុទ្ធសាស្ត្រខុសគ្នាអាស្រ័យទៅលើលក្ខណៈភូមិសាស្ត្រប្រមូលផ្តុំ ឬរាយប៉ាយរបស់សហគមន៍ដែលរងការប៉ះពាល់។ ការតស៊ូមតិដែលតម្រង់ទិសដៅទៅរកប្រជាជនដែលស្ថិតនៅតំបន់តាមភូមិសាស្ត្រប្រមូលផ្តុំ មានលក្ខណៈងាយស្រួលជាងការតស៊ូមតិដែលប្រាថ្នាចង់ទៅដល់ ឬចង់ទទួលបានការគាំទ្រពីសំណាក់បុគ្គលនៅរាយប៉ាយទូទាំងប្រទេសដែលមានលក្ខណៈស្មុគស្មាញច្រើន និងមានការពិបាកក្នុងការរៀបចំព្រោះទាមទារឱ្យមាននូវប្រភពធនធានច្រើនទៀតផង ។

**កម្រិតនៃការឆ្លើយតប :**

**សំណួរ** : តើគួរចាប់ផ្តើមយុទ្ធនាការថ្មីមួយ ឬប្រើប្រាស់យុទ្ធនាការដែលកំពុងមាន ?

យោងទៅតាមសភាពនិងការបែងចែកភូមិសាស្ត្រនៃបញ្ហាយុទ្ធនាការនៃការតស៊ូមតិអាចតម្រង់ទៅរកកម្រិត

ថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ឬថ្នាក់អន្តរជាតិ។ ប្រសិនបើមានភូមិតែមួយដែលមានបញ្ហាជម្លោះដីធ្លី ចម្លើយដ៏សមរម្យមួយគឺជាការឆ្លើយតបដែលតម្រង់ទិសដៅទៅរកភូមិ ឃុំ ស្រុក ឬអាជ្ញាធរខេត្តជាការសមស្រប ។ ប្រសិនបើបញ្ហានោះមាននៅពាសពេញប្រទេស ការឆ្លើយតបអាចចាំបាច់ជាកម្រិតថ្នាក់ជាតិ ។ ប្រសិនបើមានបញ្ហាឆ្លងដែនណាមួយដូចជាការជួញដូរផ្លូវភេទ ហ៊ីវ (HIV) ឬបញ្ហាពាណិជ្ជកម្មនានា ចម្លើយតបអាចនឹងដោះស្រាយទៅតាមកម្រិតថ្នាក់អន្តរជាតិ ។ ប្រសិន បើអង្គការរបស់លោកអ្នកខ្វះធនធានដើម្បីធ្វើឱ្យការងារប្រព្រឹត្តទៅនៅកម្រិតថ្នាក់ជាតិ ឬអន្តរជាតិបាន លោកអ្នកអាចចងសម្ព័ន្ធជាមួយនិងបណ្តាយុទ្ធនាការតស៊ូមតិដទៃទៀត ដែលពួកគេកំពុងធ្វើការនៅត្រឹមកម្រិតទាំងនេះស្របពេលគ្នាដែលលោកអ្នកតម្រង់ទិសដៅទៅរកកម្រិតថ្នាក់មូលដ្ឋាន ។ ឧទាហរណ៍ ការខំប្រឹងប្រែងដើម្បីបញ្ឈប់ការជួញដូរស្ត្រីភេទ និងកុមារ ចាំបាច់ត្រូវតែផ្តួចផ្តើមឡើងនៅកម្រិតថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និង ថ្នាក់អន្តរជាតិ ដើម្បីឱ្យវាមានប្រសិទ្ធភាព ។

ជារឿយៗប្រភេទនៃបញ្ហា និងកម្រិតចាំបាច់នៃការឆ្លើយតបនឹងកំណត់ឱ្យយើងឃើញថាតើវាជាប់ទាក់ទងនឹងអ្នកតស៊ូមតិណាខ្លះហើយត្រូវប្រើយុទ្ធសាស្ត្រណាខ្លះ តាមធម្មតាបញ្ហាមូលដ្ឋានគឺអ្នកមូលដ្ឋានជាអ្នកដោះស្រាយមានដូចជា ក្រុមប្រឹក្សាឃុំ-សង្កាត់ និងមេដឹកនាំសហគមន៍ជាដើម ។ អង្គការពហុភាគី និងអង្គការអន្តរជាតិដូចជាធនាគារពិភពលោក ឬក៏អង្គការសហប្រជាជាតិ គឺជាអ្នកដែលសមនឹងដោះស្រាយបញ្ហាសកល ដូចជាភាពមិនសមាមាត្រផ្នែកពាណិជ្ជកម្ម និងការឆ្លងរាលដាលនៃជំងឺអេដស៍លើពិភពលោក ។ ដើម្បីឱ្យមានប្រសិទ្ធភាពជាងនេះទៅទៀតនោះ អង្គការទាំងនេះនឹងត្រូវធ្វើការរួមជាមួយនិងអង្គការជាតិ ឬ អន្តរជាតិនានាដែលមានចំណាប់អារម្មណ៍ក្នុងរឿងនេះ ។

**វិធីឆ្លើយតប :**

**សំណួរ :** តើយុទ្ធនាការតស៊ូមតិរបស់លោកអ្នកទាមទារការដោះស្រាយកម្រិតណា ?

ពេលណាស្ថានភាពនៃការតស៊ូ មតិ មិនមានការគំរាមកំហែងឬបន្ទាន់ សកម្មភាពផ្ទាល់មិនសូវជាល្អដូចជាយុទ្ធសាស្ត្ររយៈពេលវែងឡើយ ។ ជារឿយៗយុទ្ធនាការទាំងនេះរួមបញ្ចូលនូវយុទ្ធសាស្ត្ររយៈពេលវែង ដើម្បីបង្កើតឬផ្លាស់ប្តូរគោលនយោបាយនិងរួមទាំងការចរចាកម្រិតខ្ពស់។ លោកអ្នកគួរតែបង្កើតឱ្យមានបរិយាកាសប្រជាធិបតេយ្យជាចាំបាច់ដើម្បីពិភាក្សា និងចរចាអំពីបញ្ហាតស៊ូ មតិទាំងឡាយនោះ។ កម្រិតនៃការទាមទារដើម្បីដោះស្រាយគួរតែត្រូវបានសិក្សា ដោយអនុលោមតាមតម្រូវការរបស់ក្រុមដែលរងការប៉ះពាល់ និងពិនិត្យតាមស្ថានភាពនៃពេលវេលា។ កំលាំង និងប្រភេទយុទ្ធសាស្ត្រនៃការតស៊ូ មតិវាអាស្រ័យទៅលើថា តើស្ថានការណ៍នោះវាគំរាមកំហែងប៉ុនណាដែលអាចធ្វើឱ្យជះឥទ្ធិពលដល់ក្រុមមនុស្សក្នុងតំបន់នោះបាន។ ជម្លោះកើតឡើងនៅពេលណាដែលក្រុមមួយអត់ទ្រាំនឹងបញ្ហាមួយលែងបានតទៅទៀត ទើបពួកគេក៏សម្រេចចិត្តចាត់វិធានការណ៍ ។ ជម្លោះអាចជា ហិង្សា ឬ អហិង្សា អាចគ្រប់គ្រងបាន ឬមិនអាចគ្រប់គ្រងបាន អាចបណ្តាលឱ្យមានមហន្តរាយ ឬក៏អាចនាំមកនូវលទ្ធផលជាផ្លែផ្កា ។ រាល់ជម្លោះទាំងអស់មិនមែនសុទ្ធតែនាំមកនូវការខូចខាតដល់ប្រយោជន៍នោះទេ តែផ្ទុយទៅវិញវាអាចនាំមកនូវ សារប្រយោជន៍ក្នុងការធ្វើយុទ្ធនាការតស៊ូមតិបាន ប្រសិនបើជម្លោះនោះត្រូវបានគេរៀបចំត្រឹមត្រូវតាមបែបផែនបច្ចេកទេសដោយមានការជួយជ្រោមជ្រែង ពីបណ្តាអ្នកតស៊ូមតិដ៏ទៃទៀត។ឧទាហរណ៍សហគមន៍នេសាទមួយចំនួន

បានធ្វើការរឹបអូសម៉ាស៊ីនបូមទឹកខុសច្បាប់យកទៅប្រគល់ឱ្យមន្ទីរជលផលមូលដ្ឋានដើម្បីទាមទារឱ្យមានការចុះធ្វើប្រតិបត្តិការណ៍អង្កេត។ អ្នកធ្វើការតស៊ូមតិមិនត្រូវព្យាយាមធ្វើអ្វីមួយឱ្យមានការរាំងស្ទះដល់ការអំពាវនាវនានាសំដៅឱ្យមានសកម្មភាពពីសហគមន៍ទាំងឡាយនោះទេ តែពួកគេគួរតែព្យាយាមជួយធ្វើយ៉ាងណាដើម្បីណែនាំ ឬជួយសម្រួលយ៉ាងណាឱ្យសមស្របក្នុងយុទ្ធនាការតស៊ូមតិដែលមានទ្រង់ទ្រាយធំជាងនេះ។

# ការរៀបចំយុទ្ធសាស្ត្រនៃការតស៊ូមតិ

កំណត់នូវអត្តសញ្ញាណនៃបញ្ហា

កំណត់គោលបំណង

## គោលការណ៍ ៥ ជំហានដើម្បីរៀបចំយុទ្ធនាការតស៊ូមតិ

កំណត់មនុស្សគោលដៅមានឥទ្ធិពលសមស្រប

ការប៉ាន់ប្រមាណលើធនធាន

ការធ្វើផែនការ

## ជំហានទី១ ការកំណត់នូវអត្តសញ្ញាណនៃបញ្ហា

ជំហានដំបូងក្នុងការរៀបចំនិងការអនុវត្តយុទ្ធនាការតស៊ូមតិមួយ គឺត្រូវ**វិភាគបញ្ហា**ដែលអ្នកចង់តម្រង់ទិសដៅទៅរក ។ ការយល់ឱ្យបានច្បាស់និងស៊ីជំរៅដល់បុព្វហេតុនៃបញ្ហា វាពិតជាសំខាន់ណាស់ក្នុងការបង្កើតឱ្យមានរូបរាងយុទ្ធនាការនៃការតស៊ូមតិដែលមានប្រសិទ្ធភាព និងទទួលបានការចាប់អារម្មណ៍ពីសំណាក់អ្នកធ្វើការសម្រេចចិត្ត ។ តាមធម្មតាបញ្ហាទាំងឡាយដែលបានកើតឡើងចេញពីគោលនយោបាយគឺពិតជាមិនអាចដោះស្រាយក្នុងកម្រិតបុគ្គលនោះបានឡើយ ។ វាត្រូវតែដោះស្រាយតាមវិធីដែលមានការរៀបចំត្រឹមត្រូវដែលអាចនាំទៅរកគោលនយោបាយមួយប្រសើរជាងនេះបាន ។

បើសិនជាបញ្ហាមួយកើតឡើងនៅតំបន់មួយជាក់លាក់នោះអ្នក និងអ្នកតស៊ូមតិទាំងឡាយផ្សេងទៀត គួរតែចុះទៅមើលតំបន់ និងសហគមន៍នៅជុំវិញនោះផង ដើម្បីអោយដឹងថា តើពួកគេធ្លាប់បានជួបប្រទះបញ្ហាដូចគ្នានេះដែរឬទេ។ បើសិនជាបញ្ហានោះកើតមានឡើងនៅក្នុងតំបន់ទាំងឡាយជុំវិញនោះដែរ វាជាការចាំបាច់ក្នុងការប្រមូលពតិមានឱ្យបានសុក្រិត្យ ហើយកត់ត្រាជាឯកសារនូវទំហំនៃបញ្ហានោះ ។ ដំណើរការនៃការយល់ដឹងនូវបញ្ហា គួរតែបញ្ចូលសហគមន៍នានាដែលទទួលរងការប៉ះពាល់ពីបញ្ហាផង។ អ្នកភូមិនិងសហគមន៍ដែលជួបបញ្ហា គឺជាប្រភពធនធានដ៏សំខាន់ និងជាដៃគូរបស់អង្គការ ក្នុងការស្វែងយល់អំពីបញ្ហានាពេលបច្ចុប្បន្ន និងទៅអនាគត ។

***សំណួរជាគន្លឹះមួយចំនួនដែលលោកអ្នកត្រូវតែឆ្លើយឱ្យបានមុនបង្កើតយុទ្ធនាការរបស់លោកអ្នក :***

- តើប្រវត្តិរបស់បញ្ហានោះវាយ៉ាងណា? តើវាកើតតាំងពីពេលណាមក ? តើវានៅតែកំពុងកើតឡើងឬទេ ?
- តើនរណាខ្លះទទួលផលប៉ះទង្គិចពីវា ?
- តើនរណាមានសិទ្ធិអំណាចបង្ក្រាប ឬក៏ប្តូរវាបាន ?
- តើធ្លាប់មានយុទ្ធនាការតស៊ូមតិផ្សេងៗដែលចង់ផ្លាស់ប្តូរស្ថានការណ៍នោះហើយឬនៅ ?
- តើមានក្រុមដទៃណាទៀត ( អង្គការមិនមែនរដ្ឋាភិបាលទីភ្នាក់ងារផ្តល់ជំនួយផ្នែកឯកជន នាយកដ្ឋាន រដ្ឋាភិបាល ឬអង្គការសង្គមស៊ីវិលដ៏ទៃទៀត) ដែល ចាប់អារម្មណ៍ក្នុងការចូលរួមធ្វើការជាមួយអ្នកដែរ ឬទេ ?
- តើបញ្ហានោះកំពុងកើតឡើងក្នុងកម្រិតណាមួយ ? តើវាគ្រាន់តែជាបញ្ហានៅក្នុងភូមិមួយ ឬក៏វាជាផ្នែកមួយដែលទាក់ទងនិងបញ្ហាគោលនយោបាយចម្បងណាមួយ ?
- តើមានអ្វីខ្លះទៀតដែលលោកអ្នកចាំបាច់ត្រូវដឹងដើម្បីឱ្យបានយល់ពីបញ្ហាពេញលេញ ?
- តើមានឯកសារស្ថិតិស្រាវជ្រាវណាមួយអាចផ្តល់នូវភស្តុតាងបន្ថែមអំពីបញ្ហានោះដែរឬទេ ?

***ចូរចងចាំថានេះគឺគោលការណ៍ណែនាំមួយប៉ុណ្ណោះ*** លោកអ្នកសាកសួរខ្លួនឯងទៅមើល ថាតើមានអ្វីខ្លះទៀត ដែលលោកអ្នកចាំបាច់ត្រូវតែដឹងស្តីអំពីបញ្ហាជាក់លាក់ណាមួយនោះ ។

## ជំហានទី ២ កំណត់គោលបំណងជាក់លាក់

បន្ទាប់ពីលោកអ្នកបានបញ្ជាក់ឫសគល់នៃបញ្ហារួច មក លោកអ្នកគួរតែសម្រេចចិត្តទៅ**លើគោលបំណងជាក់លាក់ណាមួយសម្រាប់គម្រោងការតស៊ូមតិរបស់លោកអ្នក** ។ ជារឿយៗយុទ្ធនាការតស៊ូមតិអាចមានកំហុស ដោយការកំណត់គោលបំណងនិងគោលនយោបាយស្មើឡើងខ្ពស់ពេក ដែលមិនអាចទទួលយកបានពីសំណាក់អ្នកតាក់តែងគោលនយោបាយ ឫក៏វាមានចន្លោះតិចតួចពេកសម្រាប់ការចរចា បើដូច្នេះមែន ឱកាសទទួលបានលទ្ធផលល្អមានតិចតួច ណាស់ ។ វាជាការប្រសើរបើលោកអ្នកចាប់ផ្តើមជាមួយនិងគោលបំណងដែលសមល្មមនឹងអាចទទួលយកបាន ហើយពង្រីកវិសាលភាពរបស់វាទៅតាមជោគជ័យនានាជាបន្តបន្ទាប់វិញ ។ គោលបំណងរបស់អ្នកត្រូវតែគិតឱ្យទទួលបានជោគជ័យនិងសមហេតុសមផល ។ ប្រសិនបើមានគោលបំណងខ្ពស់ពេក អង្គការរបស់លោកអ្នកអាចនឹងខ្វះប្រភពធនធាន និងបាត់បង់នូវការខំប្រឹងប្រែងមុននឹងលោកអ្នកបានទទួលនូវគោលបំណងនោះ ។

គោលបំណងសម្រាប់អ្នកតស៊ូមតិខាងក្រៅណាម្នាក់ គួរតែបង្កើតយុទ្ធសាស្ត្រមួយដែលចុងបញ្ចប់នឹងផ្តល់អំណាចដល់សហគមន៍ដែលរងគ្រោះទាំងឡាយនោះ ។ ការផ្តល់សិទ្ធិអំណាចគួរតែគិតថាជាគោលដៅមួយក្នុងចំណោមគោលដៅជាច្រើនរបស់លោកអ្នក ។ សហគមន៍ទាំងនេះគួរតែដឹកនាំឱ្យមានការផ្តួចផ្តើមមួយដើម្បីធានាឱ្យយុទ្ធនាការមាននូវដំណើរការទៅមុខ ។ ថ្វីបើអ្នកខាងក្រៅអាចបំពេញតួនាទីជាកាតាលីករដ៏សំខាន់ក្នុងយុទ្ធនាការក៏ដោយ វាជាការសំខាន់ណាស់ដែលអង្គការមិនមែនរដ្ឋាភិបាលមើលឃើញសហគមន៍ដែលពួកគេធ្វើការជាមួយថាជាភ្នាក់ងារនៃបំលាស់ប្តូរដែលមានលទ្ធភាពតាក់តែងនូវរបៀបវារៈសម្រាប់ការតស៊ូមតិបាន។

តាំងតែពីដើមរៀងមកការកំណត់វត្ថុបំណងជាក់ លាក់ជាចំណុចខ្សោយមួយស្ទើរតែនៅគ្រប់យុទ្ធសាស្ត្រការតស៊ូមតិនៅក្នុងប្រទេសកម្ពុជា ។ ករណីសិក្សាពីរដែលបានដាក់បង្ហាញជូនបានបញ្ជាក់ឱ្យឃើញថា យុទ្ធនាការដែលមិនបានទទួលផលគឺដោយសារតែកង្វះភាពច្បាស់លាស់ក្នុងការកំណត់គោលបំណង និងយុទ្ធសាស្ត្រ។

សកម្មភាពខ្លះទៀតមានតែនៅលើក្រដាស ប៉ុន្តែនៅពេលអនុវត្តន៍មិនឃើញមានឥទ្ធិពលអ្វីជាធំដុំ ហើយការប្រើប្រាស់ធនធានក៏មិនប្រកបដោយប្រសិទ្ធភាព។ ឧទាហរណ៍ អ្នកតស៊ូមតិពេលខ្លះសម្រេចធ្វើបាតុកម្មជាការចាំបាច់មួយដើម្បីសម្តែងនូវការមិនពេញចិត្តទៅលើរឿងអ្វីមួយ ។ ពិតមែនតែបាតុកម្ម គឺជាយន្តការមួយដែលមានប្រសិទ្ធិភាព តែវាទាមទារពេលវេលា និងការខិតខំច្រើនក្នុងការរៀបចំឡើង។ បើមនុស្សមកចូលរួមមានចំនួនតិច ប្រព័ន្ធផ្សព្វផ្សាយមិនយកចិត្តទុកដាក់បានគ្រប់គ្រាន់ ហើយអ្នកធ្វើគោលនយោបាយក៏មិនមានការចាប់អារម្មណ៍ដែរ ។ អ្នកគាំទ្រត្រូវវិភាគទៅលើប្រយោជន៍នៃសកម្មភាពតស៊ូមតិ ហើយធ្វើយ៉ាងណាឱ្យមានសកម្មភាពធ្វើជាបន្តដើម្បីពង្រឹងបន្ថែមសកម្មភាពនោះ។

***គោលបំណងទូទៅ(Goal) ខ្លះៗដែលអ្នកត្រូវកំណត់មុនពេលចាប់ផ្ដើមយុទ្ធនាការតស៊ូមតិ :***

- ***គោលបំណងទូទៅរយៈពេលខ្លី : (Short Term Goals)*** អ្វីដែលអ្នកចង់សម្រេចបាន នៅក្នុងពេលអនាគតដ៏ខ្លី ចំពោះមុខនេះ ។
- ***គោលបំណងទូទៅរយៈពេលវែង :(Long Term Goals)*** អ្វីដែលអ្នកចង់សម្រេចបាននៅ ក្នុងរយៈពេលវែងទៅមុខ ។
- ***គោលបំណងទូទៅជាក់ស្ដែង ( Content Goals)*** ការផ្លាស់ប្ដូរពិតប្រាកដមួយ ដែលអ្នកចង់ឱ្យវាកើតមានឡើង (ឧទាហរណ៍ ការផ្លាស់ប្ដូរលើគោលនយោបាយ)
- ***គោលបំណងជាដំណើរការ (Process Goals)*** អ្វីដែលអ្នកចង់ឱ្យអង្គការរបស់ អ្នកទទួលបានពីយុទ្ធនាការនេះ (ឧទាហរណ៍ ការកសាងសមត្ថភាពនៅក្នុងរង្វង់អង្គការ របស់អ្នក)
- ***គោលបំណងនៃការផ្ដល់សិទ្ធិអំណាច : ( Empowerment Goals)*** ការប្រែប្រួលដែលអ្នកចង់ឱ្យមាននៅតាមសហគមន៍ដែលពាក់ព័ន្ធនឹងបញ្ហា ដើម្បីឱ្យពួកគេអាចគ្រប់គ្រងបានលើមធ្យោបាយរស់នៅរបស់ពួកគេ ។

## ជំហានទី៣ កំណត់តួអង្គគោលដៅមានឥទ្ធិពលសម្រេច

តើអ្នកចង់ធ្វើយុទ្ធនាការមាន ទិសដៅទៅរកអ្នកណាពិតប្រាកដ? នៅពេលរៀបចំនូវយុទ្ធសាស្ត្រតស៊ូមតិ **អ្នកត្រូវប្រាកដថាមនុស្សគោលដៅដែលមានឥទ្ធិពលគឺជាអ្នកដែលមានអំណាចផ្លាស់ប្ដូរគោលនយោបាយ ។**

> **ជាទូទៅកំហុសដែលច្រើនមាននៅក្នុងប្រទេសកម្ពុជា គឺគេខិតខំធ្វើការតស៊ូមតិតែជាមួយនឹងរាជការថ្នាក់ក្រោមហើយនៅពេលជាមួយគ្នានោះពួកគេក៏ភ្លេចរៀបចំយុទ្ធសាស្ត្រដើម្បីធ្វើការបញ្ចុះបញ្ចូលមន្ត្រីថ្នាក់ខ្ពស់ដែលជាអ្នកធ្វើការសម្រេចចិត្តចុងក្រោយ។**

ការនេះមានន័យថា អ្នកត្រូវមានការយល់ឱ្យបានច្បាស់ទៅលើទំនាក់ទំនងនៃអំណាចនិងលំដាប់ថ្នាក់នៅក្នុងស្ថាប័នមួយ ដើម្បីយល់បានបែបនេះអ្នកប្រហែលជាត្រូវការជំនួយបច្ចេកទេសពីអ្នកឯកទេសដែលមានការយល់ដឹងពីស្ថាប័ននោះច្បាស់លាស់ ។ ឧទាហរណ៍ អ្នកធ្វើការតស៊ូមតិអាចទាត់ចោល ឬចាប់ផ្ដើមបញ្ចុះបញ្ចូលអ្នកដែលមានសិទ្ធិសម្រេចចិត្តយ៉ាងសំខាន់ ឬអាចចាប់ផ្ដើមធ្វើការបញ្ចុះបញ្ចូលស្ថាប័នរដ្ឋាភិបាលខុសនៅមុនពេលកំណត់ឱ្យបានច្បាស់ថាតើនរណានៅក្នុងជួររដ្ឋាភិបាលដែលមានការទទួលខុសត្រូវលើគោលនយោបាយនោះ ។

វាជាការសំខាន់ដែលត្រូវកំណត់ពីបុគ្គល ឬក្រុមដែលមានសមត្ថភាពធ្វើការបញ្ចុះបញ្ចូលអាជ្ញាធរ ក្រុមទាំងនេះរួមមានប្រព័ន្ធឃោសនា និងមជ្ឈដ្ឋានសំខាន់ៗដូចជាទីភ្នាក់ងារម្ចាស់ជំនួយ ស្ថានទូត និង ក្រុមអ្នកដើរបញ្ចុះបញ្ចូល ។ អង្គការសិទ្ធិមនុស្សតាមទម្លាប់កន្លងមក ពូកែជាងគេខាងបញ្ចុះបញ្ចូលរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជា។ ដូច្នេះបើអ្នកធ្វើការលើបញ្ហាដែលទាក់ទងនឹងសិទ្ធិមនុស្ស អ្នកគួរតែទៅទាក់ទងនឹងអង្គការទាំងនេះ។ ក្នុងករណីដែលអាចធ្វើបានត្រូវបង្កើតការទាក់ទងជាប់លាប់ជាមួយ និងអង្គការដែលមានទំនាក់ទំនងរឹងមាំជាមួយនឹងអ្នក សម្រេចការនានាដើម្បីទាញយកប្រយោជន៍ពីទំនាក់ទំនង ដែលមានជាប់លាប់មកនោះ។

មានការឯកភាពរួមមួយគឺថា ជាទូទៅម្ចាស់ជំនួយកំពុងតែបែរពីផ្នែកអភិវឌ្ឍន៍សហគមន៍ទៅរកការតស៊ូមតិនិងអភិបាលកិច្ច ម្ចាស់ជំនួយនិងអង្គការអន្តរជាតិនានាអាចផ្តល់ដល់អ្នកនូវការគាំទ្រផ្នែកថវិកា និងការដាក់ការគាបសង្កត់ទៅលើរដ្ឋាភិបាលឱ្យធ្វើការផ្លាស់ប្តូរគោលនយោបាយរបស់ខ្លួន។ ដូចច្នេះធ្វើយ៉ាងណាកុំភ្លេចបញ្ចូលពួកគេទៅក្នុងផ្នែកមួយនៃយុទ្ធនាការរបស់អ្នក ដើម្បីទទួលផលប្រយោជន៍គាំទ្រពីប្រជាជន ហិរញ្ញវត្ថុ និង នយោបាយ ។

***សំណួរដើម្បីជួយដល់ការកំណត់តួអង្គគោលដៅដែលមានឥទ្ធិពល :***

- តើមនុស្សនិងស្ថាប័នណាដែលអ្នកត្រូវការប្រាស្រ័យទាក់ទងជាមួយ ?
- តើកម្រិតណាមួយនៅក្នុងរដ្ឋាភិបាលដែលអ្នកចង់ប្រាស្រ័យទាក់ទងជាមួយ ហើយថាតើគេស្តាប់នូវអ្វីដែលអ្នកចង់ប្រាប់គេដែរឬទេ ?
- តើតួអង្គដទៃណាខ្លះដែលនឹងអាចធ្វើឱ្យមានឥទ្ធិពលដល់ពួកគេ ( ឧទាហរណ៍ ភ្នាក់ងារអង្គការសហប្រជាជាតិ ភ្នាក់ងារផ្តល់ជំនួយនិងអង្គការក្រៅរដ្ឋាភិបាល) ដែលធ្វើការបញ្ចុះបញ្ចូល ? ។

## ជំហានទី ៤ ការប៉ាន់ប្រមាណលើធនធាន

នៅពេលកំណត់បានអ្នកត្រូវធ្វើការសម្រេចហើយ **ចាំបាច់ត្រូវធ្វើការប៉ាន់ប្រមាណលើធនធានទាំងអស់ដែលមានសម្រាប់យុទ្ធនាការតស៊ូមតិ ។** ចាំបាច់ត្រូវយល់ពីអ្វីដែលជាសេចក្តីត្រូវការសម្រាប់ចាត់ចែងយុទ្ធនាការមួយ ហើយមានធនធានគ្រប់គ្រាន់សម្រាប់ឈានទៅសម្រេចបំណងជាក់លាក់ (Objective) ។ បើមិនដឹងច្បាស់ពីធនធានដែលខ្លួនមានទេនោះ យុទ្ធនាការរបស់អ្នកអាចខ្វះធនធានសមស្របដើម្បីសម្រេចបានជោគជ័យលើបំណងជាក់លាក់របស់អ្នក ។

បើយុទ្ធនាការរបស់អ្នកត្រូវការនិរន្តរភាពក្នុងកំឡុងពេលយូរ ជាការល្អអ្នកគួរតែភ្ជាប់ជាមួយនិងបុគ្គលិកនៃអង្គការដែលជួយគាំទ្រ ឬអង្គការដែលជាដៃគូណាមួយនិងបុគ្គលិករបស់គេ ហើយថែមទាំងបញ្ចូលការគាំទ្ររបស់អ្នកស្ម័គ្រចិត្តដើម្បីទទួលបានផលប្រយោជន៍ទាំងធនធានមនុស្សនិងធនធានហិរញ្ញវត្ថុ ។

***ប្រមាណលើធនធានសំខាន់ៗរបស់អ្នក***

- ***ធនធានមនុស្ស*** តើបុគ្គលិកអង្គការរបស់អ្នកមានចំណុចខ្លាំងនិងចំណុចខ្សោយអ្វីខ្លះ? តើមនុស្សប៉ុន្មាននាក់នៅក្នុងអង្គការរបស់អ្នកដែលអាចធ្វើការបានលើយុទ្ធនាការ? តើគេមានជំនាញអ្វីខ្លះ ( បច្ចេកទេសទំនាក់ទំនងសង្គម ) តើបទពិសោធន៍របស់គេលើការតស៊ូមតិមានកម្រិតណា? តើត្រូវមានការកសាងសមត្ថភាពបន្ថែមអ្វីខ្លះដល់ធនធានមនុស្សសម្រាប់សកម្មភាពយុទ្ធនាការ ?
- ***បណ្តាញ*** តើនរណានឹងជួយអ្នក? តើគេមានចំណុចខ្សោយនិងចំណុចខ្លាំងអ្វីខ្លះ? តើអ្នកមានទំនាក់ទំនងយ៉ាងដូចម្តេចជាមួយនឹងអង្គាធរ? តើគេមានបណ្តាញរឹងមាំដែលមានក្រុមការងារធ្វើការលើបញ្ហាដែលអ្នកកំពុងតែពិចារណាដែរឬទេ ?
- ***ហិរញ្ញវត្ថុ*** តើមានថវិកាប៉ុន្មាន? តើបានពីខាងណាមក? តើប្រភពថវិកាអាចសម្រុះសម្រួលដល់គោលបំណងនៃយុទ្ធនាការបានដែរឬទេ?

## ជំហានទី ៥ ការធ្វើផែនការ

នៅពេលដែលអ្នកយល់ច្បាស់ពីសមត្ថភាពនៃអង្គការរបស់អ្នក និងគោលបំណងជាក់លាក់ (Objective) ដែលអ្នកចង់សម្រេចបណ្តាញដែលមានស្រាប់ ឬដែលនឹងត្រូវបង្កើតឡើងព្រមទាំងធនធានហិរញ្ញវត្ថុហើយ**អ្នកត្រូវធ្វើផែនការសកម្មភាព ។ ផែនការនេះកំណត់យុទ្ធសាស្ត្រ ឬសកម្មភាពជាក់លាក់នានាដែលភ្ជាប់និងយោងតាមពេលវេលា**គឺថា : ត្រូវដឹងច្បាស់នូវអ្វីដែលអ្នកចង់ធ្វើហើយនិងធ្វើ

នៅពេលណា ។ ទោះជាផែនការរបស់អ្នកត្រូវបានធ្វើឡើងដោយយោងតាមព្រឹត្តិការណ៍ក៏ដោយ តែបើគ្មានការព្រមព្រៀងគ្នារវាងដៃគូធ្វើការរួមគ្នានោះទេ យុទ្ធនាការតស៊ូមតិនឹងមានកង្វះខាតប្រសិទ្ធភាពខ្លះៗមិនខាន ។

## ផែនការលើយុទ្ធនាការ គួរតែត្រូវមាន :

- គោលបំណងទូទៅ គោលបំណងជាក់លាក់ និង សកម្មភាព ច្បាស់លាស់ ។
- សន្ទស្សន៍សម្រាប់វាស់វែងសកម្មភាព ។
- ការវិភាគដែលរៀបរាប់ពីអ្វីដែលអ្នកនឹងសម្រេចនិងពេលវេលា ។
- ការកំណត់អ្នកពាក់ព័ន្ធសំខាន់ៗ ហើយនិងវិធីបញ្ចូលពួកគេទៅក្នុងយុទ្ធសាស្ត្ររបស់អ្នក ។
- ការស៊ែងឆែកការងារច្បាស់លាស់ ដើម្បីឱ្យអ្នកចូលរួមម្នាក់ៗដឹងច្បាស់ថាកាន់មុខងារអ្វី ?
- វិធីសាស្ត្រច្បាស់លាស់នៅក្នុងការប្រមូលនិងផ្សព្វផ្សាយព័ត៌មាន បញ្ចុះបញ្ចូលដល់តួអង្គគោលដៅ ។
- វិធីសម្រាប់ធ្វើការតាមដាននិងកែសម្រួលយុទ្ធនាការ ។
- យន្តការសម្រាប់ត្រួតពិនិត្យនិងវាយតំលៃយុទ្ធនាការរបស់អ្នក ។
- ផែនការបម្រុងទុកផ្សេងទៀតសម្រាប់ត្រៀមទុកប្រសិនបើយុទ្ធសាស្ត្រស្នូលរបស់អ្នកមិនមានប្រសិទ្ធភាពទេនោះ ។



សិក្ខាសាលាស្តីអំពី " ស្ត្រីនិង អភិបាលកិច្ចល្អ " នៅខេត្តពោធិសាត់ដែលគាំទ្រដល់ការចូលរួមរបស់ស្ត្រី ទាំងឡាយនៅក្នុងឆាកនយោបាយនិងបង្កើនការពិភាក្សាគ្នារវាងបេក្ខជន និងបេក្ខនារីទាំងឡាយ។

# ការណែនាំ ៥ ជំហានសម្រាប់ការអនុវត្តន៍ យុទ្ធនាការតស៊ូមតិ

នៅពេលអ្នកកំណត់បានបញ្ហាសម្រាប់ លើកយកមកធ្វើការតស៊ូមតិ ដូចជាគោលបំណងជាក់លាក់ (Objective) បុគ្គលដែលមានឥទ្ធិពល ធនធាន និងផែនការសម្រាប់រយៈពេលយូរ ហើយអ្នកអាចរៀបចំប្រការមួយៗដោយឡែកៗសម្រាប់យុទ្ធនាការ ។ ការដែលមិនមានរូបមន្តអ្វីដែលប្រាកដប្រជាសម្រាប់ធ្វើឱ្យយុទ្ធនាការតស៊ូមតិទទួលបាននូវជោគជ័យនោះ អ្នកគួរចងចាំទុកនូវចំណុចជាគន្លឹះចំនួនបី ។ ទីមួយៈ យុទ្ធនាការតស៊ូមតិដែលទទួលបានជោគជ័យគួរផ្តោតអារម្មណ៍លើបញ្ហាផ្ទាល់ជាជាងរង់ចាំបញ្ហានោះត្រូវបានគេដោះស្រាយ ។ ឧទាហរណ៍ ការញែកឱ្យដាច់រវាងគោលបំណងយុទ្ធនាការ និងការបំពេញលើអាទិភាពឯកជន និងអង្គការ ។ ទីពីរៈ យុទ្ធនាការដែលទទួលបានជោគជ័យប្រហែលត្រូវការបច្ចេកទេស និងវិធីសាស្ត្រថ្មីៗខ្លះ ។ ចូររៀនសូត្រពីយុទ្ធនាការតស៊ូមតិនៅក្នុងពេលកន្លងមកហើយថ្លៃប្រឌិតនៅក្នុងការប្រើប្រាស់បច្ចេកទេសឬវិធីថ្មីៗទាំងនោះ ។ ទីបីៈ យុទ្ធនាការតស៊ូមតិដែលទទួលបានជោគជ័យ គឺត្រូវប្រើប្រាស់សកម្មភាពទាំងឡាយដែលមានវិសាលភាពទូលាយ និងស៊ីសង្វាក់ជាជាងសកម្មភាពតែមួយ ឬក្រុមសកម្មភាពដែលមិនមានការទាក់ទងគ្នា ។

## ជំហានទី ១ ប្រមូលនិងផ្សព្វផ្សាយពត៌មាន

ការប្រមូលនិងផ្សព្វផ្សាយពតិមានជួយពង្រឹងដល់យុទ្ធនាការរបស់អ្នក និងផ្តល់ពតិមានដល់អ្នកសម្រេចចិត្តរួមទាំងភស្តុតាងអំពីភាពចាំបាច់និងហេតុផលដែលត្រូវធ្វើការកែទម្រង់ ។ មានពតិមានបីប្រភេទដែលអ្នកគួរប្រមូលនិងចែកចាយ គឺពតិមានស្តីពីបញ្ហា ពតិមានសាធារណៈ មតិភាគច្រើនស្តីអំពីដំណោះស្រាយដែលអាចធ្វើបានដូចជា ៈ

***ចងក្រងនិងកត់ត្រាឯកសារ*** ៈ ចាំបាច់ត្រូវមានពតិមានច្បាស់លាស់និងត្រឹមត្រូវ ។ ឧទាហរណ៍ យុទ្ធនាការតស៊ូមតិលើផ្នែកជលផលធ្វើទៅបានល្អ ដោយសារមានការប្រមូលពតិមានបានច្រើន ។ ក្រុមការងារផ្នែកជលផលរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា បានរៀបចំករណីសិក្សាមួយចំនួនដែលកត់ត្រាអំពីឧបទ្ទវហេតុនៃការរំលោភលើការនេសាទត្រី ។ ពតិមានទាំងនេះបានផ្តល់នូវការពិពណ៌នានិងពតិមានជាក់លាក់លើមាត្រានៃច្បាប់ដែលត្រូវបានគេកំពុងរំលោភ ។ ភស្តុតាងនេះបានបើកកកាយវិសាលភាពនៃការរំលោភ និងផ្តល់នូវការគាំទ្រយ៉ាងរឹងមាំនៅពេលមានការជជែកក្នុងការដោះស្រាយបញ្ហាជាមួយអាជ្ញាធរ ។ ទោះបីជាបញ្ហាពិសេសជាទំនាស់សេដ្ឋកិច្ច វិធីសាស្ត្របែបនេះក៏ធ្លាប់បានប្រើប្រាស់សម្រាប់បញ្ហា HIV/AIDS យ៉ាងមានប្រសិទ្ធភាពដែរ ។ លោកអ្នកគួរតែប្រមើលមើលឱ្យឃើញនូវពតិមានអ្វីដែលចាំបាច់សម្រាប់ធ្វើការតស៊ូមតិឱ្យមានប្រសិទ្ធភាព ដោយមានការពិចារណាអំពីអ្វីដែលអ្នកត្រូវធ្វើការសម្រេចចិត្តចង់បាន និងអាចត្រូវបញ្ចុះបញ្ចូលបាន ។ គ្រប់ពតិមានគួរតែមានជាសាធារណៈតាមដែលអាចធ្វើទៅបាន (គួរមានទាំងជាភាសាខ្មែរ និងភាសាអង់គ្លេស) ។

***ប្រមាណមតិសាធារណៈ*** ការជួយគាំទ្របានច្រើនរបស់មតិសាធារណៈធ្វើឱ្យគេមើលឃើញថា យុទ្ធនាការនេះមានលក្ខណៈជាធម្មានុរូប (ភាពត្រឹមត្រូវ) ទាំងនៅចំពោះមុខអ្នកធ្វើច្បាប់និងអ្នកផ្តល់ជំនួយ ។ ការនេះនឹងជួយនៅក្នុងការទាក់ទងជាមួយនិងអ្នកសម្រេចចិត្ត ហើយធ្វើឱ្យការយល់ដឹងទៅលើបញ្ហាកាន់តែមានភាពជ្រាលជ្រៅ ។ ដូច្នេះអ្នកត្រូវធ្វើការសិក្សាដើម្បីកំណត់ថា តើអ្វីទៅដែលធ្វើឱ្យមនុស្សនៅក្នុងសហគមន៍ប៉ះពាល់បញ្ហា និងគំនិតសាធារណជនទូទៅគិតយ៉ាងដូចម្តេចចំពោះបញ្ហានោះ ។ ប្រសិនបើជាអ្នកនយោបាយមើលឃើញថាប្រជាជនភាគច្រើនយល់បែបណានោះ ពួកគេទាំងនោះពិតជាងាយយល់នឹងស្តាប់ដំណោះស្រាយបញ្ហាដែលស្នើឡើង ។

***ផ្តល់ដំណោះស្រាយដែលអាចធ្វើទៅបាន*** : អ្នកសម្រេចចិត្ត និងអាជ្ញាធរតែងតែរកមើលដំណោះស្រាយចំពោះបញ្ហា ។ ពួកគេភាគច្រើនអាចកំណត់រកមើលបញ្ហាដោយខ្លួនគេ តែមិនដឹងជាត្រូវដោះស្រាយយ៉ាងដូចម្តេច ។ អ្នកសម្រេចចិត្តត្រូវការអនុសាសន៍របស់អ្នក ថាតើគេគួរចាត់វិធានការយ៉ាងណា ពីព្រោះគេមិនមានពេលដើម្បីគិតលំអិតទៅលើបញ្ហាស្មុគស្មាញនោះទេ ។ អ្នកត្រូវប្រមូលពតិមានស្តីពីវិធីដោះស្រាយបញ្ហាដូចគ្នានៅក្នុងប្រទេសរបស់អ្នក និងរៀនសូត្រពីបទពិសោធន៍អន្តរជាតិ និងនៅតាមតំបន់ ។

ការនេះរួមមានបទបញ្ញាផ្ទៃក្នុង គោលនយោបាយ ឬជម្រើសនៅក្នុងការដោះស្រាយដែលនាំទៅរកដំណោះស្រាយជោគជ័យនៃបញ្ហាណាមួយ ។ អ្នកសម្រេចចិត្ត និងមនុស្សមានឥទ្ធិពលចូលចិត្តស្តាប់អ្នក ប្រសិនបើអ្នកឧទ្ទេសនាមនូវដំណោះស្រាយដែលពួកគេអាចធ្វើបាន ។ នៅពេលអ្នកប្រមូលបានពតិមាន រួចស្ទង់មតិសាធារណៈនិងបានកំណត់ទៅលើដំណោះស្រាយដែលអាចធ្វើទៅបានហើយ អ្នកត្រូវឱ្យអាជ្ញាធរដឹងពីការមិនពេញចិត្តរបស់មតិសាធារណៈ ហើយនិងឆន្ទៈរបស់អ្នកនៅក្នុងការជួយគេដើម្បីដោះស្រាយបញ្ហា ។

## ជំហានទី ២ ការបង្កើនការយល់ដឹងនិងការព្រួយបារម្ភ

យុទ្ធនាការតស៊ូមតិតាមធម្មតាត្រូវការការគាំទ្រ ឬការចាប់អារម្មណ៍ពីសាធារណជន ឬក្រុមមនុស្សដោយឡែកៗនៅខាងក្រៅ ។ ដូច្នេះអ្នកគួរតែធ្វើសកម្មភាពដែលលើកកម្ពស់ដល់ការយល់ដឹង និងការព្រួយបារម្ភស្តីពីបញ្ហា ។ បច្ចេកទេសធ្វើដូច្នេះរួមមានយុទ្ធនាការអប់រំសិក្ខាសាលា និងយុទ្ធសាស្ត្រដែលធ្វើតាមរយៈប្រព័ន្ធឃោសនា ។

- ***សកម្មភាពអប់រំ*** : ដូចជាសិក្ខាសាលានិងកម្មវិធីចុះដល់ទីកន្លែង ជួយជម្រាបដល់ក្រុមជនដែលងាយរងគ្រោះពីសិទ្ធិរបស់គេ ប្រការដែលសិទ្ធិរបស់គេត្រូវបានទទួលរងការរំលោភ ហើយអ្វីខ្លះទៅដែលជាដំណោះស្រាយនិងធនធានដែលមាន ។ ឧទាហរណ៍ ការអប់រំមានប្រសិទ្ធភាពនៅក្នុងការបង្រៀនសហគមន៍ព្រៃឈើដែលស្របទៅតាមច្បាប់នាឆ្នាំ 1988 ដែលកំណត់ថាគ្មាននរណាម្នាក់មានសិទ្ធិកាប់ដើមឈើដែលអ្នកភូមិមូលដ្ឋានកំពុងយកជ័រឡើយ ។
- ***លិខិតនិងញ្ញត្តិ*** ដែលផ្ញើទៅឱ្យអាជ្ញាធរដែលមានការចុះហត្ថលេខារបស់មនុស្សច្រើននាក់ គឺជាវិធីពីរយ៉ាងសម្រាប់បង្ហាញពីការគាំទ្រ ឬការមិនពេញចិត្តរបស់សាធារណជន ។ ទាំងពីរនេះគឺជាវិធីល្អសម្រាប់ចាប់ផ្តើមយុទ្ធនាការ ពីព្រោះវាធ្វើឱ្យអ្នកដឹកនាំដឹងពីបញ្ហា ហើយឯកសារតែងទទួលបាននូវការគាំទ្រដ៏ទូលំទូលាយ ។

**ការប្រមូលផ្តុំនិងការផ្សព្វផ្សាយពត៌មានដើម្បីពង្រឹងយុទ្ធនាការរបស់អ្នកនិងផ្តល់ដំណឹងដល់អ្នកធ្វើសេចក្តីសម្រេចចិត្តទាំងឡាយ**

- ***ការរៀបចំប្រារព្ធពិធីបុណ្យពិសេសៗ*** ៖ ដូចជាទិវានារីអន្តរជាតិជួយសាធារណជនឱ្យមានការយល់ដឹង ។ បើអ្នកសម្រេចចិត្តរៀបចំពិធីអ្វីមួយ អ្នកត្រូវអញ្ជើញមន្ត្រីថ្នាក់ខ្ពស់ អ្នកដឹកនាំសហគមន៍ ឬអង្គការមិនមែនរដ្ឋាភិបាល និងសមាជិកសាធារណៈឱ្យមកថ្លែងសុន្ទរកថា ដើរដង្ហែរក្បួន និងចូលរួមនៅក្នុងសកម្មភាពដទៃទៀតដែលជួយលើកកម្ពស់ដល់ការយល់ដឹង ។ សកម្មភាពអាចធ្វើច្រើនថ្ងៃនៅពេលមុន និងក្រោយពិធីប្រារព្ធនោះ ដើម្បីប្រមូលបាននូវភាពខ្លាំងនិងការដឹងឮច្រើនរបស់សាធារណជន ។ ការប្រារព្ធបែបនេះមានប្រយោជន៍ពិតប្រាកដទាល់តែសាធារណជនទូទៅមិនមានការយល់ដឹងទៅលើបញ្ហា ឬទាល់តែមានយុទ្ធនាការតស៊ូមតិបន្ទាប់ពីមានការប្រារព្ធបែបនេះ ។ ក្រៅពីនេះអ្នកត្រូវគិតផងដែរពីការកំណត់ពេលវេលា បើសិនយើងធ្វើឡើងខុសពេលវេលានាំឱ្យអ្នកមានដំណើរអវិជ្ជមានទៅវិញ ។ ឧទាហរណ៍ បើមិនមាននរណាម្នាក់មកចូលរួមនៅក្នុងពិធីនោះទេ នោះយុទ្ធនាការរបស់អ្នកនឹងបាត់បង់នូវធម្មានុរូប ។ ចូរធ្វើការស្រាវជ្រាវ ៖ តើពីមុនមកពិធីបែបនេះធ្លាប់ត្រូវបានរៀបចំនៅក្នុងតំបន់របស់អ្នកឬទេ ? តើប្រជាជនមានការយល់ដឹងពីបញ្ហានេះហើយឬនៅ ? តើគេនឹងចូលរួមក្នុងព្រឹត្តិការណ៍របស់អ្នកទេ ? នេះជាសំណួរចាំបាច់ដែលគេត្រូវសួរសម្រាប់ការប្រារព្ធពិធីជាសាធារណៈនានា ។
- ***ប្រព័ន្ធឃោសនា*** គឺជាមធ្យោបាយដែលមានប្រយោជន៍នៅក្នុងការលើកកម្ពស់ការយល់ដឹងជាសាធារណៈ និងដាក់ការគាបសង្កត់ទៅលើអ្នកសម្រេចចិត្ត (សូមមើលផ្នែកខាងក្រោមដែលមានការរៀបរាប់ច្រើនពីការប្រើប្រាស់ប្រព័ន្ធឃោសនា) ។ សេចក្តីប្រកាសផ្សាយពត៌មានតាមវិទ្យុ និងទូរទស្សន៍ គឺជាវិធីបញ្ជូនសាររបស់អ្នកទៅកាន់សារធារណជន ។ វិធីផ្សេងទៀតដែលគេអាចប្រើដើម្បីបញ្ចូលប្រព័ន្ធឃោសនារួមមាន ៖

  *១. អញ្ជើញអ្នកកាសែតឱ្យចុះធ្វើការសិក្សាបញ្ហាដោយផ្ទាល់ ។*

  *២. ថតសុន្ទរកថារបស់មន្ត្រីធំៗហើយចាក់ផ្សាយឱ្យអ្នកភូមិស្តាប់ដើម្បីឱ្យគេបានដឹងពីការសន្យារបស់មន្ត្រីទាំងនោះ ហើយធ្វើឱ្យមន្ត្រីទាំងនោះកាន់តែមានការទទួលខុសត្រូវខ្ពស់ ។*

  *៣. ទូរស័ព្ទអនាមិកទៅកាន់បណ្តាញឃោសនាដោយប្រាប់ពីការរំលោភច្បាប់ដែលអ្នកបានដឹងហើយដែលអ្នកគិតថាប្រព័ន្ធឃោសនានោះមានការចាប់អារម្មណ៍នៅក្នុងការយកពត៌មានបន្ថែមដោយធ្វើការស្រាវជ្រាវដោយខ្លួនគេលើបញ្ហានេះ ។*

## ជំហានទី ៣ សកម្មភាពដែលត្រូវបានរៀបចំ

សកម្មភាពដែលមានការរៀបចំផែនការ និងតាមដានច្បាស់លាស់អាចជំរុញឱ្យបានខ្លាំងក្លាដល់យុទ្ធនាការតស៊ូមតិ ។ សកម្មភាពទាំងនេះអាចដាក់ការគាបសង្កត់ប្រកបដោយប្រសិទ្ធភាពលើអ្នកសម្រេចចិត្ត ឬក្រុមនានាឱ្យកែប្រែគោលនយោបាយ ឬយ៉ាងហោចណាស់ឱ្យគេចូលរួមនៅក្នុងដំណើរការចរចា ។ ខាងក្រោមនេះគឺជាសេចក្តីរៀបរាប់ខ្លីៗនៃសកម្មភាពខ្លះ ដែលមានការចាត់តាំងត្រឹមត្រូវ ៖

- ***ការធ្វើពហិការ*** ៖ ក្រុមនិងសហគមន៍ទាំងឡាយដែលជាជនរងគ្រោះពីគោលនយោបាយច្បាប់ និងទង្វើមិនសមរម្យនានាពីផ្នែកឯកជន ឬអាជ្ញាធរ អាចចូលរួមគ្នាដើម្បីធ្វើ **ពហិការ** (ការមិនព្រមគាំទ្រ) ទៅលើក្រុមហ៊ុន ឬប្រទេសណាមួយរបស់ពួកគេ ។ ពហិការជាអ្វីដែលក្រុមមួយដកការគាំទ្រផ្នែកនយោបាយ ហិរញ្ញវត្ថុ ឬទំនាក់ទំនងសង្គម ហើយបដិសេធការទិញ ឬចូលរួមក្នុងសកម្មភាពណាមួយ ដែលមានប្រយោជន៍ដល់ក្រុមហ៊ុន ឬប្រទេសហើយមានការជុំរុញលើកទឹកចិត្តឱ្យអ្នកដទៃចូលរួមផងដែរ ។ ពហិការដ៏ខ្លាំងគឺជាពហិការដែលមានការអំពាវនាវរកការគាំទ្រពីសំណាក់សាធារណជនលើទង្វើអយុត្តិធម៌ចំពោះបញ្ហាសាធារណៈ ឬសេដ្ឋកិច្ច ហើយការងារនេះទាមទារឱ្យមានការប្រមែប្រមូលការគាំទ្រដើម្បីគាបសង្កត់ ។ ការផ្សព្វផ្សាយការអប់រំដល់ក្រុមរងគ្រោះ និងការព្រួយបារម្ភណ៍ត្រូវតែធ្វើដើម្បីទទួល

ជោគជ័យ និងស្វែងរកចលនាអ្នកចូលរួមឱ្យបានច្រើន ។ ព្រឹត្តិការណ៍ផ្សាយពតិមានការចែកចាយពតិមាន និងការដើរក្បួននានាជាគំរូ សកម្មភាពផ្សព្វផ្សាយឱ្យប្រជាជនដឹងអំពី ទង្វើ ឬគោលនយោបាយច្បាប់ដែលអយុត្តិធម៌នានាទាំងនោះ ។ ពេលខ្លះអាចគំរាមដល់ក្រុមហ៊ុន ឬ ប្រទេស ថាបណ្តាញក្រុមសកម្មជនមានផែនការដើម្បីសម្របសម្រួលឱ្យមានពហិការមួយដែលនឹងបង្កើតឱ្យមានកម្លាំងគ្រប់គ្រាន់ដើម្បីដាក់ការគាបសង្កត់ និងបញ្ចុះបញ្ចូលអ្នកធ្វើខុសឱ្យមានការចរចាគ្នារកដំណោះស្រាយស្តីអំពីទំនាស់ទាំងឡាយណាមួយ ។

- ***បាតុកម្មនិងការដង្ហែក្បួន*** **:** មនុស្សមួយក្រុមធំមកជួបជុំគ្នាដើម្បីទាមទារលើរឿងអ្វីមួយ ។ វាជាហេតុការណ៍មួយល្អសម្រាប់ឱ្យអ្នកយកពតិមានមកថតរូបភាពនិងផ្សព្វផ្សាយ ព្រោះវាធ្វើឱ្យគេមើលឃើញថាអ្នកដែលគាំទ្រជាកម្លាំងមួយដ៏ខ្លាំងដែលអាចគាបសង្កត់អ្នកបង្កើតច្បាប់បាន ។ ***បាតុកម្ម***គឺជាការតវ៉ានៅកន្លែងមួយដែលជាកន្លែងយុទ្ធសាស្ត្រ ឬនៅកន្លែងណាមួយដែលជានិមិត្តរូបដូចជា នៅមុខ រដ្ឋសភា វិមានឯករាជ្យ ឬនៅកន្លែងផ្សេងទៀតនៅតាម បណ្តាខេត្ត ។ ***ការដង្ហែក្បួន*** គឺជាការតវ៉ាដែលមិននៅមួយ កន្លែង ហើយធ្វើដំណើរឆ្លងកាត់កន្លែងជាយុទ្ធសាស្ត្រ នៅទីបំផុតច្រើនតែក្លាយទៅជាបាតុកម្ម ។ ទាំងនេះគឺជាការតវ៉ាជានិមិត្តរូបដើម្បីសម្តែងមតិ និងការសាមគ្គីគ្នារបស់ក្រុមមួយ ឬបណ្តាញមួយទៅលើបញ្ហា ឬព្រឹត្តិការណ៍ណាមួយ ។ការធ្វើដូច្នេះអាចមានប្រសិទ្ធភាពខ្លាំង ប្រសិនបើគេរៀបចំឱ្យបាន ល្អ ។ តែអ្នកត្រូវដឹងថាវាត្រូវការថាមពល និងធនធានច្រើន ហើយបើមានមនុស្សតិចចូលរួមនោះ វាអាចធ្វើឱ្យខូចដល់យុទ្ធនាការតស៊ូមតិ ។ ដើម្បីឱ្យបាតុកម្មឬការដើរហែរក្បួនមានប្រសិទ្ធភាព វិធីល្អៗដែលត្រូវធ្វើការរៀបចំគឺ :

**១.ជម្រាបប្រាប់មនុស្សដែលចង់ចូលរួមឱ្យបានដឹងជាមុនយូរបន្តិច** ការជម្រាបនេះត្រូវមានរបៀបទៀតគឺអ្នកអាចចុះទៅតាមផ្ទះ ឬអាចបើកពិធីអ្វីមួយជាមុនបន្តិចដើម្បីផ្តល់ជាសញ្ញាឬអប់រំពួកគេស្តីពីបញ្ហាទាំងនេះ ។

**២.ភ្ជាប់បណ្តាញសម្រុះជាមួយនិងអង្គការដទៃៗទៀត** ដើម្បីឱ្យក្រុមមនុស្សជាច្រើនដែលមានការចាប់អារម្មណ៍ដឹងពី ព្រឹត្តិការណ៍ អាចជួយនៅក្នុងការរៀបចំព្រមទាំងចូលរួមក្នុងពិធី ។

**៣.ជ្រើសរើសថ្ងៃដែលសមស្រប :** ដូចជាចុងសប្តាហ៍ ឬថ្ងៃសម្រាកដើម្បីបានមនុស្សច្រើននាក់មកចូលរួម ។






ការប្រារព្ធពិធីដើរជាក្បួននៅថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០០២ ដែលបានចូលរួមដោយប្រជាជនកម្ពុជាជាមួយនិងបណ្តាញអ្នកដែលផ្ទុកមេរោគហ៊ីវនិងអ្នកកើតជំងឺអេដស៍ ។ ការដើរជាក្បួនបានទទួលជោគជ័យព្រោះមានការរៀបចំល្អ អនុវត្តដោយក្រុមចាប់អារម្មណ៍ហើយនាំទៅរកចំណងរឹងមាំជាងមុនជាមួយរដ្ឋាភិបាល ។

**៤. ជូនដំណឹងទៅបណ្តាញឃោសនាឱ្យដឹងជាមុនអំពីព្រឹត្តិការណ៍ ហើយធ្វើយ៉ាងណាឱ្យប្រាកដថានឹងមកចូលរួម** យកល្អអ្នកគួរទាក់ទងជាមួយនិងគេឱ្យបានយ៉ាងតិចបីដងក្នុងអំឡុងពេលមួយខែ ។ ខិតខំប្រើវិធីទាក់ទងខុសៗគ្នា ដើម្បីឱ្យគេយល់ច្បាស់ពីអ្វីដែលអ្នកចង់និយាយ ។ឧទាហរណ៍ អ្នកអាចផ្ញើអ៊ីម៉ែលមួយខែមុនរួចទូរស័ព្ទសួរមួយអាទិត្យមុនព្រឹត្តការណ៍ បន្ទាប់មកទៅកាន់ការិយាល័យរបស់គេមួយថ្ងៃមុនព្រឹត្តិការណ៍ ។ ព្រឹត្តិការណ៍នេះនឹងរឹតតែមានប្រសិទ្ធភាពទៀត បើសិនជាត្រូវបានគេចុះផ្សាយក្នុងទំព័រកាសែត ឬ ត្រូវបានគេពិភាក្សានៅតាមវិទ្យុ ។ដូច្នេះត្រូវខំធ្វើយ៉ាងណាឱ្យមានវត្តមានរបស់ប្រព័ន្ធឃោសនានៅទីនោះ ។

**៥. ជ្រើសរើសគោលដៅឱ្យត្រូវ ព្រឹត្តិការណ៍គួររៀបចំឡើងនៅជុំវិញបញ្ហាគ្រឹះមួយ** មិនចាំបាច់ដល់ទៅបញ្ហាជាគោលដៅទាំងមូលនោះឡើយ ។ពង្រាងច្បាប់នៅពេលបច្ចុប្បន្ន ដែលជាសកម្មភាពមួយរបស់រដ្ឋាភិបាលត្រូវបានគេផ្សព្វផ្សាយយ៉ាងខ្លាំងឬករណីមួយនៅក្នុងតុលាការអាចជាគោលដៅមួយដែលអ្នកអាចរៀបចំបាតុកម្មរបស់អ្នកផ្តោតទៅលើនោះ ។ ប្រជាជននឹងមានការចាប់អារម្មណ៍ខ្លាំងលើរឿងជាក់ស្តែងណាមួយ ហើយគេមានការគិតគូរច្បាស់លាស់ល្អពីអ្វីដែលអ្នកកំពុងតែនិយាយនិងអ្វីដែលគេអាចធ្វើបានក្នុងរឿងនោះ ។

**៦. ធ្វើឱ្យព្រឹត្តិការណ៍មានភាពអធិកអធមដោយមានទង់បដា** អាចជាក្រដាសចែកផ្សាយ សុន្ទរកថា ការស្រែក និងញត្តិជាដើម ។

**៧. ការតាមដានបន្ត** អ្នកត្រូវចេះតភ្ជាប់ចលនាតស៊ូមតិពីពេលមុន និងក្រោយព្រឹត្តិការណ៍ ដើម្បីជំរុញបន្ថែមដល់យុទ្ធនាការរបស់អ្នក ។ ត្រូវធ្វើជាបន្តទៀតដោយរៀបចំសន្និសីទកាសែតឬបង្កើតអ្នកគាំទ្រថ្មីៗឱ្យចូលរួមនៅក្នុងយុទ្ធនាការនោះ ។

- ***កូដកម្ម*** កូដកម្មគឺនៅពេលដែលក្រុមកម្មករមិនព្រមនាំគ្នាចូលធ្វើការ ។**កូដកម្ម**ត្រូវបានកម្មករកាត់ដេរធ្វើរួចទៅ ហើយនិងប្រកបដោយប្រសិទ្ធភាពនៅភ្នំពេញ ។ វាជាមធ្យោបាយរួមមួយដើម្បីទទួលបានសម្បទាននៅក្នុងការតវ៉ារួមរបស់កម្មករ ។ កូដកម្មអាចមានជាការដើរក្បួនបាតុកម្មនិងការនាំគ្នាមិនចូលធ្វើការ( កម្មករចូលរោងចក្រចុះវត្តមានតែមិនព្រមធ្វើការ) ឬធ្វើការមិនរហ័ស ។
- ***សកម្មភាពដោយផ្ទាល់*** ការប្រើប្រាស់យុទ្ធសាស្ត្រ**សកម្មភាពដោយផ្ទាល់**មានន័យថា ចូលប្រឡូកនៅក្នុងបញ្ហាយ៉ាងពេញបន្ទុក ហើយមិនខិតខំបញ្ចុះបញ្ចូលអាជ្ញាធរឬបុគ្គលណាមួយទៀតដើម្បីដោះស្រាយនូវរឿងនេះទេ ។ ដោយមិនរង់ចាំឱ្យអាជ្ញាធរចេញការយល់ព្រម ឬក្រុមហ៊ុនធ្វើការផ្លាស់ប្តូរគោលនយោបាយជាផ្លូវការ សហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលធ្វើការនៅក្នុងវិស័យនោះ ធ្វើការស្វែងរកដំណោះស្រាយនោះដោយផ្ទាល់ ។ ដូចដែលធ្លាប់បានបង្ហាញកន្លងមក ក្នុងករណីដែលទាក់ទងនឹងរឿងជលផល សកម្មភាពដោយផ្ទាល់អាចជាយុទ្ធសាស្ត្រតស៊ូមតិយ៉ាងមានប្រសិទ្ធភាព ។ នៅពេលណាដែលគេប្រើវាបានសមស្រប សកម្មភាពដោយផ្ទាល់អាចធ្វើឱ្យគេជ្រួតជ្រាបពីការមិនពេញចិត្ត ឬភាពចាំបាច់ដែលត្រូវឱ្យមានការកែប្រែ ។ គេតែងតែមានការព្រួយបារម្ភថា សកម្មភាពទាំងនេះអាចទៅជាអំពើហិង្សា តែនៅពេលដែលគេអាចគ្រប់គ្រងវាបានត្រឹមត្រូវកុំឱ្យក្លាយទៅជាមានហិង្សា ពេលនោះវាជាការសម្តែងចេញបានខ្លាំងក្លានូវការមិនពេញចិត្ត ហើយបែរជាទាក់ទាញការចាប់អារម្មណ៍ពីសំណាក់ប្រព័ន្ធឃោសនាសាធារណៈ និង

**បញ្ចូលអាជ្ញាធរតាំងពីដំបូង** ៖ អ្នកត្រូវបញ្ចូលអ្នកធ្វើគោលនយោបាយនៅក្នុងយុទ្ធនាការរបស់អ្នក តាំងតែពីពេលចាប់ផ្តើមដំបូង។ ប្រសិនបើគេដឹងពីទិសដៅនៃយុទ្ធនាការរបស់អ្នក ហើយយល់ពីហេតុផលនៅពីក្រោយគោលបំណងរបស់អ្នក នោះគេអាចក្លាយទៅជាអ្នកតស៊ូមតិយ៉ាងប្រសើរ ។ សកម្មភាពទាំងឡាយគួរគ្រោងឡើងដើម្បីដាក់ការគាបសង្កត់ទៅលើពួកគេឱ្យបញ្ចូលអ្នក ឬអង្គការសង្គមស៊ីវិលទៅក្នុងការពិភាក្សាលើបញ្ហា ឬចាប់ផ្តើមដំណើរការដែលចាំបាច់សម្រាប់ដោះស្រាយបញ្ហា។ អ្នកត្រូវដឹងឱ្យច្បាស់ជានិច្ចពីអ្វីដែលអ្នកចង់ឱ្យអាជ្ញាធរធ្វើជាជំហានបន្ត ឧទាហរណ៍ យុទ្ធនាការស្តីពីពលកម្មកុមាររបស់សម្ព័ន្ធដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្សនៅខេត្តសៀមរាប ផ្តើមឡើងដោយសិក្ខាសាលាដែលធ្វើនៅតាមលំដាប់ថ្នាក់ផ្សេងៗមានការចូលរួមពីអាជ្ញាធរខេត្ត ស្រុក មន្ទីរជុំវិញខេត្ត ឪពុកម្តាយនិងកុមារ ។ មន្ត្រីរាជការចូលរួមនៅក្នុងសិក្ខាសាលាជាបន្តបន្ទាប់ចំនួនបីបួនលើក រួចហើយសុំឱ្យចាត់បញ្ជូនតំណាងចំនួនពីរនាក់ពីសិក្ខាសាលាទៅចូលរួមការប្រជុំប្រចាំខែ។ អ្នកចូលរួមនៅក្នុងការប្រជុំប្រចាំខែ(ដោយរួមទាំងមន្ត្រីរបស់មន្ទីរស្ថាប័ននានាផង)បានផ្តួចផ្តើមគំនិតលើសកម្មភាពនៅពេលមានការរាយការណ៍ពីករណីរំលោភលើពលកម្មកុមារ ។ មួយភាគនៃជោគជ័យនេះបានមកដោយសារមានការគាបសង្កត់របស់សមាជិកសហគមន៍នៅមុនពេលមានសិក្ខាសាលា ។

អាជ្ញាធរចំពោះរឿងនេះ ។ ករណីសិក្សាលើផ្នែកជលផលប្រហែលជាឧទាហរណ៍មួយយ៉ាងល្អបំផុតនៃសកម្មភាពដោយផ្ទាល់នៅក្នុងបរិបទប្រទេសកម្ពុជា ៖ សហគមន៍រំាប់រងលើការធានា ការគោរពគោលការណ៍ ឬវិធាននៃច្បាប់ ហើយឈប់នេសាទខុសច្បាប់ដែលបំផ្លាញមុខរបរចិញ្ចឹមជីវភាពរស់នៅរបស់ពួកគេ ។ សកម្មភាពបែបនេះចាំបាច់ត្រូវតែធ្វើនៅពេលដែលអាជ្ញាធរមានការយឺតយ៉ាវក្នុងការឆ្លើយតបទៅនឹងការស្នើសុំឱ្យជួយ ។

## ជំហានទី ៤ សម្របសម្រួលការទំនាក់ទំនង

ការអប់រំនិងការយល់ដឹងរបស់សាធារណជនមានសារៈសំខាន់ តែវាមិនគ្រប់គ្រាន់ទេសម្រាប់ការផ្លាស់ប្តូរគោលនយោបាយ ។ នៅពេលដែលសាធារណជន និងអង្គការដែលមានឥទ្ធិពលមានការយល់ដឹងទៅលើបញ្ហា ហើយកំណត់បាននូវដំណោះស្រាយដែលអាចធ្វើទៅបាន នោះអ្នកបង្កើតគោលនយោបាយប្រហែលជាមានការចាប់អារម្មណ៍ច្រើនលើការចាប់ផ្តើមពិភាក្សាស្តីអំពីបញ្ហា ។ ខាងក្រោមនេះគឺជាបច្ចេកទេសខ្លះៗសម្រាប់យកទៅប្រើនៅក្នុងការពិភាក្សាជាមួយនិងអ្នកសម្រេចចិត្តលើការពិគ្រោះពិភាក្សាសំខាន់ៗ ។

- ***វេទិកាបើកចំហរ ឬ ការពិភាក្សាតទល់គ្នា*** ៖ វេទិកាបើកចំហនិងការពិភាក្សាតទល់គ្នា ធ្វើឱ្យតួអង្គទាំងឡាយដែលមានការពាក់ព័ន្ធនឹងបញ្ហា មកជួបគ្នានៅចំពោះមុខសាធារណជន ។ ការនេះធ្វើឱ្យអ្នកទាំងនោះបានឡើងសម្តែងមតិ និងស្តាប់ការអះអាងនានាដែលជាធម្មតាគេមិនបានជួបប្រទះនិងមិនបានដឹង ។ ត្រូវអញ្ជើញ ឬបញ្ចុះបញ្ចូលអ្នកដឹកនាំនៅនឹងកន្លែងឱ្យចូលរួមនិងឱ្យគេឡើងសម្តែងមតិ។ វេទិកា និងការពិភាក្សាដេញដោលគឺជាវិធីល្អសម្រាប់ធ្វើឱ្យអ្នកបង្កើតគោលនយោបាយមានការទទួលខុសត្រូវចំពោះទង្វើរបស់គេ ហើយនិងធ្វើឱ្យអ្នកភូមិដឹងថាគេមានអំណាចនៅក្នុងការប្រើឥទ្ធិពលទៅលើមេដឹកនាំរបស់គេដែលជាប់ឆ្នោតនោះ ។ ដូច្នេះវេទិកានិងការពិភាក្សាទល់មុខគ្នាបង្កើតបានជាការសន្ទនា។
- ***ទស្សនកិច្ចសិក្សានៅខាងក្រៅ*** ៖ ទស្សនកិច្ចសិក្សាជាធម្មតា គឺធ្វើឡើងនៅថ្នាក់ជាតិ ដោយបញ្ជូនអ្នកធ្វើគោលនយោបាយនិងអ្នកដឹកនាំសហគមន៍ ទៅបរទេស ដើម្បីបង្ហាញពីគំរូនៃការងារដែលអនុវត្តបានល្អ ។ គេអាចធ្វើទស្សនកិច្ចសិក្សានៅក្នុងតំបន់ឬមូលដ្ឋានផងដែរ ។ គេអាចរៀបចំឱ្យមេដឹកនាំសហគមន៍ និង អ្នកនយោបាយនៅក្នុងស្រុកនាំគ្នាទៅមើល ឃុំ ខេត្ត ផ្សេងទៀតដែលនៅទីនោះ គេបាន

ដោះស្រាយបញ្ហាចេញ ឬអ្នកដែលមានការពាក់ព័ន្ធអាចកំពុងតែដំណើរការពិគ្រោះយោបល់យ៉ាងល្អ ។ ទស្សនៈកិច្ចទាំងនេះធ្វើឱ្យអ្នកមានឱកាសនិយាយទៅកាន់អ្នកតាក់តែងគោលនយោបាយហើយផ្តល់ឱ្យអ្នកដែលមានការពាក់ព័ន្ធនូវឱកាស ដើម្បីបើកការពិភាក្សាជាមួយគ្នាជាលើកដំបូង ។ ការងាររបស់អ្នកក្នុងនាមជាអ្នកធ្វើការតស៊ូមតិជានិច្ចកាល គួរតែលើកទឹកចិត្តឱ្យមានការប្រាស្រ័យទាក់ទងគ្នាដោយផ្ទាល់រវាងអ្នកតាក់តែងគោលនយោបាយ និងសហគមន៍ដែលមានការពាក់ព័ន្ធដែលដឹងច្បាស់ពីរឿងរ៉ាវរបស់គេច្រើនជាងអ្នកនៅខាងក្រៅ ។

- ***ដំណើរការពិគ្រោះយោបល់*** **:** ដំណើរការពិគ្រោះយោបល់គឺជាទម្រង់នៃការនិយាយទាក់ទងគ្នាដែលមានលក្ខណៈស៊ីជម្រៅជាមួយនិងអ្នកធ្វើគោលនយោបាយ ។ តំណាងរបស់សហគមន៍ អង្គការមិនមែនរដ្ឋាភិបាល និងសមាជិកដទៃទៀតនៃសង្គមស៊ីវិល អាចទទួលការអញ្ជើញពីអាជ្ញាធរ ដើម្បីផ្តល់អនុសាសន៍ទៅលើពង្រាងគោលនយោបាយនិងច្បាប់ ។ ឧទាហរណ៍ តំណាងរបស់សហគមន៍នេសាទត្រូវបានគេបញ្ចូលទៅក្នុងសិក្ខាសាលាថ្នាក់ជាតិ ដើម្បីផ្តល់ប្រតិកម្មឆ្លើយតបដល់នាយកដ្ឋានជលផល ដោយអនុញ្ញាតិឱ្យពួកគេផ្តល់អនុសាសន៍ទាក់ទងនឹងច្បាប់នេះ ។ ដំណើរការពិគ្រោះយោបល់ ជាធម្មតាកើតមានដោយសារមានការចែងនៅក្នុងកិច្ចព្រមព្រៀងផ្តល់ជំនួយទ្វេភាគី ឬពហុភាគីជាមួយនិងអ្នកផ្តល់ជំនួយ ពីព្រោះមានការទទូចនិងការគាបសង្កត់ពីអង្គការមិនមែនរដ្ឋាភិបាល ឬសមាគម ។ ក្រសួងខ្លះឥឡូវកំពុងយល់ដោយខ្លួនគេពីសារៈសំខាន់នៃដំណើរការពិគ្រោះយោបល់ដែលជាជោគជ័យមួយ ។

ជាទូទៅដំណោះស្រាយប្រកបដោយស្ថេរភាពទាំងឡាយត្រូវមានការទទួលស្គាល់ដោយតួអង្គដែលជាអ្នកពាក់ព័ន្ធ ហើយនិងប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន ដោយមិនពឹងផ្អែកទៅលើ សកម្មភាពឯកកោណាមួយដើម្បីដោះស្រាយនូវបញ្ហារួមនោះទេ ។

ដំណោះស្រាយសំខាន់បំផុតប្រកបដោយស្ថេរភាពត្រូវតែមានការត្រួតពិនិត្យ ឬចូលរួមពីសហគមន៍ដែលទទួលនូវផល ប៉ះពាល់ពីបញ្ហានោះផង ។

- ***ការបញ្ចុះបញ្ចូល*** **:** ការបញ្ចុះបញ្ចូលគឺជាការទៅទាក់ទងដោយផ្ទាល់ជាមួយមន្ត្រីអាជ្ញាធរ ឬរដ្ឋាភិបាល ដើម្បីបញ្ចុះបញ្ចូលឱ្យពួកគេទទួលធ្វើជាតំណាងលើការព្រួយបារម្ភរបស់អ្នកនៅក្នុងរដ្ឋាភិបាល ។ អ្នកបញ្ចុះបញ្ចូលត្រូវតែជាអ្នកដែលមានឋានៈ ឬភាពស្របច្បាប់ដើម្បីអាចចូលដល់អ្នកធ្វើច្បាប់ ។ ដូច្នេះការបញ្ចុះបញ្ចូលអាចមានភាពសមស្របសម្រាប់ដំណាក់កាលក្រោយៗនៅក្នុងយុទ្ធនាការ ក្រោយពីបានប្រមូលកំលាំងធ្វើឱ្យគេមានការយល់ដឹង និងបណ្តាញត្រូវបានចងក្រងរួច ។ ការជួយជ្រោមជ្រែងជួយជាឯកជនរបស់មន្ត្រីណាម្នាក់ មិនមែនមានន័យថាជាការគាំទ្ររបស់គេជាសាធារណៈនោះឡើយ ។ ការភ័យខ្លាចពីការតបតរបស់អ្នកនយោបាយដែលមានអំណាចនៅក្នុងជួររដ្ឋាភិបាលជារឿយៗដាក់កម្រិតទៅលើអ្វីដែលមន្ត្រីទាំងនោះចង់ធ្វើជាចំហ ។ ការបញ្ចុះបញ្ចូលស្ថានទូតបរទេស ទីភ្នាក់ងារ ទ្វេឬពហុភាគី អង្គការមិនមែនរដ្ឋាភិបាល ដែលជាមិត្ត ឬបណ្តាញអង្គការក្នុងតំបន់ ឬសូម្បីតែអ្នកកាន់អំណាច នៅក្នុងបណ្តាញរបស់អ្នកក៏អាចមានប្រសិទ្ធភាពដែរ ។

**ការតភ្ជាប់ជាមួយសហគមន៍ :** ក្រុមដែលសំខាន់ជាងគេត្រូវចូលរួមនៅក្នុងយុទ្ធនាការរបស់អ្នកគឺសហគមន៍ដែលទទួលរងនូវការប៉ះពាល់ ។ គេត្រូវការដឹងពីគោលបំណងរបស់អ្នកហើយគាំទ្រគោលបំណងទាំងនោះ។ នៅក្នុងករណីខ្លះ ត្រូវធ្វើយ៉ាងណាដើម្បីឱ្យគេមានការជឿជាក់ថា ចាំបាច់ត្រូវតែធ្វើយុទ្ធនាការតស៊ូមតិ។ អ្នកប្រឆាំងនឹងអំពើហិង្សានៅក្នុងគ្រួសារបានជួបនឹងបញ្ហានេះជាមួយនិងនារីដែលប្រកាន់តាមប្រពៃណី ហើយបណ្តោយឱ្យប្តីរបស់ខ្លួនរំលោភធ្វើបាបខ្លួន ។ នៅក្នុងករណីខ្លះទៀតអ្នកអាចនឹងធ្វើជាតំណាងឱ្យសហគមន៍ ហើយអ្នកចាំបាច់ត្រូវធ្វើឱ្យគេចូលរួមនៅក្នុងដំណើរការនេះ ហើយអប់រំគេលើបញ្ហាយ៉ាងទូលំទូលាយដើម្បីឱ្យគេអាចឈានទៅធ្វើការតស៊ូមតិបានដោយខ្លួនគេនៅពេលអនាគត។

- ***បង្កើតការតភ្ជាប់នានាជាមួយនិងសហគមន៍ :*** មុនពេលចាប់ផ្តើមយុទ្ធនាការតស៊ូមតិ អ្នកត្រូវវាយតំលៃមើលថាតើសហគមន៍ត្រូវការអ្វី ។ជួបសម្ភាសន៍ ចូលរួមនៅក្នុងការប្រជុំរបស់គេ ហើយស្តាប់ការបកស្រាយពីកង្វល់របស់គេ ។ តើយុទ្ធនាការរបស់អ្នកពិតជាឆ្លុះបញ្ចាំងពីសេចក្តីត្រូវការរបស់គេដែរឬទេ ?

- ***ចូលរួមជាមួយនិងសហគមន៍តាំងពីពេលដំបូងនៃយុទ្ធនាការរបស់អ្នក :*** នៅពេលដែលអ្នកកំណត់បានថាអ្វីទៅជាបញ្ហាគន្លឹះនោះ អ្នកត្រូវធ្វើយ៉ាងណាឱ្យមានការចូលរួមរបស់សហគមន៍នៅក្នុងការរៀបចំយុទ្ធសាស្ត្រ ។ប្រាប់គេពីបំណងរបស់អ្នកហើយសុំមតិឆ្លើយតបរបស់គេមកវិញ។ វេទិកា ឬការប្រជុំជាមួយនិងសហគមន៍ ជាមួយនិងអ្នកដឹកនាំនៅនឹងមូលដ្ឋាន គឺជាវិធីល្អសម្រាប់កំណត់ពីការឆ្លើយតបរបស់គេ ។ ត្រូវកំណត់ទិសដៅដែលបំពេញសេចក្តីត្រូវការច្បាស់លាស់របស់ប្រជាជន ។ ឧទាហរណ៍ល្អមួយនៃការធ្វើដូច្នេះ គឺករណីសិក្សាមួយស្តីពីអ្នកក្រនៅតាមទីក្រុង នៅពេលដែលប្រជាជនប្រាប់ទៅអង្គការដែលធ្វើការនៅតាមទីក្រុងថា សហគមន៍ដែលរស់នៅតាមសំណង់អណាធិបតេយ្យចង់ទៅរស់នៅកន្លែងថ្មីជិតក្រុង ដូច្នេះអង្គការទាំងនោះរៀបចំយុទ្ធសាស្ត្រតស៊ូមតិរបស់គេនៅជុំវិញការទាមទារនោះ ។

- ***បញ្ចូលសមាជិកសហគមន៍នៅក្នុងតំណែងដឹកនាំសំខាន់ៗ*** គោលបំណងនៃយុទ្ធនាការតស៊ូមតិ គឺផ្តល់សិទ្ធិអំណាចទៅឱ្យមនុស្សដែលអ្នកខិតខំជួយ ។ នៅក្នុងប្រទេសមួយដូចជាប្រទេសកម្ពុជាដែលប្រជាជនភាគច្រើនមិនសូវមានការយល់ដឹង ឬមិនសូវមានជំនាញដូចបុគ្គលិករបស់អ្នក ដូចនេះការចូលរួមរបស់អ្នកជាមួយនិងគេ ប្រហែលជាឱកាសមួយល្អបំផុតនៅក្នុងការបង្រៀនគេឱ្យចេះធ្វើការតស៊ូមតិដោយខ្លួនឯង ។វិធីស្រួលជាងគេនៅក្នុងកិច្ចការនេះគឺ ឱ្យសមាជិកឬអ្នកដឹកនាំសហគមន៍បានរៀនសូត្រនិងគាំទ្រពីបុគ្គលិករបស់អ្នក ហើយដឹកនាំផ្នែកខ្លះនៃយុទ្ធនាការរបស់អ្នក ។ ភាពជាអ្នកដឹកនាំ និងការឱ្យមានការសិក្សាដោយអនុវត្ត ជាឱកាសអប់រំល្អបំផុតដែលអ្នកអាចផ្តល់ជូនពួកគេ ។

- ***រក្សាឱ្យមានជាចំហនូវបណ្តាញទាក់ទង :*** សមាជិកសហគមន៍គួរតែដឹងពីពត៌មានសម្រាប់ហៅទាក់ទងជាមួយនិងអ្នកគ្រប់ពេល ការធ្វើដូច្នេះធ្វើឱ្យអ្នកដឹង បានជំរាបដំណឹងបើសិនជាមានបញ្ហាអ្វីមួយកើតឡើង ។ ត្រូវធ្វើឱ្យគេហ៊ានទាក់ទងជាមួយនិងបុគ្គលិករបស់អ្នក ហើយមានការទាក់ទងយ៉ាងស្និទ្ធស្នាលជាមួយបុគ្គលិកខ្លះ ឬទាំងអស់ ។ការចូលរួមដោយផ្ទាល់ជាមួយនិងសហគមន៍នឹងជួយផ្តល់ភាពស្របច្បាប់ដល់អ្នកក្នុងការធ្វើយុទ្ធនាការប្រកបដោយប្រសិទ្ធភាព ។

- ***បញ្ចូលសហគមន៍នៅក្នុងការអនុវត្តន៍ :*** នៅពេលគោលបំណងនិងផែនការការងារត្រូវបានដាក់ចេញរួចហើយការចូលរួមរបស់សហគមន៍មិនមែនចប់ត្រឹមប៉ុណ្ណឹងទេ ។ ត្រូវអញ្ជើញគេឱ្យមកចូលរួមនៅក្នុងបាតុកម្ម សកម្មភាពបញ្ចុះបញ្ចូល និងការប្រជុំនានា ។ ការនាំអ្នកតាក់តែងច្បាប់ឱ្យចុះ

ទស្សនកិច្ចក្នុង និងក្រៅដើម្បីមើលសហគមន៍ក៏ជាយុទ្ធសាស្ត្រមួយទៀតផងដែរ សហគមន៍នឹងមានលទ្ធភាពភ្ជាប់ខ្លួនគេក្នុងដំណើរការតស៊ូមតិ ហើយអ្នកតាក់តែងច្បាប់នឹងបានដឹងដោយផ្ទាល់ជាបឋមពីបញ្ហាដែលអ្នកខិតខំ ដោះស្រាយ ។

## ជំហានទី ៥ ការភ្ជាប់បណ្តាញ

**បណ្តាញ** បង្កើតឱ្យមានជាការគាំទ្រទូលំទូលាយសម្រាប់បញ្ហាមួយ ហើយផ្តល់ភាពស្របច្បាប់ដល់យុទ្ធនាការតស៊ូមតិ ។ ដោយធ្វើការរួមគ្នាតាមរយៈបណ្តាញអង្គការមិនមែនរដ្ឋាភិបាល ទទួលបាននូវភាពស្របច្បាប់កាន់តែច្រើនជាមួយនិងមនុស្សដែលមានឥទ្ធិពលជាគោលដៅរបស់អ្នក ។ អត្ថប្រយោជន៍នៃការសហការគ្នាកន្លងមក នាំឱ្យគេបានទៅបង្កើត គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC) គឺ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ហើយនិង Medicam ។ ការសម្របសម្រួលការងារគ្នានៃបណ្តាញនៅក្នុងវិស័យមួយ គឺជាការបង្ហាញឱ្យឃើញពីភាពខ្លាំងរបស់គេ ។ អ្នកត្រូវមើលថា តើបណ្តាញមានហើយឬនៅក្នុងវិស័យរបស់អ្នក ហើយត្រូវគិតគូរបញ្ចូលបណ្តាញនេះឬសមាជិករបស់បណ្តាញនេះ ទៅក្នុងយុទ្ធនាការ របស់អ្នក យុទ្ធនាការផ្នែកជលផលបង្ហាញពីសារៈសំខាន់ នៃបណ្តាញល្អ ។ អ្នកតស៊ូមតិបង្កើតឡើងនូវសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (FACT) ដែលបើកឱ្យមានការសម្របសម្រួលការងារល្អទាំងនៅថ្នាក់មូលដ្ឋាន និងនៅថ្នាក់ជាតិ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើការចូលរួមរបស់សហគមន៍មូលដ្ឋាន ។ ជោគជ័យមួយផ្នែកធំនៃយុទ្ធនាការផ្នែកជលផលនៅក្នុងការគាបសង្កត់រដ្ឋាភិបាល គឺបានមកពីការប្រើប្រាស់បណ្តាញដែលល្អ ។



សិក្ខាសាលាផ្សព្វផ្សាយបង្កើនការយល់ដឹងរបស់សហគមន៍ និងអ្នកពាក់ព័ន្ធអំពីសហគមន៍ព្រៃឈើវត្តវល្លិយាវដោយមានបញ្ហានៃការប្រើប្រាស់ដីធ្លីមិនសមរម្យពីសំណាក់ផ្នែកឯកជន។ សកម្មភាពនេះបានបង្ហាញនូវគំរូល្អលើការបង្កើតបណ្តាញល្អរវាងអង្គការ និងអង្គការ និងរវាងអង្គការជាមួយនិងអាជ្ញាធរតំបន់ ។ ថ្ងៃទី ៧-៨ មករា ឆ្នាំ ២០០០ ។

# ពិនិត្យមើលឡើងវិញ និង ការកែប្រែយុទ្ធនាការ

## ត្រួតពិនិត្យភាពរឹងមាំ និងភាពទន់ខ្សោយរបស់អ្នក

ទោះបីថាការវាយតំលៃលើឥទ្ធិពលប៉ះពាល់នៃសកម្មភាពធ្វើយុទ្ធនាការមិនមែនជាការស្រួលក្ដី តែគេអាចពិនិត្យមើលឡើងវិញលើយុទ្ធនាការតាមពេលកំណត់ទៀងទាត់ ដើម្បីវាយតម្លៃមើលថា តើធនធានដែលយកទៅប្រើប្រាស់បានល្អយ៉ាងណា តើបានសម្រេចអ្វីខ្លះ (វិជ្ជមាន និងអវិជ្ជមាន) ហើយដកស្រង់មេរៀនទុកសម្រាប់អនាគត ។ អ្នកត្រូវធ្វើកាលវិភាគសម្រាប់ពិនិត្យមើលឡើងវិញតាមរបៀបត្រឹមត្រូវលើយុទ្ធនាការរបស់អ្នក ។ អ្នកត្រូវរៀបចំប្រតិទិនសម្រាប់ពិនិត្យមើលឡើងវិញលើភាពត្រឹមត្រូវនៃយុទ្ធនាការរបស់អ្នក ។

ការពិនិត្យមើលឡើងវិញនេះគួរមានបញ្ចូលនូវការប៉ាន់ប្រមាណរបស់អ្នកដែលមានការពាក់ព័ន្ធច្រើនគ្នាបំផុតដោយរួមបញ្ចូលទាំងសហគមន៍ដែលរងនូវការប៉ះពាល់ដើម្បីកំណត់ពីទម្រង់មួយច្បាស់លាស់ និងត្រឹមត្រូវបំផុតនៃយុទ្ធនាការ ។ នេះជាផ្នែកសំខាន់ចាំបាច់នៃយុទ្ធនាការដែលមានជោគជ័យ ពីព្រោះវាធ្វើឱ្យគេគិតបានល្អិតល្អន់ពីដំណើរការទៅមុខដែលគេសម្រេចបានហើយនិងកំហុសទាំងឡាយនៅក្នុងវិធីសាស្ត្ររបស់គេ ។ អ្នកត្រូវគិតពីអ្វីដែលអង្គការរបស់អ្នកត្រូវការដឹងពីយុទ្ធនាការដើម្បីធ្វើឱ្យវាមានប្រសិទ្ធភាព ។ ចូរចាំថាវាមិនជាថ្វីទេបើការពិនិត្យឡើងវិញទៅឃើញលទ្ធផលអវិជ្ជមាននោះ ព្រោះវានឹងជួយអ្នកឱ្យធ្វើនូវជំហានក្រោយទៀតបានល្អ ។ ខាងក្រោមនេះគឺជាបញ្ជីនៃសំណួរដែលអ្នកត្រូវការសួរនៅពេលពិនិត្យមើលឡើងវិញលើយុទ្ធនាការរបស់អ្នក ។

ការពិនិត្យមើលឡើងវិញលើយុទ្ធនាការរបស់អ្នកធ្វើឱ្យអ្នកដឹងពីចំណុចខ្លាំងនិងចំណុចខ្សោយរបស់វា ។ អ្នកគួរប្រើប្រាស់មេរៀនដែលត្រូវបានដកស្រង់ចេញពីការពិនិត្យមើលឡើងវិញ ដើម្បីធ្វើការកែសម្រួលវិធី និងយុទ្ធសាស្ត្ររបស់អ្នកដើម្បីឈានទៅធ្វើការតស៊ូមតិឱ្យកាន់តែមានប្រសិទ្ធភាព ។ ឧទាហរណ៍ ប្រសិនបើជាការពិនិត្យឡើងវិញលើយុទ្ធនាការរបស់អ្នកបង្ហាញថា វិធីរបស់អ្នកទទួលបានជោគជ័យក្នុងការចាប់ផ្ដើមកិច្ចពិភាក្សាជាមួយនិងមន្ត្រីនៅតាមមូលដ្ឋាន តែមិនបានបញ្ចូលឱ្យមានការចូលរួមរបស់សហគមន៍ដែលទទួលរងនូវការប៉ះពាល់ទេ នោះអ្នកគួរតែបង្កើតយុទ្ធសាស្ត្រថ្មីដើម្បីបញ្ចូលឱ្យមានការចូលរួមរបស់គេ ។ យុទ្ធនាការនីមួយៗមានសំណួរផ្សេងៗដោយឡែកៗពីគ្នាដែលអ្នកតស៊ូមតិត្រូវសួរ :

### បញ្ហាសំខាន់ៗសម្រាប់ពិចារណាដើម្បីសម្រេចនូវយុទ្ធនាការ

**ពិនិត្យមើលដំណើរជឿនលឿនទៅមុខរបស់អ្នក** នៅក្នុងការសម្រេចជោគជ័យលើគោលបំណងទាំងឡាយរបស់អ្នកដែលបានកំណត់មកជាមុន ។

**ប្រមាណលើឥទ្ធិពល** ទាំងវិជ្ជមាន និងអវិជ្ជមាននៃ យុទ្ធសាស្ត្រឬសកម្មភាពតស៊ូមតិនីមួយៗដែលអ្នកបានអនុវត្តកន្លងមក ។

**ពិនិត្យមើលថាតើយុទ្ធវិធី (គាក់ទិច) របស់អ្នកបានឈានទៅដល់មនុស្សមានឥទ្ធិពលដែលជាគោលដៅទទួលបានជោគជ័យដែរឬទេ?**

**វិភាគលើការឆ្លើយតប**ទាំងវិជ្ជមាននិងអវិជ្ជមានរបស់មនុស្សជាគោលដៅរបស់អ្នក ។

**វិភាគទៅលើប្រសិទ្ធភាពនៃការប្រើប្រាស់ប្រព័ន្ធឃោសនា វិភាគពីបច្ចេកទេសរបស់អ្នកលើការភ្ជាប់បណ្ដាញ** ដើម្បីពិនិត្យមើលថា តើអ្នកពិតជាបានធ្វើការបានល្អប្រសើរជាមួយនិងដៃគូទៅអនាគតរបស់អ្នកដែរឬទេ ?

**ភាពជាអ្នកដឹកនាំការទទួលខុសត្រូវនានាដែលបានចែងចែក ។**

# ការទំនាក់ទំនងជាមួយតួអង្គសំខាន់ៗ : រដ្ឋាភិបាល និង ប្រព័ន្ធឃោសនា

## ធ្វើឱ្យមានឥទ្ធិពលលើដំណើរការតាក់តែងច្បាប់

អវត្តមាននៃច្បាប់ និងវត្តមានច្បាប់ដែលសរសេរឡើងមិនបានល្អនិងហួសសម័យ បង្កើតឱ្យមានប្រព័ន្ធយុត្តិធម៌តាមអំពើចិត្តហើយបណ្តាលឱ្យមានបញ្ហាផ្នែក នយោបាយ សេដ្ឋកិច្ច និងសង្គម ។ ការតស៊ូមតិស្ថិតនៅជាមួយនឹងផ្នែកនីតិបញ្ញត្តិ គឺជាផ្នែកសំខាន់មួយនៃយុទ្ធនាការប្រកបដោយជោគជ័យ តែកិច្ចការនេះច្រើនតែគេមិនសូវចាប់អារម្មណ៍ទៅវិញ ។ ការអធិប្បាយលំអិតស្តីពីដំណើរប្រព្រឹត្តិទៅនៃផ្នែកនីតិបញ្ញត្តិនៅក្នុងប្រទេសកម្ពុជា គឺមាននៅក្នុងផ្នែកខាងក្រោយនៃសៀវភៅនេះ ។ ខាងក្រោមនេះគឺសេចក្តីរៀបរាប់ត្រួសៗស្តីពីវិធីដែលអង្គការសង្គមស៊ីវិលអាចធ្វើការជាមួយនិងផ្នែកនីតិបញ្ញត្តិ ។

- ***ដំណើរការផ្នែកនីតិបញ្ញត្តិ*** : សមាជិកទាំងអស់របស់ព្រឹទ្ធសភា និងសភាជាតិ ហើយនិងនាយករដ្ឋមន្ត្រី មានសិទ្ធិផ្តួចផ្តើមច្បាប់ យោងទៅតាមមាត្រាទី៩១នៃរដ្ឋ-ធម្មនុញ្ញកម្ពុជា ។ មន្ត្រីថ្នាក់ក្រសួងក៏អាចធ្វើសេចក្តីព្រាងច្បាប់ទៅឱ្យទីស្តីការគណៈរដ្ឋមន្ត្រី ដែលនាយករដ្ឋមន្ត្រីជាអ្នកផ្ញើច្បាប់នោះជូនទៅឱ្យសភាជាតិ ។ ច្បាប់ដែលស្នើនោះត្រូវតែសរសេរឡើងដោយមានកំណត់បែងចែកជាមាត្រាហើយមានភ្ជាប់មកជាមួយនូវសេចក្តីថ្លែងពីមូលហេតុចាំបាច់ត្រូវមានច្បាប់នោះ ។ សេចក្តីស្នើច្បាប់នោះបន្ទាប់មកត្រូវផ្ញើទៅឱ្យគណៈកម្មការមួយនៃគណៈកម្មការទាំង ៩ ដើម្បីសុំការពិនិត្យ ។ គណៈកម្មការនោះរួមមាន គណៈកម្មការកិច្ចការផ្ទៃក្នុងអង្កេតស្រាវជ្រាវ ហើយនិងក្រុមប្រឹក្សាភិបាលជាតិប្រឆាំងនិងអំពើពុករលួយ ។ ក្រោយពីពិចារណាហើយគណៈកម្មការនោះអាចបញ្ជូនសេចក្តីស្នើទៅសភាពេញអង្គដោយភ្ជាប់អនុសាសន៍ដែលថា សុំឱ្យសភាពិចារណា ឬមិនពិចារណា យោងតាមសភាពបន្ទាន់នៃតម្រូវការ ។

> **ការអនុវត្តជាអន្តរជាតិល្អបំផុត គឺសំដៅលើសកម្មភាព ឬច្បាប់ដែលធ្លាប់មានពីមុនមក ។ ទាំងនេះគឺជាយុទ្ធសាស្ត្រ និងច្បាប់ជាច្រើនដែលប្រទេសមួយចំនួនព្យាយាមអនុវត្តតាមដោយសារច្បាប់ឬយុទ្ធសាស្ត្រទាំងនេះត្រូវបានគេអនុវត្តប្រកបដោយប្រសិទ្ធភាព។ ឧទាហរណ៍ច្បាប់ឆ្នាំ១៩៩៨ស្តីអំពីជំងឺអេដស៍របស់ហ្វីលីពីនគឺជាមូលដ្ឋានសម្រាប់កម្ពុជា ។**

- ***តម្លាភាព*** : ជាមួយនិងករណីលើកលែងដែលមានមិនច្រើននោះ ការធ្វើច្បាប់គឺជាដំណើរការមួយដែលត្រូវប្រព្រឹត្តទៅជាសាធារណៈ ។ មាត្រាទី ៨៨ នៃរដ្ឋធម្មនុញ្ញធានាថា សម័យប្រជុំសភាទាំងអស់ត្រូវបើកចំហជាសាធារណៈ លើកលែងតែមានការស្នើសុំជាពិសេសពីប្រមុខរដ្ឋ ព្រះមហាក្សត្រ នាយករដ្ឋមន្ត្រី ឬសមាជិកចំនួនមួយភាគដប់ ។ តែតាមពិតទៅសម័យប្រជុំសភាភាគច្រើននៅកម្ពុជា គឺបិទមិនបង្ហាញ

ជាសាធារណៈទេ ។ ការខ្វះការចូលរួមរបស់សាធារណជននៅពេលនេះមានន័យថា អ្នកត្រូវតែចាប់ផ្តើមការតស៊ូមតិនៅមុនពេលដែលច្បាប់មួយត្រូវបានគេពិភាក្សាដេញដោល បើអ្នកចង់ឱ្យគេធ្វើច្បាប់នោះនៅក្នុងលក្ខណៈបែបណាមួយ ។

- ***យុទ្ធសាស្ត្រតស៊ូមតិ :*** យុទ្ធសាស្ត្រដែលគេប្រើដើម្បីធ្វើឱ្យឥទ្ធិពលទៅលើដំណើរការនីតិបញ្ញត្តិ គឺមានបរិយាយដូចនៅក្នុងសៀវភៅណែនាំខាងក្រោមនេះ

**១. ការស្រាវជ្រាវនិងកត់ត្រាពត៌មាន** : ការស្រាវជ្រាវនិងការចងក្រងឯកសារ ផ្តល់នូវហេតុផលសំខាន់ៗទាំងសម្រាប់អ្នកតស៊ូមតិនិងអ្នកធ្វើច្បាប់ ។ នៅក្នុងករណីខ្លះអ្នកធ្វើច្បាប់អាចមិនដឹងពីបញ្ហាណាមួយ ។ ជាញឹកញាប់គេមិនមានធនធានដើម្បីធ្វើការសិក្សា ដើម្បីក្តាប់ឱ្យបានណែនចំពោះរឿងនោះ។

**២. ការបង្កើតឡើងនូវទំនាក់ទំនងក្នុងផ្លូវឯកជនផ្ទាល់** ជាមួយនិងអ្នកសម្រេចចិត្ត ហើយធ្វើឱ្យអ្នកសម្រេចចិត្តទាំងនោះមានចំណែកនៅក្នុងយុទ្ធនាការក៏ជាការសំខាន់មួយដែរ ។ ការភ្ជាប់ខ្លួនជាមួយអ្នកសម្រេចចិត្តទាំងឡាយមានន័យថា ជួយអ្នកសម្រេចចិត្តទាំងនោះឱ្យយល់បានពីបញ្ហាចែករំលែកការយល់ដឹងនោះទៅឱ្យគេ ធ្វើអោយគេមានជំនឿថាមានភារៈកិច្ច និង អំណាចសរសេរ ឬប្រើឥទ្ធិពលទៅលើផ្នែកនីតិបញ្ញត្តិ ហើយនិងផ្តល់ដល់គេនូវពត៌មានចាំបាច់សម្រាប់យកទៅបញ្ជាក់បន្ថែមលើហេតុផលលើកឡើងរបស់គេ ។ អ្នកតស៊ូមតិត្រូវការផ្តល់ឱកាសដល់គេ ដើម្បីឱ្យឃើញបញ្ហាដោយផ្ទាល់តាមរយៈការចុះទស្សនៈកិច្ច ឬធ្វើការទាក់ទងជាមួយនិងសហគមន៍ដែលទទួលរងការប៉ះពាល់ ។

**៣. ការធ្វើសេចក្តីព្រាងច្បាប់** ដើម្បីដាក់ស្នើទៅក្រសួង ។ ច្បាប់ត្រូវផ្អែកលើមូលដ្ឋាននៃការស្រាវជ្រាវលើទម្លាប់អនុវត្តន៍ជា អន្តរជាតិដែលល្អជាងគេ ជារួមមានទាំងអនុសាសន៍របស់អង្គការមិនមែនរដ្ឋាភិបាលដែលមានការពាក់ព័ន្ធធ្វើទៅតាមបរិបទនៅក្នុងប្រទេសកម្ពុជាពិនិត្យមើលឡើងវិញដោយ អ្នកឯកទេសខាងច្បាប់និងផ្តល់ជូនអ្នកពាក់ព័ន្ធដើម្បីធ្វើការ វាយតំលៃទៅលើសេចក្តីព្រាងនោះ ។ ទោះបីជាទង្វើនេះទាមទារ ការខិតខ និងការធ្វើផែនការ ច្រើនជាងការបញ្ចុះបញ្ចូល (Lobby) លើច្បាប់ដែលមានស្រាប់ក្តីតែជាញឹកញាប់ការធ្វើ សេចក្តីព្រាងច្បាប់គឺជាវិធីតែមួយគត់ដើម្បីធ្វើឱ្យដំណើរការច្បាប់ ផ្តើមឡើងនៅក្នុងទិសដៅដើម្បីស្នើឡើងនូវច្បាប់ថ្មីៗទាំង នោះទៅកាន់សភា ។

**៤. ការបញ្ចុះបញ្ចូល** យុទ្ធសាស្ត្រមួយទៀតដែលមានប្រសិទ្ធភាពគឺ បញ្ចុះបញ្ចូលក្រសួងដែលទទួលបន្ទុកលើច្បាប់ណាមួយ ។ ការដែលគេអាចផ្តល់អនុសាសន៍ដល់សេចក្តីព្រាងច្បាប់មួយនៅថ្នាក់ក្រសួង គឺវាមានសារៈសំខាន់ណាស់សម្រាប់ធ្វើ ឱ្យច្បាប់ដែលគេអនុម័តទៅនោះពិតជាឆ្លុះបញ្ចាំង ពីកង្វល់របស់សាធារណជន ។ ការផ្តល់ឱ្យក្រសួងនូវពត៌មានចាំបាច់ផ្នែកបច្ចេកទេសហើយនិងធ្វើឱ្យក្រសួងមានឈ្មោះល្អចំពោះការងារនោះ អាចជួយច្រើននៅក្នុងការធ្វើឱ្យសេចក្តីព្រាងច្បាប់ ដែលល្អមួយក្លាយទៅជាច្បាប់ពិតប្រាកដ ។ ការជួយក្រសួង នៅក្នុងការធ្វើសេចក្តីព្រាងច្បាប់ក៏បានជួយផងដែរចំពោះអង្គការរបស់អ្នក ដើម្បីឱ្យមានបណ្តាញទាក់ទងជាមួយនិងរដ្ឋាភិបាល ប៉ុន្តែត្រូវមានការប្រយ័ត្នថា តួនាទីរបស់អ្នក គឺគ្រាន់តែជាអ្នកប្រឹក្សាផ្តល់យោបល់តែប៉ុណ្ណោះ ហើយកិច្ចការនេះមិនត្រូវឱ្យប៉ះពាល់ដល់ឯករាជ្យភាពរបស់អង្គការអ្នកទេ ។




នាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងសុន្ទរកថាក្នុងឱកាសសន្និសីទជាតិលើកទីពីរស្តីអំពីជំងឺអេដស៍នៅកម្ពុជា ។ បណ្តាញអ្នកមានមេរោគហ៊ីវនិងអ្នកជំងឺអេដស៍ បានឱទ្ទេសនាមសេចក្តីថ្លែងការនៅចំពោះមុខនាយករដ្ឋមន្ត្រីដើម្បីឱ្យពួកគេបានទទួលនូវថ្នាំពេទ្យនិងសេវាថែទាំសុខភាព ។

**៥. ធ្វើយុទ្ធនាការ** ក្រោយពីដាក់ស្នើសេចក្តីព្រាងច្បាប់គឺជាការចាំបាច់ តាមធម្មតាច្បាប់មិននិយាយលំអិតរហូតដល់វិធីដែលគេយកច្បាប់ទៅប្រើនោះទេ រាជរដ្ឋាភិបាលអនុម័តច្បាប់ទៅតាម ៖

- អនុក្រឹត្យ
- សេចក្តីប្រកាស
- សេចក្តីសម្រេច
- សារាចរ

ឯកសារទាំងនេះមានការទាក់ទងច្រើនជាមួយនិងជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាសាមញ្ញច្រើនជាងច្បាប់ទៅទៀត ពីព្រោះវាកំណត់ពីសេចក្តីលំអិតនៃវិធីដែលគេយកច្បាប់ទៅអនុវត្តជាក់ស្តែង។ ដូច្នេះចាំបាច់អ្នកតស៊ូមតិត្រូវតែបន្តដាក់ការគាបសង្កត់ ទោះបីជាច្បាប់ត្រូវបានអនុម័តហើយក្តី ត្រូវតាមដានចំពោះការចេញគោលការណ៍ណែនាំជាបន្ថែមទៀត ។

***កត្តាដែលនាំទៅរកលទ្ធផលជាទីពេញចិត្ត*** ៖ កត្តាទាំងនេះរួមមានទំនាក់ទំនងល្អជាមួយនិងក្រសួង ការទាក់ទងក្រៅផ្លូវការការសម្របសម្រួលការងារល្អ និងការយល់គ្នាបានច្បាស់រវាងអង្គការមិនមែនរដ្ឋាភិបាលជាមួយនិងអង្គការអន្តរជាតិ ។ សកម្មភាពរបស់ប្រជាជនដូចជាបាតុកម្មតវ៉ាលើ ជម្លោះដីធ្លីឬសកម្មភាពដោយផ្ទាល់ ដូចជាសហគមន៍រួមគ្នាចាប់ម៉ាស៊ីនបូមទឹកខុសច្បាប់ សុទ្ធតែផ្តល់ជាកម្លាំងនិងភាពស្របច្បាប់ឱ្យដល់ការខិតខំលើការតស៊ូមតិ ។ ជាញឹកញាប់ការងារបញ្ចុះបញ្ចូលជាមួយនិងផ្នែកនីតិបញ្ញត្តិមិនមែនជាការនាំទៅរកការបង្កើតច្បាប់ថ្មីទេ តែអាចជួយក្នុងការធ្វើសំណើច្បាប់ឱ្យមានសមធម៌ច្រើនដោយផ្អែកទៅលើការអនុវត្តន៍បានល្អ ។ ការងារនេះអាចទទួលបានជោគជ័យនៅក្នុងប្រការដទៃទៀតដែរ គឺវាធ្វើឱ្យអ្នកដែលមានការពាក់ព័ន្ធដឹងពីសិទ្ធិរបស់គេ និងការទទួលខុសត្រូវរបស់មន្ត្រីដែលជាប់ឆ្នោតនៅក្នុងរដ្ឋាភិបាល ត្រូវតែដឹងពីបញ្ហាដែលខ្លួនត្រូវដោះស្រាយ ។ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលនិងបុគ្គលិករដ្ឋាភិបាលត្រូវលើកកម្ពស់សមត្ថភាពរបស់គេនៅក្នុងការប្រើឥទ្ធិពលទៅលើអ្នកធ្វើច្បាប់នៅក្នុងដំណើរការនីតិបញ្ញត្តិហើយដាក់ការគាបសង្កត់ទៅលើរដ្ឋាភិបាលឱ្យដំណើរការនៃការអនុម័តច្បាប់ និងលិខិតបទដ្ឋានផ្សេងៗ មានតម្លាភាពនិងមានលក្ខណៈចូលរួម ។

**ការទាក់ទាញប្រព័ន្ធឃោសនា ៖**

ជាយុទ្ធសាស្ត្រមួយនៅក្នុងចំណោមយុទ្ធសាស្ត្រសំខាន់ៗនៃការតស៊ូមតិគឺទាក់ទាញការយកចិត្តទុកដាក់របស់អ្នកធ្វើគោលនយោបាយ និងសាធារណជនទូទៅ ចំពោះបុព្វហេតុមួយ ដើម្បីឱ្យគេគាំទ្រឬមានការយល់ដឹងបុព្វហេតុនោះ ។ **យុទ្ធនាការតាមប្រព័ន្ធឃោសនារួមមាន** ការរៀបចំសារការបង្ហាញសារ ការស្វែងរក និងការដាក់គោលដៅលើក្រុមមនុស្សមានឥទ្ធិពលដែលមានតួនាទីសំខាន់នៅក្នុង

ការស្វែងរកការគាំទ្រ ដើម្បីដោះស្រាយឬគាំទ្របុព្វហេតុអ្វីមួយ ។ ទោះបីជាបណ្តាញឃោសនានៅក្នុងប្រទេសកម្ពុជានៅមានបញ្ហាទាក់ទងនិងរឿងឯករាជភាព និងការយកពត៌មានដែលពិតក៏ដោយ ប៉ុន្តែវិទ្យុ កាសែត និងទូរទស្សន៍នៅតែមានសារៈសំខាន់ចាំបាច់ សម្រាប់អន្ទងដល់មតិសាធារណៈ ។ អ្នកដែលអាចធ្វើការផ្សព្វផ្សាយនូវពត៌មាននេះបានគឺ បណ្តាញឃោសនា កាសែត ស្ថានីយ៍វិទ្យុ និងទូរទស្សន៍ ។

ខាងក្រោមនេះគឺជាបញ្ជីនៃយុទ្ធសាស្ត្រសម្រាប់ធ្វើការជាមួយនិងបណ្តាញឃោសនា ៖

### ***សេចក្តីប្រកាសពត៌មាន និង សន្និសីទកាសែត***

***សេចក្តីប្រកាសពត៌មាន*** ៖ គឺជាសេចក្តីសង្ខេបមួយទំព័រដែលមានពត៌មានសំខាន់ៗមួយចំនួន ដែលអង្គការនានាចែកជូនដល់កាសែតនិងស្ថានីយ៍ផ្សព្វផ្សាយ ដើម្បីឱ្យគេផ្សព្វផ្សាយពីព្រឹត្តិការណ៍ឬរឿងអ្វីមួយ ។ គោលបំណងនៃការធ្វើដូចនេះគឺ ដើម្បីឱ្យប្រព័ន្ធឃោសនាធ្វើការបោះពុម្ព ឬផ្សាយពត៌មានដល់អ្នកស្តាប់និងអ្នកអានឱ្យបានច្រើនគ្នា ។ សេចក្តីប្រកាសពត៌មាន ច្រើនតែត្រូវបានគេប្រើប្រាស់ដើម្បីទាក់ទាញអ្នកកាសែតឱ្យមកចូលរួមនៅក្នុងព្រឹត្តិការណ៍ដូចជាសន្និសីទ ឬបាតុកម្ម ។ សេចក្តីប្រកាសពត៌មានគំរូមាននៅក្នុងសៀវភៅណែនាំនេះ ។

***សន្និសីទកាសែត*** ៖ ប្រហាក់ប្រហែលគ្នាទៅនឹងសេចក្តីប្រកាសពត៌មាននៅត្រង់ថា អ្នកកាសែតត្រូវបានគេអញ្ជើញឱ្យមកទទួលយកពត៌មានស្តីពីរឿងអ្វីមួយ ។ សកម្មភាពនេះមានប្រយោជន៍នៅត្រង់ ការធ្វើឱ្យមានការប្រាស្រ័យទាក់ទងជាមួយ និងអ្នកដែលតំណាងឱ្យយុទ្ធនាការរបស់អ្នក ។ សន្និសីទ កាសែតមានសារៈសំខាន់នៅត្រង់ការធ្វើឱ្យគេមានការចាប់អារម្មណ៍ភ្លាមៗ តែបើមិនមានសកម្មភាពអ្វីទៀតអមមកជាមួយទេនោះ សន្និសីទកាសែតក៏គ្មានប្រសិទ្ធិភាពដែរ ។ ឧទាហរណ៍ អង្គការអភិវឌ្ឍទីក្រុងបានរៀបចំសន្និសីទកាសែតមួយបានល្អ ដើម្បីតវ៉ានឹងគោលនយោបាយលើការរើទីលំនៅរបស់ជនរងគ្រោះដោយអគ្គិភ័យនៅសង្កាត់ទន្លេបាសាក់របស់សាលាក្រុង តែដោយសារការខ្វះសាមគ្គីនិងការចងក្រងគ្នាបានល្អ អង្គការទាំងនោះមិនអាចធ្វើឱ្យមានការកែប្រែគោលនយោបាយរបស់សាលាក្រុងបានទេ ។

### ***បង្កើតទំនាក់ទំនងការងារជាមួយនិងអ្នកកាសែត***

វត្តមានរបស់ប្រព័ន្ធឃោសនានៅក្នុងព្រឹត្តិការណ៍មួយមានឥទ្ធិពលដោយផ្ទាល់ទៅលើអាកប្បកិរិយារបស់អាជ្ញាធរ ។ នៅពេលដែលមន្ត្រីនានាដឹងថាពាក្យសំដីនិងសកម្មភាពរបស់គេត្រូវបានកត់ត្រាទុកនោះ គេនឹងមានការប្រុងប្រយ័ត្ន ។ អ្នកតស៊ូមតិឱ្យជនក្រីក្រនៅតាមទីក្រុងបានប្រើប្រាស់វិធីនេះបានល្អ គឺនៅពេលដែលសហគមន៍មួយមិនបានទទួលការយល់ព្រមពីអាជ្ញាធរដើម្បីកសាងកន្លែងមើលក្មេងមួយនៅក្នុងតំបន់សំណង់អាណាធិបតេយ្យ មេដឹកនាំសហគមន៍សម្រេចសង់កន្លែងមួយនៅពេលយប់ ហើយអញ្ជើញឱ្យអ្នកកាសែតទៅចូលរួមនៅក្នុងពិធីបើកនៅថ្ងៃបន្ទាប់មក ។ ដោយមានការចាប់អារម្មណ៍របស់សាធារណជន អាជ្ញាធរមូលដ្ឋានមានការរអានៅក្នុងការរុះរើកន្លែងនោះ ។ ការមានបញ្ជីឈ្មោះអ្នកកាសែតដែលអ្នកធ្លាប់មានបទពិសោធន៍ល្អជាមួយកន្លងមក គឺជាវិធីល្អសម្រាប់រៀបចំឱ្យមានឱកាសបែបនេះ ។

### ***ចែកផ្សាយពត៌មានដែលអាចទុកចិត្តបាន***

យុទ្ធនាការតស៊ូមតិពឹងផ្អែកមួយភាគធំលើប្រភពពត៌មានច្បាស់លាស់ និងការចែកចាយពត៌មានដែលគេអាចយកជាការបាន ដើម្បីធ្វើការផ្លាស់ប្តូរទស្សនៈយល់ឃើញរបស់សាធារណជនទៅលើបញ្ហាមួយ ។ ដូច្នេះគេត្រូវតែ

ប្រមូល និងចងក្រងពត៌មានឱ្យបានត្រឹមត្រូវច្បាស់លាស់សម្រាប់យកទៅប្រើនៅក្នុងប្រព័ន្ធឃោសនានិងយុទ្ធនាការឯទៀត ។ ពេលប្រាប់ពត៌មានរបស់អ្នកទៅកាន់ប្រព័ន្ធឃោសនា ធ្វើយ៉ាងណាឱ្យអង្គការរបស់អ្នក (និងអង្គការដៃគូរបស់អ្នក) យល់ស្របជាមុនលើអ្វីដែលត្រូវបញ្ចេញប្រាប់ទៅឱ្យអ្នកកាសែតដឹង ។ បើមិនមានការយល់ស្របគ្នាលើខ្លឹមសារនិងសេចក្ដីលំអិតទេ នោះវានឹងធ្វើឱ្យរូបភាពខាងក្រៅនៃយុទ្ធនាការរបស់អ្នកមិនល្អ ហើយធ្វើឱ្យខូចដល់បំណងនៃការប្រើប្រាស់បណ្ដាញសារពត៌មានដែលមាននាទីប្រាប់ទៅសាធារណជនឱ្យបានច្បាស់ពីអ្វីដែលជាបញ្ហា ហើយនិងវិធីដែលអ្នកកំពុងតែខិតខំដោះស្រាយបញ្ហានោះ ។ ចូរមានការប្រុងប្រយ័ត្ន ក្រែងមានផ្ដល់ពត៌មានដែលមានលក្ខណៈផ្ទុយគ្នា ឬធ្វើឱ្យច្រឡំដល់អ្នកកាសែត បើសិនជាមានអ្នកនាំពាក្យលើសពីម្នាក់សម្រាប់យុទ្ធនាការមួយ ។ ជាងនេះទៅទៀត ប្រព័ន្ធឃោសនាមិនមែនសុទ្ធតែរួចផុតទាំងស្រុងពីភាពលំអៀងផ្នែកនយោបាយឡើយ ។ ដូច្នេះបើអ្នកផ្ដល់ពត៌មានមួយ ឬពីរដែលខុសពីការពិតនោះយុទ្ធនាការរបស់អ្នកអាចត្រូវបានគេមើលច្រលំ ។ មនុស្សគ្រប់គ្នាដែលធ្វើការនៅក្នុងយុទ្ធនាការរបស់អ្នក គួរតែប្រាប់ទៅអ្នកក្រៅនូវរឿងតែមួយ ហើយត្រូវដឹងពីអ្វីដែលគេមិនត្រូវនិយាយប្រាប់អ្នកកាសែត ។ ប្រសិនបើជាអង្គការនានាដែលជាផ្នែកនៃយុទ្ធនាការរបស់អ្នកចង់ផ្ដល់ពត៌មានដោយឡែក១ពីគ្នា អ្នកត្រូវធ្វើយ៉ាងណាឱ្យអ្នកនាំពាក្យមិននិយាយតាំងនាមឱ្យបណ្ដាញទាំងមូលទេ តែមិនត្រូវនិយាយក្នុងនាមជាតំណាងឱ្យក្រុមរបស់គេប៉ុណ្ណោះ ។

នៅពេលដែលមានការចូលរួមប្រាកដប្រជាមួយ រវាងអង្គការសង្គមស៊ីវិល និង ផ្នែកនីតិបញ្ញត្តិរដ្ឋាភិបាលហើយដំណើរការបង្កើតគោលនយោបាយ ឬច្បាប់នៅមិនទាន់រលូននៅឡើយក៏ប៉ុន្តែជាទូទៅភាគីទាំងអស់មានការពេញចិត្តលើសមិទ្ធិផលដែលសម្រេចមកនោះ ។

# សមិទ្ធិផលសម្រេចបាន ការលំបាកប្រឈមមុខ និង មេរៀនសម្រាប់អនាគត

## សមិទ្ធិផលដែលសម្រេចបានពីការតស៊ូមតិនៅកម្ពុជា :

- របៀបវារៈផ្នែកនីតិបញ្ញត្តិមួយចំនួនរួមទាំងច្បាប់ការងារឆ្នាំ១៩៩៧ និងច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារដែលនៅពេលថ្មីៗនេះកំពុងត្រូវបានគេជជែកដេញដោលគ្នា ហើយត្រូវបានផ្តួចផ្តើមឡើងតាមរយៈយុទ្ធនាការតស៊ូមតិ ។ ពង្រាងច្បាប់ផ្សេងៗទៀតដែលមានលក្ខណៈផុយស្រួយពាក់ព័ន្ធនិងនយោបាយខ្លាំងមានដូចជា ច្បាប់ភូមិបាលថ្មី ច្បាប់ស្តីពីសហគមន៍នេសាទ ច្បាប់ស្តីពីជំងឺអេដស៍ ហើយនិងច្បាប់ព្រៃឈើ ត្រូវបានផ្តួចផ្តើមឡើងនៅក្រោមអានុភាពម្ចាស់ទុន ។

- ស្ថាប័នពហុភាគីខ្លះដូចជាធនាគារពិភពលោកបានចាប់ផ្តើមដាក់ល័ក្ខខ័ណ្ឌទៅលើប្រាក់កម្ចីចំពោះរដ្ឋាភិបាល ដោយទាមទារឱ្យរដ្ឋាភិបាលចូលរួមនៅក្នុងដំណើរការពិគ្រោះយោបល់ជាមួយនិងអង្គការមិនមែនរដ្ឋាភិបាល ហើយនិងអង្គការសង្គមស៊ីវិលដទៃៗទៀត ។ ឧទាហរណ៍ លក្ខខ័ណ្ឌលើកម្ចីចំពោះរដ្ឋាភិបាលដែលបើកឱ្យអង្គការមិនមែនរដ្ឋាភិបាលចូលរួមនៅក្នុងការពិភាក្សាស្តីពីគោលនយោបាយលើផ្នែកជលផល ។

- អង្គការមិនមែនរដ្ឋាភិបាលត្រូវបានគេបញ្ចូលទៅក្នុងការពិគ្រោះយោបល់អំពីសេចក្តីណែនាំការប្រតិបត្តិថ្នាក់ក្រសួងនានា ( សេចក្តីប្រកាស អនុក្រឹត្យ សារាចរ ។ល ។) ដោយរួមទាំងអនុក្រឹត្យស្តីពីច្បាប់ភូមិបាលផង ។ ច្បាប់អនុក្រឹត្យទាំងនេះមានសារៈសំខាន់ខ្លាំងណាស់ ព្រោះវាបានធ្វើឱ្យមានភាពច្បាស់លាស់នូវរបៀបអនុវត្តន៍គោលនយោបាយធំៗទាំងឡាយ ។

- យុទ្ធសាស្ត្រតស៊ូមតិ ដូចជាសិក្ខាសាលាដែលមានការចូលរួមរបស់អង្គការ ទីភ្នាក់ងារអន្តរជាតិ និង តំណាងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ ការធ្វើសន្និសីទកាសែត និងការប្រជុំដែលមានធ្វើជាបន្តជាមួយនិងក្រសួងព្រមទាំងសមាជិកសភាជាតិ បានទទួលជោគជ័យនៅក្នុងការធ្វើឱ្យរដ្ឋាភិបាលចុះហត្ថលេខាលើកិច្ចព្រមព្រៀងអន្តរជាតិមួយចំនួន ។ ការនេះរួមមានទាំងបញ្ហាដែលមានចម្រូងចម្រាស់ដូចជា តុលាការកាត់ក្តីឧក្រិដ្ឋជនអន្តរជាតិ ហើយ និងអនុសញ្ញាសហប្រជាជាតិស្តីពីការបំបាត់ការរើសអើងតាមគ្រប់រូបភាពដែលប្រឆាំងនឹងនារី ។

- សង្គមស៊ីវិលបានពុះពារហើយបានទទួលជោគជ័យច្រើននៅក្នុងការធ្វើឱ្យគេបញ្ចូលខ្លួនទៅក្នុងការសម្រេចចិត្តស្តីពីការរៀបចំគោលនយោបាយ ។ នៅពេលមានការភ្ជាប់ទំនាក់ទំនងរវាងអង្គការសង្គមស៊ីវិលនិងអ្នកធ្វើគោល-នយោបាយរបស់រដ្ឋាភិបាលបានច្បាស់លាស់ ដំណើរការមិនប្រព្រឹត្តិទៅស្រួលទេ ប៉ុន្តែលទ្ធផលគឺបានជាទីពេញចិត្តដល់ភាគីទាំងសងខាង ។

- ការយល់ដឹងរបស់សាធារណជនលើសិទ្ធិ និងការទទួលខុសត្រូវសំខាន់ៗត្រូវបានលើកឡើង ។ ឧទាហរណ៍ អំពើពុករលួយនៅពេលនេះត្រូវបានគេនិយាយពេញមាត់ ។ ពីមុនមិនមាននរណាហ៊ាននិយាយទេ ហើយនៅពេលនេះរដ្ឋាភិបាលកំពុងតែពិភាក្សាដេញដោលលើច្បាប់ប្រឆាំងនឹងអំពើពុករលួយ ។

- អង្គការមួយចំនួនដែលធ្វើការលើការកសាងសមត្ថភាពលើការតស៊ូមតិ បានបង្កើនសកម្មភាពរបស់គេ ។ វេទិការបស់អង្គការមិនមែនរដ្ឋាភិបាល និងអង្គការស្តារកម្ពុជានៅតែបន្តបើកវគ្គបណ្តុះបណ្តាលដើម្បីលើកកម្ពស់ជំនាញនៅក្នុងការតស៊ូមតិ ។ អង្គការស្តារកម្ពុជាបានបង្កើតបណ្តាញតស៊ូមតិនៅខេត្តចំនួន ៤ ។

- រដ្ឋាភិបាលបានសម្តែងចេញនូវការប្តេជ្ញាបញ្ចូលទិសដៅប្រឆាំងនឹងភាពក្រីក្រ និងអនុគ្រោះដល់អ្នកក្រនៅក្នុងផែនការយូរអង្វែងរបស់ខ្លួន ។ មន្ត្រីរដ្ឋាភិបាលថ្នាក់ខ្ពស់ៗនិយាយដោយចំហពីភាពចាំបាច់ត្រូវបំបាត់អំពើពុករលួយហើយនិងជួយអ្នកក្រីក្រ ។ ការធ្វើការតស៊ូមតិនៅក្នុងប្រទេសមួយដែលបានសន្យាជួយអ្នកក្រីក្រ តែទ្រឹស្តីនិងពង្រឹងនីតិវិធីច្បាប់ គឺខុសគ្នាខ្លាំងជាងទង្វើសង្កត់សង្កិនជាចំហ ។ អ្នកតស៊ូមតិនៅក្នុងប្រទេសកម្ពុជាអាចធ្វើការដោយមានការគាំទ្រជាទ្រឹស្តីហើយនិងការការពារពីរដ្ឋាភិបាល ហើយរំលឹកមន្ត្រីនានារបស់ពួកគេអំពីការតាំងចិត្តរបស់ពួកគេពីអតីតកាលកន្លងមក ។

## ការលំបាកប្រឈមមុខចំពោះការតស៊ូមតិនៅក្នុងប្រទេសកម្ពុជា :

- មន្ត្រីនៅថ្នាក់ជាតិនិងថ្នាក់ខេត្តខ្លះត្រូវបានតែងតាំងឡើងដោយគណបក្សរបស់គេ មិនមែនត្រូវបានជាប់ឆ្នោតតាមឯកត្តនាម( បុគ្គល )ទេ ។ ឧទាហរណ៍ អភិបាលខេត្តត្រូវបានតែងតាំងឡើងដោយគណបក្សដែលមានកៅអីសភាច្រើនជាងគេនៅក្នុងខេត្តនោះ ។ ទោះបីនៅក្នុងការបោះឆ្នោតដោយផ្ទាល់ក្តីដូចជាការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អ្នកបោះឆ្នោតបោះឱ្យគណបក្សមិនមែនបោះឆ្នោតឱ្យបុគ្គលទេ ។ ការមិនមានការបោះឆ្នោតដោយផ្ទាល់មានន័យថា មន្ត្រីនានាមិនសូវឈឺក្បាលនឹងការរិះគន់របស់ប្រជាជនក្នុងមណ្ឌលរបស់គេទេ ពីព្រោះថាការគម្រាមកំហែងនៃការបោះឆ្នោតទម្លាក់គឺមិនមែនមានលក្ខណៈដោយផ្ទាល់ឬទៅតាមបុគ្គលនិមួយៗនោះទេ ។ មន្ត្រីរដ្ឋាភិបាលភាគច្រើនមិនយល់ច្បាស់ថាជាដំបូងពួកគេតំណាងឱ្យប្រជាពលរដ្ឋ និង ទី២ តំណាងឱ្យគណបក្ស ។ ការនេះជាបញ្ហាលំបាកមួយសម្រាប់អ្នកដែលចង់ធ្វើការបញ្ចុះបញ្ចូលដើម្បីបុព្វហេតុអ្វីមួយ ហើយកំណត់ឱ្យអ្នកនយោបាយទទួលខុសត្រូវទៅតាមពាក្យសំដីរបស់គេ ។

- យន្តការនៃការធ្វើឱ្យមានសុពលភាពច្បាប់គឺមានភាពមិនច្បាស់លាស់នៅក្នុងប្រទេសកម្ពុជា ។ ច្បាប់មិនត្រូវបានគេធ្វើឱ្យមានសុពលភាពតាមប្រព័ន្ធត្រឹមត្រូវនៅឡើយ ហើយអំពើពុករលួយមានន័យជាប្រាក់ជាជាង ច្បាប់ ដែលជារើយៗវាបានប្រាប់ឱ្យដឹងថា តើមុខនាទីប្រព័ន្ធយុត្តិធម៌មានការអនុវត្តយ៉ាងដូចម្តេច ។ ការនេះមានន័យថាការផ្លាស់ប្តូរលើគោលនយោបាយសាធារណៈ មិនមែនសុទ្ធតែត្រូវបានឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរនៃការរស់នៅរបស់ប្រជាជនឡើយ ។

- ផ្នែកខាងការតស៊ូមតិរបស់ប្រទេសកម្ពុជានៅមានភាពក្មេងខ្ចីនៅឡើយ ។ អង្គការមិនមែនរដ្ឋាភិបាលភាគច្រើន

- មិនសូវមានបទពិសោធន៍នៅក្នុងការធ្វើយុទ្ធនាការ ហើយក៏មិនមានសមត្ថភាពធ្វើឱ្យយុទ្ធនាការទទួលបានជោគជ័យដែរ ។ សមត្ថភាពគឺនៅទាបខ្លាំងនៅក្នុងវិស័យដែលទាក់ទងជាមួយនិងរដ្ឋាភិបាល ។ គេមិនដឹងថា តើសង្គមស៊ីវិលនិងរដ្ឋាភិបាលប្រសព្វគ្នានៅត្រង់ណា បញ្ហានេះធ្វើឱ្យមានការពិបាកនៅក្នុងការកំណត់ថា តើសង្គមស៊ីវិលគួរប្រាស្រ័យជាមួយថ្នាក់ណាខ្លះក្នុងរដ្ឋាភិបាលដើម្បីដោះស្រាយបញ្ហាអ្វីមួយ ។ អង្គការមិនមែនរដ្ឋាភិបាលត្រូវធ្វើការប្រឹងប្រែងរួមគ្នាដើម្បីអប់រំខ្លួនគេពីប្រព័ន្ធច្បាប់នៅក្នុងប្រទេសកម្ពុជាបើសិនជាគេចង់ឈានទៅសម្រេចជោគជ័យនៅក្នុងទិសដៅអភិវឌ្ឍន៍របស់គេ ។

**មេរៀនដែលបានរៀនសូត្រ :** អ្នកតស៊ូមតិបានរៀនសូត្រច្រើនពីបទពិសោធន៍របស់ខ្លួននៅក្នុងពេលប៉ុន្មានឆ្នាំកន្លងទៅនេះ ។ មេរៀនសំខាន់ៗមានដូចជា :

- ***ត្រូវប្រាកដថាយុទ្ធនាការមានការគាំទ្រពីប្រជាជន*** បើមិនមានការគាំទ្រពីប្រជាជននិងមិនមានឯកសារសម្រាប់យកមកធ្វើអំណះអំណាងឱ្យបានគ្រប់គ្រាន់ទេនោះ អ្នកនយោបាយមិនសូវអើពើលើបញ្ហាលើកឡើងប៉ុន្មានទេ ពីព្រោះនៅពេលអនាគតនយោបាយរបស់គេមិនរងការប៉ះពាល់ដល់រឿងនោះទេ ។

- ***ចាប់ផ្ដើមធ្វើការបញ្ចុះបញ្ចូលឱ្យបានឆាប់ :*** កាលណាអង្គការមិនមែនរដ្ឋាភិបាលណាដែលបញ្ចុះបញ្ចូលបានឆាប់ និងមន្ត្រីរដ្ឋាភិបាលអាចទទួលយកអនុសាសន៍បញ្ចូលទៅលើច្បាប់ថ្មី ឬច្បាប់កែសម្រួលបានកាន់តែឆាប់ ឱកាសល្អគឺអនុសាសន៍របស់ពួកគេត្រូវបានគេបញ្ចូលទៅក្នុងច្បាប់នោះកាន់តែមានច្រើន ។ អ្នកតស៊ូមតិដែលចាប់ផ្ដើមធ្វើការតស៊ូមតិនៅពេលដែលពង្រាងច្បាប់ត្រូវបានផ្ញើទៅក្រុមប្រឹក្សារដ្ឋមន្ត្រី ហើយប្រហែលជាមិនទទួលបានជោគជ័យទេ គឺបណ្ដាលមកពីការចូលប្រឡូកនៅក្នុងដំណើរការមានការយឺតពេក ។

- ***កំណត់គួរអង្គតស៊ូមតិនៅក្នុងជួររដ្ឋាភិបាល :*** នៅពេលដែលមន្ត្រីម្នាក់មិនពេញចិត្តនឹងរឿងអ្វីមួយ ហើយការពិភាក្សាគ្នាលែងដំណើរការទៅមុខរួចនោះ អ្នកតស៊ូមតិអាចរកមើលមនុស្សសំខាន់ៗផ្សេងទៀតដែលមានចិត្តចង់ស្ដាប់អំណះអំណាងរបស់យើង ព្រោះអ្នកទាំងនេះអាចដាក់ការគាបសង្កត់បន្ថែមលើអង្គនីតិបញ្ញត្តិ ។

- ***ត្រៀមជាស្រេចចំពោះយុទ្ធវិធីពន្យាពេលជាទូទៅដែលធ្វើឡើងដោយអ្នកតាក់តែងច្បាប់*** ការនេះរួមមាន :

**១.** ដាក់ការស្ដីបន្ទោសទៅលើប្រធានឬប្រកាសថាគេមិនមានអំណាចដើម្បីចាត់ការទេ ។ ការឆ្លើយតបសមស្របមួយ គឺប្រើវិធីសាស្ត្រសម្រាប់ទំនាក់ទំនងជាមួយនិងលំដាប់ថ្នាក់ច្រើនបាន ព្យាករណ៍មើលពីជំហររបស់មន្ត្រីនៅមុនពេលទៅជួបជាមួយគេ ស្វែងរកការគាំទ្រពីមន្ត្រីនានាឱ្យបានច្រើន ហើយធ្វើឱ្យគេឯងដឹងពីការគាំទ្រនោះត្រូវពិចារណាលើការដៅ ឬធ្វើការជាមួយនិងស្ថាប័នផ្សេងៗទៀតរបស់រដ្ឋាភិបាលឱ្យបានច្រើន ។

**២.** សុំឱ្យអ្នកតវ៉ាប្រមូលពត៌មានឱ្យបានច្រើនទាក់ទងនឹងការតវ៉ារបស់គេ ឬឱ្យគេមានការទទួលខុសត្រូវលើការសម្រេចបានលើជំហានបន្ទាប់ (ការអនុវត្តន៍ល្អបំផុតគឺ អ្នកត្រូវបង្ហើយការស្រាវជ្រាវរបស់អ្នកនៅមុនពេលប្រជុំ ដើម្បីអាចឆ្លើយបាននឹងសំណួរទាំងឡាយដែលអាចកើតមានឡើង) ។

**៣.** បង្កឱ្យមានភាពតានតឹងនៅក្នុងសហគមន៍ដែលទទួលរងនូវការប៉ះពាល់ (ការឆ្លើយតបល្អបំផុតគឺ យល់ពីបំណងនិងសេចក្ដីត្រូវការរបស់សហគមន៍ដែលទទួលរងនូវការ

ប៉ះពាល់ប្រភេទនៃការគាបសង្កត់ដែលអាចដាក់ទៅលើសមាជិករបស់ខ្លួន ហើយនិងវិធីដែលអ្នកអាចជួយគេនៅក្នុងការឆ្លើយតបនឹងភាពតានតឹងនេះ ។ រក្សាទស្សនៈច្បាស់លាស់និងមានទំនាក់ទំនងល្អជាមួយនិងសមាជិកសហគមន៍) ។

៤.សន្យាចាត់វិធានការតែបែរជាមិនធ្វើ (ការឆ្លើយតបល្អបំផុតគឺ ប្រសិនបើមន្ត្រីម្នាក់ព្រមចាត់វិធានការហើយ ចូររកមើលថា តើជំហានបន្ទាប់ទៀតត្រូវធ្វើអ្វីដើម្បីឱ្យមន្ត្រីនោះចាត់វិធានការតាមការសន្យា ហើយតាមដានលើដំណើរការនោះឱ្យបានជាប់ ។ ការធ្វើដូច្នេះធ្វើឱ្យអ្នកដឹងភ្លាមបើមានការយឺតយ៉ាវ ។ ឱ្យអ្នកនយោបាយធ្វើការសន្យាជាសាធារណៈហើយបង្ខំគេឱ្យធ្វើតាមការសន្យានោះ ។

- ***ត្រូវមានឯកសារច្បាប់ឱ្យច្រើនទុកបម្រុងសម្រាប់ចែកចាយ*** ផ្នែកឯកជនក៏មានប្រើយុទ្ធវិធីដើម្បីធ្វើការពន្យាពេលផងដែរ ។ ឧទាហរណ៍ ថៅកែឡូតិ៍នេសាទអះអាងថាគេមិនបានដឹងពីអនុក្រឹត្យឬបទបញ្ញាអ្វីផ្សេងឡើយ ។ ចូរបម្រុងឯកសារទាំងនោះទុកផ្ដល់ដល់គេ ។

- ***ចូរចាំថាការសម្រេចចិត្តទាំងអស់ត្រូវបានគេធ្វើហើយនៅមុនពេលប្រជុំធំៗ*** ដូច្នេះការបញ្ចុះបញ្ចូលត្រូវធ្វើឱ្យបានយូរមុនការ ប្រជុំសម្រេចចិត្តសំខាន់ៗ ។

- ***រក្សាការសម្របសម្រួលការងារល្អនៅក្នុងចំណោមអ្នកតស៊ូមតិ*** : គេត្រូវមានទស្សនៈរួមគ្នាហើយរកមើលឧបសគ្គដែលអាចធ្វើឱ្យប៉ះពាល់ដល់ការប្ដេជ្ញាចិត្តយូរទៅមុខរបស់សមាជិកនៅក្នុងសម្ព័ន្ធដើម្បីជៀសវាងការចុះទន់ខ្សោយនៃការសាមគ្គីរបស់សម្ព័ន្ធដែលអាចបំផ្លាញដល់យុទ្ធនាការ ។



អង្គការត្រួតពិនិត្យការបោះឆ្នោតចែកចាយពត៌មានដល់តំបន់ជនបទ

# ករណីសិក្សាទីមួយ

**សហគមន៍នេសាទ ៖ សហគមន៍នេសាទ និង ការធ្វើឱ្យចេញជាលទ្ធផលលើយុទ្ធនាការតស៊ូមតិ**

## សហគមន៍នេសាទ ៖ សហគមន៍នេសាទនិងការធ្វើឱ្យចេញជាលទ្ធផលលើយុទ្ធនាការតស៊ូមតិ

នៅពេលនេះកម្ពុជា ជាប្រទេសទីបួនដែលមានឧស្សាហកម្មត្រីទឹកសាបធំជាងគេនៅក្នុងពិភពលោកដែលផ្តល់ការងារឱ្យដល់មនុស្សជាងពីរលាននាក់ ហើយបំពេញតម្រូវការជាតិប្រូតេអ៊ីនសាច់ដល់ទៅ៧៥%នៅក្នុងប្រទេស ។ គោលនយោបាយផ្នែកជលផលរបស់រដ្ឋាភិបាលដែលត្រូវបានអនុម័តនៅឆ្នាំ ១៩៨៨ គឺមានលក្ខណៈហួសសម័យ បើយកទៅអនុវត្តពិតជាអាចគំរាមកំហែងដល់និរន្តរភាពនៃវិស័យជលផលនៅកម្ពុជា ។ ដោយឡែកសហគមន៍ដែលរស់នៅពឹងផ្អែកលើការនេសាទទទួលរងនូវការគំរាមកំហែងខ្លាំងពីការនេសាទពាណិជ្ជកម្ម ។ ពួកគេបានបាត់បង់ការគ្រប់គ្រងលើការនេសាទដែលជាការគំរាមកំហែងមួយដល់ការរស់រានយូរអង្វែងទៅមុខរបស់ផ្នែកជលផលព្រមទាំងសហគមន៍ ។ ជម្លោះលើរឿងឡូតិ៍នេសាទជាមួយនិងសហគមន៍មូលដ្ឋានមានកាន់តែច្រើន ដែលជាការណ៍មួយធ្វើឱ្យគេធ្វើយុទ្ធនាការតស៊ូមតិមានជាប់ជាហូរហែរ ។

- **បណ្តាញការងារផ្នែកបរិស្ថានរបស់អង្គការមិនមែនរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់លើបញ្ហានេះ**

នៅក្នុងការប្រជុំក្រុមការងារផ្នែកបរិស្ថានរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលកាលពីឆ្នាំ ១៩៩៩ អង្គការអភិវឌ្ឍន៍ស្ត្រីបានលើកឡើងនូវករណីជម្លោះជលផលនៅខេត្តបាត់ដំបងដែលបានបញ្ចប់ដោយមានការបាញ់ប្រហារមួយ ហើយគណៈកម្មាធិការទន្លេមេគង្គក៏បានធ្វើបទឧទ្ទេសនាមមួយស្តីពីស្ថានភាពរួមនៃវិស័យជលផលនៅក្នុងប្រទេសកម្ពុជាដែលបង្ហាញពីទំហំនៃបញ្ហា ។ ក្រុមការងារបានសម្រេចថាជម្លោះលើវិស័យជលផល គេត្រូវតែគិតគូរឱ្យបានច្រើន ហើយត្រូវបង្កើតឱ្យមានក្រុមការងារផ្នែកជលផលដើម្បីពិភាក្សាលើករណីទាំងនេះ ។ វេទិកាសាធារណៈមួយដែលត្រូវបានរៀបចំឡើងនៅបាត់ដំបងនៅក្នុងខែកុម្ភៈ ឆ្នាំ ២000 ដោយមានការចូលរួមពីឧបនាយករដ្ឋមន្ត្រី អនុរដ្ឋលេខាធិការក្រសួងកសិកម្ម អាជ្ញាធរមូលដ្ឋាននិងសមាជិកសហគមន៍ដែលរងនូវការប៉ះពាល់ ។ នៅក្នុងសេចក្តីសន្និដ្ឋាននៃវេទិកានេះរដ្ឋាភិបាលបានសន្យាថានឹងដោះស្រាយបញ្ហា ហើយកំណត់ទុកតំបន់នេសាទសម្រាប់សហគមន៍ ។ ទោះបីជាយ៉ាងណាក៏ដោយ មន្ត្រីរដ្ឋាភិបាលបានបង្ហាញឱ្យដឹងពីភាពចាំបាច់ដែលត្រូវធ្វើការសិក្សាមើលទៅលើជម្លោះជលផលមុនពេលធ្វើកំណែទម្រង់ ។

- **បញ្ហាផ្នែកជលផលដែលត្រូវបាននចងក្រងឡើងនៅក្នុងករណីសិក្សា**

ក្រុមការងារផ្នែកជលផលបានចងក្រងករណីសិក្សាមួយស្តីអំពីជម្លោះនៅខេត្តបាត់ដំបង ហើយចែកចាយឯកសារនោះទៅឱ្យអង្គការមិនមែនរដ្ឋាភិបាលបុគ្គលិករដ្ឋាភិបាលនិងម្ចាស់ជំនួយនានា ។ គោលបំណងនៃរបាយការណ៍នេះគឺដើម្បី

ធ្វើការផ្សព្វផ្សាយពត៌មាន នៅពេលជាមួយគ្នានេះការលើកទឹកចិត្តដល់សមាជិករបស់បណ្តាញឱ្យចេះរាយការណ៍ត្រឡប់មកវិញស្តីពីជម្លោះផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានៅក្នុងតំបន់របស់គេ។ នៅពេលគេដឹងពីបញ្ហាច្រើនទៀត សមាជិករបស់ក្រុមការងារបានចាប់ផ្តើមចងក្រងឯកសារលើករណីផ្សេងទៀត ហើយនិងផ្សព្វផ្សាយពត៌មានថ្មីនេះ។

- **អង្គការមិនមែនរដ្ឋាភិបាលរៀបចំសិក្ខាសាលាជលផលថ្នាក់ជាតិនិងថ្នាក់ខេត្ត**

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលបានបើកសិក្ខាសាលាផ្នែកជលផលនៅតាមខេត្តដោយចាប់ផ្តើមនៅក្នុងខែតុលា ឆ្នាំ ២000 ដើម្បីឆ្លើយតបទៅនឹងរបាយការណ៍ស្តីពីជម្លោះនេសាទកើតមានកាន់តែច្រើនឡើង ។ សិក្ខាសាលាទាំងនោះទទួលបានជោគជ័យច្រើននៅក្នុងការផ្តួចផ្តើមឱ្យមានការពិភាក្សាគ្នាស្តីពីជលផលនៅថ្នាក់សហគមន៍ ដោយធានាថាការពិភាក្សាមិនមែនមាននៅត្រឹមតែការប្រជុំរបស់អង្គការមិនមែនរដ្ឋាភិបាលនោះទេ។

តំណាងរបស់សហគមន៍នេសាទ និងអង្គការមិនមែនរដ្ឋាភិបាលត្រូវបាននាយកដ្ឋានជលផលអញ្ជើញឱ្យមកចូលរួមនៅក្នុងសិក្ខាសាលាថ្នាក់ជាតិមួយស្តីពីការគ្រប់គ្រងជលផលដែលបានប្រារព្ធធ្វើឡើងនៅភ្នំពេញកាលពីខែធ្នូឆ្នាំ២000។ សិក្ខាសាលានេះត្រូវបានរៀបចំឡើងដោយអង្គការតំបន់ដីសើមអន្តរជាតិ (Wetlands International) ដែលបានទទួលថវិកាពីអង្គការ Oxfam America ។ ការជួយរបស់អង្គការ Oxfam អាចធ្វើឱ្យអង្គការមិនមែនរដ្ឋាភិបាលអាចសុំការបញ្ចូលវត្តមានរបស់សង្គមស៊ីវិលនិងសមាជិកសហគមន៍នៅក្នុងសិក្ខាសាលានេះ ។ ទោះបីជាការពិភាក្សាមានផ្លែផ្កាក្តី តែសិក្ខាសាលាមិនបាននាំទៅរកការបង្កើតផែនការការងារមួយទេ ។ នេះគឺជាការបិទវគ្គមួយដែលជាទឹកចិត្តនៅថ្នាក់ជាតិ ។ សិក្ខាសាលាត្រូវបានគេគិតថាបានទទួលជោគជ័យខ្លះ ពីព្រោះវាផ្តួចផ្តើមឱ្យមានការពិភាក្សាគ្នានៅថ្នាក់មូលដ្ឋាន ហើយនាំឱ្យអ្នកមូលដ្ឋានមានស្មារតីម្ចាស់ការទទួលខុសត្រូវ។

- **សហគមន៍ដែលទទួលរងការប៉ះពាល់ចាត់វិធានការផ្ទាល់**

នៅមុនពេលដែលអង្គការមិនមែនរដ្ឋាភិបាលចាប់ផ្តើមធ្វើការសិក្សាទៅលើបញ្ហាជលផល សហគមន៍នេសាទដែលទទួលរងនូវការប៉ះពាល់ធ្លាប់បានប្រើប្រាស់វិធីសាស្ត្ររបស់គេរួចទៅហើយនៅក្នុងការដាក់ការគាបសង្កត់ទៅលើរដ្ឋាភិបាល ។ខុទ្ទកាល័យរបស់នាយករដ្ឋមន្ត្រី គឺជាគោលដៅនៃលិខិតដែលប្រកបដោយការខឹងសម្បាររបស់សហគមន៍ ការធ្វើបាតុកម្មនៅមុខរដ្ឋសភាជាតិ និងការគាបសង្កត់ពីអន្តរការីនៅក្នុងខុទ្ទការល័យនាយករដ្ឋមន្ត្រី ។ ទោះបីជាវិធីធ្វើការតស៊ូមតិបែបនេះពិតជាចេញមកពីបំណងពិតប្រាកដនៅក្នុងការគាបសង្កត់ទៅលើរដ្ឋាភិបាលក្តី តែគេពិបាកនឹងវាស់វែងបានពីប្រសិទ្ធភាពរបស់វាណាស់ ។ អ្នកខ្លះមានការសង្ស័យថា បច្ចេកទេសទាំងនេះមានប្រយោជន៍ណាស់នៅ



សហគមន៍ជាច្រើនមានការអាក់អន់ចិត្តខ្លាំងឡើងៗដោយសារជម្លោះដ៏ខ្លាំងក្លានិងកង្វះដំណោះស្រាយលើបញ្ហានេសាទ។ ជាញឹកញាប់, សហគមន៍មួយចំនួនបានសម្រេចដោះស្រាយបញ្ហាដោយផ្ទាល់ដៃខ្លួនឯង។ ឧទាហរណ៍ការរឹបអូសឧបករណ៍នេសាទខុសច្បាប់ដូចដែលបានបង្ហាញតាមរយៈរូបភាពខាងលើដែលកើតឡើងក្នុងខេត្តតាកែវ ។

ក្នុងការជំរុញឱ្យរដ្ឋាភិបាលមានការទទួលខុសត្រូវនៅក្នុងកម្រិតណាមួយ ។

តែលទ្ធផលល្អនៃចំណាត់ការដោយផ្ទាល់នៅតាមលំដាប់សហគមន៍គឺច្បាស់ជាង ។ សូម្បីតែនៅពេលដែលមន្ត្រីរបស់រដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាលកំពុងតែជាប់រវល់ពិភាក្សាគ្នាលើការកែប្រែច្បាប់ក្តី ក៏នៅមានសហគមន៍ខ្លះអនុវត្តគោលនយោបាយដែលមានស្រាប់រួចទៅហើយ ។ ឧទាហរណ៍ នៅពេលបច្ចុប្បន្ននេះការបូមទឹកពង្រីង ស្រះ បឹង ការឆក់ត្រី ហើយនិងការអូសអួនដោយប្រើគ្រឿងចក្រគឺជាការខុសច្បាប់ ។ ចំពោះអ្នកដែលមានទំនាក់ទំនងនៅក្នុងនាយកដ្ឋានជលផលនៅតែបន្តធ្វើដូច្នេះ ដែលគំរាមកំហែងដល់និរន្តរភាពនៃធនធានជលផលសម្រាប់ផ្គត់ផ្គង់សេចក្តីត្រូវការរបស់សហគមន៍មូលដ្ឋាន ។ សមាជិកសហគមន៍ចាប់ផ្តើមអនុវត្តច្បាប់ដោយដកហូតគ្រឿងចក្រនិងម៉ាស៊ីនបូមទឹកយកធ្វើជាភស្តុតាង និងចាប់អ្នកប្រព្រឹត្តល្មើសនៅពេលដែលចាំបាច់ ។ ដោយប្រឈមនឹងភស្តុតាងដែលចេះតែមានច្រើន ផ្នែកមន្ទីរការិយាល័យជលផលនៅតាមមូលដ្ឋានត្រូវសារភាពកំហុស ហើយគោរពសិទ្ធិរបស់សហគមន៍ ។ សកម្មភាពដោយផ្ទាល់បែបនេះរបស់អ្នករស់នៅក្នុងមូលដ្ឋាន ឈានទៅកែលំអជីវភាពរស់នៅចំពោះមុខរបស់សហគមន៍នេសាទបានច្រើនជាងការពិភាក្សានៅលំដាប់ថ្នាក់លើៗ ។ សកម្មភាពដោយផ្ទាល់រួបរួមសាមគ្គីសហគមន៍ធ្វើឱ្យសហគមន៍មានលទ្ធភាពច្រើននៅក្នុងការនេសាទ សកម្មភាពដោយផ្ទាល់នៅតាមសហគមន៍អាចបង្ហាញដល់អ្នកធ្វើច្បាប់ថា លទ្ធភាពទទួលបានសិទ្ធិនេសាទគឺជារឿងរបស់សហគមន៍ តែមិនមែនជារឿងរបស់អង្គការក្រៅរដ្ឋាភិបាល ទេ ហើយវាបង្ហាញឱ្យឃើញថាសហគមន៍មានលទ្ធភាពគ្រប់គ្រងធនធានជលផលដោយខ្លួនគេ ។ នៅក្នុងករណីនេះសកម្មភាពដោយផ្ទាល់ ធ្វើឱ្យមានការប្រែប្រួលជាវិជ្ជមានទោះបីជាមិនទាន់មានការកែប្រែច្បាប់ក្តី ។

- **នាយករដ្ឋមន្ត្រីកាត់បន្ថយឡូត៍នេសាទសម្បទាន**

នៅថ្ងៃទី២៤ ខែ តុលា ឆ្នាំ ២០០០ នាយករដ្ឋមន្ត្រីបានប្រកាសការកាត់បន្ថយទំហំឡូត៍នេសាទសម្បទាន ហើយបង្វែរទៅឱ្យការនេសាទជាលក្ខណៈគ្រួសារវិញតាមរយៈអនុក្រឹត្យជាបន្តបន្ទាប់ដែលចេញឱ្យតាមបណ្តាខេត្តនានា ។ ឡូត៍នេសាទណាដែលមានតម្លៃតិចជាង ៣០លាន រៀលត្រូវបានបំបាត់ចោល ហើយបង្វែរទៅឱ្យសហគមន៍ប្រើប្រាស់វិញ ។ សេចក្តីថ្លែងការណ៍នេះធ្វើឱ្យសហគមន៍អាចគ្រប់គ្រងបានច្រើនលើការនេសាទនៅនឹងមូលដ្ឋាន ។ តែបញ្ហានៅតែមាន ទោះបីតំបន់ឡូត៍នេសាទមានការកាត់បន្ថយក្តីតែប្រវែងព្រំប្រទល់ឡូត៍នេសាទមានការកើនឡើងដែលបណ្តាលឱ្យមានជម្លោះកាន់តែច្រើនថែមទៀតរវាងគ្រួសារនេសាទ និងម្ចាស់សម្បទាន ។

- **អង្គការមិនមែនរដ្ឋាភិបាលសាកល្បងគម្រោងសហគមន៍នេសាទ**

ក្នុងខែ ឧសភា ឆ្នាំ ២០០១ កន្លងមកនេះ Oxfam/GB បានចាប់ផ្តើមធ្វើការសាកល្បងគម្រោងកម្មវិធីមួយទៅលើសហគមន៍នេសាទ ដើម្បីវាយតម្លៃពីកម្រិតនៃភាពជាកម្មសិទ្ធលើតំបន់នេសាទសហគមន៍នោះ និងដើម្បីកសាងសមត្ថភាពអង្គការមិនមែនរដ្ឋាភិបាល និងនាយកដ្ឋានជលផលក្នុងការរៀបចំសហគមន៍នេសាទ ។ គម្រោងកម្មវិធីសាកល្បងនេះបានជួបប្រទះការលំបាកមួយចំនួនដោយសារការលំបាកនៅក្នុងកិច្ចសហប្រតិបត្តិការរវាងនាយកដ្ឋានជលផលខេត្ត និងអង្គការមិនមែនរដ្ឋាភិបាល និងដោយសារភាពមិនច្បាស់លាស់នៃការទទួលខុសត្រូវរបស់អង្គការផ្សេងៗ និងអ្នកពាក់ព័ន្ធដទៃៗទៀត ។ សហគមន៍មានបទពិសោធន៍

ពិបាកក្នុងការទទួលនូវសេចក្តីសម្រេចសម្រាប់ការដាក់ព្រំដែន ហើយចំពោះអ្នកដែលទទួលបានជោគជ័យនៅតែពុំទាន់បានការកំណត់ខ្សែព្រំដែននៅឡើយ ។

- **ការពិគ្រោះយោបល់ស្តីពីគោលនយោបាយជលផល**

អង្គការមិនមែនរដ្ឋាភិបាលអាចចូលរួមនៅក្នុងការធ្វើពង្រាងអនុក្រឹត្យសហគមន៍ជលផល ដែលមានបំណងរក្សាធនធានជលផលតាមរយៈការចូលរួមរបស់សហគមន៍នៅក្នុងការគ្រប់គ្រងរួមគ្នាលើធនធានទាំងនោះ និងនៅក្នុងការពិគ្រោះយោបល់ដែលមានកម្រិតព្រំដែនស្តីពីច្បាប់ថ្មីនៃការនេសាទ ។ ពីដំបូងនាយកដ្ឋានជលផលមានការអល់អែកនៅក្នុងការចូលរួមក្នុងដំណើរការពិគ្រោះយោបល់ជាមួយអង្គការមិនមែនរដ្ឋាភិបាលនិងសហគមន៍ ដោយស្នើឱ្យអង្គការមិនមែនរដ្ឋាភិបាលធ្វើការស្នើសុំយោបល់ជាលាយលក្ខណ៍អក្សរ តែអង្គការមិនមែនរដ្ឋាភិបាលនៅតែទទូចនៅក្នុងការបញ្ចុះបញ្ចូលម្ចាស់ជំនួយ អង្គការ និង ទីភ្នាក់ងារដទៃទៀតដែលមានការពាក់ព័ន្ធក្នុងការតស៊ូមតិដោយជោគជ័យចំពោះការសុំឱ្យបញ្ចូលអង្គការមិនមែនរដ្ឋាភិបាលទៅក្នុងដំណើរការពិគ្រោះយោបល់ ។

ការពិគ្រោះយោបល់ត្រូវបានធ្វើឡើងនៅតាមសហគមន៍ផ្សេងៗ ដើម្បីសុំចម្លើយត្រឡប់ចំពោះអនុក្រឹត្យនៅក្នុងឆ្នាំ២០០១ ។នាយកដ្ឋានជលផល Oxfam/America និង Wetlands International បានរៀបចំសិក្ខាសាលាមួយដើម្បីធ្វើឱ្យមនុស្សគ្រប់ស្រទាប់មានការយល់ដឹងដូចគ្នាស្តីអំពីសហគមន៍នេសាទ ។ នៅក្នុងសិក្ខាសាលាប្រធាននាយកដ្ឋានជលផលបានបង្ហាញពង្រាងនៃអនុក្រឹត្យស្តីពីសហគមន៍នេសាទ ហើយនិយាយថាគាត់ស្វាគមន៍មតិយោបល់នានា ។ដោយកត់សំគាល់ឃើញថាអនុសាសន៍របស់គេជាច្រើនត្រូវបានដាក់បញ្ចូល អ្នកចូលរួមបានសរសេរលិខិតសរសើរនាយកដ្ឋានដែលធ្វើការបានល្អ ។ នាយកដ្ឋានជលផលបានបញ្ជូនអនុក្រឹត្យទៅក្រសួងកសិកម្ម តែអនុក្រឹត្យនោះមិនទាន់បានចុះហត្ថលេខាទេ ហើយសំណៅថ្មីក៏មិនទាន់មានបញ្ចូលអនុសាសន៍ណាមួយរបស់សហគមន៍ ឬ អង្គការមិនមែនរដ្ឋាភិបាលឡើយ ។ អនុក្រឹត្យនេះបានបាត់ដោយមិនដឹងជាធ្លាក់ទៅដល់ថ្នាក់ណាទេហើយក៏មិនឃើញមានចម្លើយជាវិជ្ជមានដែរ ។

ការពិគ្រោះយោបល់ជាមួយនិងរដ្ឋាភិបាលស្តីអំពីច្បាប់ទំនងជាមិនទទួលបានជោគជ័យ គឺរដ្ឋាភិបាលយល់ព្រមចូលរួមពិគ្រោះយោបល់ តែនៅក្រោមការគាបសង្កត់ច្រើនរបស់ម្ចាស់ជំនួយតែប៉ុណ្ណោះ ហើយមិនចង់បោះបង់ការគ្រប់គ្រងលើដំណើរការនោះទេ ។ ការពិគ្រោះយោបល់មានធ្វើតែនៅតាមខេត្តមួយចំនួនតូច ហើយបើតាមមើលទើបតែបានចាប់ផ្តើមនៅថ្នាក់ជាតិតែប៉ុណ្ណោះ ប៉ុន្តែនៅតែមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាលធំៗមួយចំនួន ហើយក៏មិនមានការចូលរួមពីសហគមន៍ដែរ ។ ការមិនចូលរួមនេះអាចមកពីភាពតានតឹងក្នុងការពិគ្រោះយោបល់លើកមុនៗជាមួយនិងសមាជិកសហគមន៍ ។ សូម្បីតែក្រុមដែលគេបានអញ្ជើញឱ្យមកចូលរួមនោះក៏មិនត្រូវបានគេប្រាប់អស់ពីពេលវេលាដែលត្រូវធ្វើការពិគ្រោះយោបល់ដែរ នេះជាហេតុនាំឱ្យមានការចូលរួមតិចពីពួកគេ ។ ទោះបីមាន ឬមិនមានការពិគ្រោះយោបល់ក្តី ការកែប្រែលើគោលនយោបាយជលផលហាក់ដូចជាមិនមាន ។

- **អ្នកតស៊ូមតិបង្កើតជាសម្ព័ន្ធមួយ**

ជាការឆ្លើយតបទៅនឹងការខកចិត្ត និងទំនាក់ទំនងដែលចុះខ្សោយជាមួយនាយកដ្ឋានជលផលកាន់តែពិបាក

សម្រាប់អ្នកតស៊ូមតិក្នុងការបង្កើតបណ្តាញមួយដែលហៅថាក្រុមសម្ព័ន្ធសកម្មភាពផ្នែកជលផល (FACT) ដែលបានធ្វើការប្រជុំប្រចាំខែនៅភ្នំពេញ ហើយដើរតួជាមធ្យោបាយមួយផ្សេងទៀតសម្រាប់ធ្វើការចរចារក្រៅពីវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ។ ការរៀបចំជាបណ្តាញបែបនេះជួយធ្វើឱ្យមានការសម្របសម្រួលការងារកាន់តែល្អរវាងក្រុមដែលមានការចាប់អារម្មណ៍ ហើយធ្វើឱ្យពួកគេចូលរួមកាន់តែមានប្រសិទ្ធភាពនៅក្នុងយុទ្ធនាការតស៊ូមតិ ។

## យុទ្ធនាការតស៊ូមតិ

- **ការរៀបចំបណ្តាញការងារ**

ការបង្កើត **FACT** និងអង្គការដែលជាក្រុមចាប់អារម្មណ៍លើបញ្ហានេសាទរបស់វេទិកាសេរី បានបង្ហាញពីភាពចាំបាច់នៃបណ្តាញដ៏មានប្រសិទ្ធភាពរវាងសហគមន៍មូលដ្ឋាន សង្គមស៊ីវិល និងរដ្ឋាភិបាល ។ ពេលចាប់ផ្តើមនៃដំណើរការតស៊ូមតិមានយុទ្ធនាការសិក្ខាសាលាសារធារណៈជាច្រើនដែលបានរៀបចំដោយគ្មានការសម្របសម្រួលគ្នា និងមិនបានបញ្ចូលគ្រប់អ្នកពាក់ព័ន្ធ ទង្វើនេះបានធ្វើឱ្យមានការលំបាកដើម្បីបង្កើតឱ្យមានចលនាតស៊ូមតិមួយដ៏ពិតប្រាកដ ។ ដើម្បីបង្កើតផែនការការងារនិងយកវាទៅអនុវត្តបាន ទាល់តែបុគ្គលគ្រប់រូបចូលរួមនៅក្នុងដំណើរការនិងប្រកបដោយឆន្ទៈ ។ បើសិនជានរណាម្នាក់ក្នុងចំណោមអ្នកពាក់ពន្ធ័ទាំងនេះមិនមានឱកាសផ្តល់អនុសាសន៍នៅក្នុងការកំណត់ពីគោលបំណង ឬការធ្វើផែនការទេនោះ គេអាចនឹងមិនយល់ស្របគ្នាលើយុទ្ធនាការដែលត្រូវធ្វើ ។ បណ្តាញអាចជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុតដើម្បីធានាថាសម្លេងទាំងអស់ត្រូវបានគេស្តាប់ ។ ដំណើរការចងក្រងជាបណ្តាញមិនមែនតែងតែងាយស្រួលនោះទេ។ គេត្រូវធ្វើការបែងចែកការងារមួយឱ្យមានប្រសិទ្ធិភាពរវាងអង្គការនិងភាពស្មុកស្មាញ ដែលនឹងកើតមានឡើងនៅពេលពួកគេខិតខំប្រឹងធ្វើការសម្របសម្រួលរវាងក្រុមផ្សេងគ្នា ។

- **សកម្មភាពដោយផ្ទាល់របស់សហគមន៍**

ផ្ទុយទៅនឹងការសន្និដ្ឋានអំពីសកម្មភាពដោយផ្ទាល់ករណីជលផលបង្ហាញថា សហគមន៍ដែលគាំទ្រច្បាប់ទម្លាប់ជាជាងការមិនគោរពតាមច្បាប់ ។ ជាធម្មតាសកម្មភាពដោយផ្ទាល់ត្រូវបានគេគិតថាជាការមិនគោរពច្បាប់នៅក្នុងលក្ខណៈខ្លះ តាមការពិភាក្សាទៅលើករណីនេះឃើញថាផ្ទុយពីការគិត ។ ដូចនេះបាតុកម្មដែលមានការរៀបចំនិងយុទ្ធនាការសរសេរជាលិខិត ប្រហែលជាមិនសូវមានប្រសិទ្ធិភាពដូចការសម្រេចចិត្តរបស់សហគមន៍នៅក្នុងការអនុវត្តច្បាប់ដែលពួកគេត្រូវការដោយខ្លួនឯង អ្នកតស៊ូមតិបានធ្វើសារទៅរដ្ឋាភិបាលសំដែងពីភាពចាំបាច់ត្រូវរក្សានីតិវិធីច្បាប់ ។ ករណីជលផលគឺស្ថិតនៅក្នុងចំណោមករណីដំបូងៗដែលនៅក្នុងនោះអង្គការមិនមែនរដ្ឋាភិបាលធ្វើការដោយផ្ទាល់ជាមួយនិងសហគមន៍ក្នុងនាមជាដៃគូ អង្គការមើលឃើញពីតម្លៃនៃសកម្មភាពរបស់សហគមន៍ហើយមិនខិតខំប្រឹងកែប្រែយុទ្ធនាការដែលកំពុងមានរបស់សហគមន៍ ។

- **ប្រព័ន្ធឃោសនា**

អង្គការមិនមែនរដ្ឋាភិបាលប្រើប្រាស់ពេលវេលាដើម្បីធ្វើដំណើរពីទីក្រុងទៅកាន់តំបន់នេសាទ ដើម្បីកសាងទំនាក់ទំនងជាមួយនិងអ្នកកាសែតដែលគេបានអញ្ជើញឱ្យរួមដំណើរជាមួយក្នុងពេលធ្វើទស្សនៈកិច្ចសិក្សា ។ អង្គការ

**បណ្តាញអាចជាមធ្យោបាយមួយដ៏មានប្រសិទ្ធភាពបំផុតដើម្បីធានាថាសម្លេងអ្នកតស៊ូមតិមានប្រសិទ្ធភាពនិងទទួលបានឱកាសដើម្បីដោះស្រាយបញ្ហា ។**

ត្រូវរក្សាការទាក់ទងនេះដោយចែកចាយរបាយការណ៍ដល់ប្រព័ន្ធឃោសនាដែលបានរួមដំណើរទស្សនៈកិច្ចជាមួយ ។

## មេរៀនដែលបានរៀនសូត្រពីយុទ្ធនាការតស៊ូមតិ

- ***សកម្មភាពដោយផ្ទាល់របស់សហគមន៍អាចមានប្រសិទ្ធភាពច្រើន***

ការតស៊ូមតិមិនមែនសុទ្ធតែត្រូវធ្វើជាមួយនិងអ្នកធ្វើគោលនយោបាយនៅថ្នាក់លើនោះទេ ។ តាមពិតទៅសកម្មភាពដែលធ្វើនៅតាមលំដាប់ថ្នាក់សហគមន៍កន្លងមកក៏មានប្រសិទ្ធភាពល្អទៅលើការរស់នៅរបស់អ្នកដែលពឹងផ្អែកលើការនេសាទច្រើនជាងការធ្វើការបញ្ចុះបញ្ចូល ឬការពិគ្រោះយោបល់នៅថ្នាក់ជាតិទៅទៀត ។ ក្នុងការរឹបអូសយកម៉ាស៊ីនបូមទឹក គ្រឿងប្រដាប់ឆក់ គ្រឿងម៉ាស៊ីន ហើយនាំយកមកកាន់នាយកដ្ឋានជលផល សហគមន៍មូលដ្ឋានបានទទួលជោគជ័យនៅក្នុងការអនុវត្តច្បាប់ ការរួបរួម និង ការផ្តល់សិទ្ធិអំណាចដល់សហគមន៍របស់គេ ហើយថែមទាំងបង្កើនលទ្ធភាពរបស់គេនៅក្នុងការនេសាទ។សហគមន៍ដែលមានការរៀបរយត្រឹមត្រូវ មានប្រសិទ្ធភាពនៅក្នុងការគ្រប់គ្រងដែននេសាទដែលរដ្ឋាភិបាលប្រគល់ឱ្យបានច្រើនជាងសហគមន៍ដែលមិនមានការរៀបរយត្រឹមត្រូវ ។ និយាយដូច្នេះមិនមែនមានន័យថា ការបញ្ចុះបញ្ចូល និង ការពិគ្រោះយោបល់មិនមានសារៈសំខាន់នោះទេ ។ ច្បាប់ជលផលដែលមានការកែប្រែត្រឹមត្រូវអាចធ្វើឱ្យសហគមន៍មូលដ្ឋានមានសិទ្ធិច្រើន ។ ផ្ទុយទៅវិញករណីជលផលនេះបង្ហាញថាដោយសារការកែទម្រង់ច្បាប់មានភាពយឺតយ៉ាវ វាត្រូវតែប្រព្រឹត្តទៅជាមួយនិងសកម្មភាពដោយផ្ទាល់នៅតាមសហគមន៍ ។ ជាញឹកញាប់ចម្លើយតបផ្នែកច្បាប់គឺងាយសម្រេចបានបើសិនជាស្ថានភាពជាក់ស្តែងមានការប្រែប្រួលទៅហើយនោះ ។ អ្នកធ្វើច្បាប់កាន់តែមានឆន្ទៈអនុម័តគោលនយោបាយ បើសិនជាការប្រែប្រួលមានរួចស្រេចទៅហើយនោះ ។

- ***បណ្តាញការងារគឺជាយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពមួយ***

ជម្លោះលើការនេសាទមិនមែនជារឿងថ្មីទេ ប៉ុន្តែការតស៊ូមតិដើម្បីសិទ្ធិនេសាទរបស់សហគមន៍គឺនៅថ្មីនៅឡើយ ។ បណ្តាញការងារ និង ការសម្របសម្រួលការងាររវាងក្រុមផ្សេងៗដែលមានការចាប់អារម្មណ៍ គឺជាការចាំបាច់នៅក្នុងការចាប់ផ្តើមយុទ្ធនាការ ហើយបានជួយច្រើននៅក្នុងការឈានទៅសម្រេចបានជោគជ័យ ។ ការធ្វើការតាមរយៈវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ហើយនិងការបង្កើត FACT អាចធ្វើឱ្យអ្នកតស៊ូមតិចូលរួមនិងសម្របសម្រួលសកម្មភាពរបស់គេ ហើយផ្ទេរការទទួលខុសត្រូវនៅក្នុងការបង្កើតយុទ្ធសាស្ត្រដែលប្រកបដោយប្រសិទ្ធផលបំផុត ។

- ***ការពិគ្រោះយោបល់នានាអាចមានប្រសិទ្ធភាពដែលមានកំណត់***

តាំងពីសកម្មភាពយុទ្ធនាការតស៊ូមតិផ្នែកជលផលបានចាប់ផ្តើមឡើងនៅក្នុងឆ្នាំ ១៩៩៩ មក អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍បានផ្តល់អនុសាសន៍ជាច្រើនទៅក្នុងគោលនយោបាយដែលកំពុងរៀបចំឡើងដោយរដ្ឋាភិបាល ។ តែជាអកុសលពង្រាងនៅក្នុងពេលថ្មីៗបំផុតនៃអនុក្រឹត្យស្តីពីសហគមន៍នេសាទ មិនបានបញ្ចូលមតិស្នើឡើងដោយសហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលឡើយ ។ ការនេះបង្ហាញឱ្យឃើញបញ្ហាពីរយ៉ាង ទីមួយអ្នកធ្វើការបញ្ចុះបញ្ចូលផ្នែកជលផលបានគិតថា ដំណើរការបញ្ចុះបញ្ចូលបាន

ជាមួយនិងសមាជិកក្រុមនេះទេ ។ ដូច្នេះអ្នកធ្វើយុទ្ធនាការគួរតែយល់ពីដំណើរការច្បាប់ ហើយតាមដានយុទ្ធនាការនេះរហូតដល់ដំណាក់កាលអនុវត្តន៍ការងារ ។ ទីពីរទោះបីមានការពិគ្រោះយោបល់ហើយក្ដី ក៏គោលនយោបាយដែលដាក់ចេញមកនោះអាចមិនស្របតាមមតិស្នើសុំទេ ។ ការធ្វើការជាមួយនិងដំណើរការនីតិបញ្ញត្តិអាចមានការយឺតយ៉ាវហើយផលប្រយោជន៍ ដែលសហគមន៍អាចទទួលមិនទាន់ពេលដែលគេចង់បាន ។ អង្គការមិនមែនរដ្ឋាភិបាលបានដឹងថាគេចាំបាច់ត្រូវជំរុញបន្តលើការងាររបស់រដ្ឋាភិបាលនៅក្នុងការបន្តភាពជិតស្និទ្ធិជាមួយនិងក្រសួងនានា ។ ស្ថាប័ននានារបស់រដ្ឋមិនចង់ឱ្យគេប្រាប់គ្រប់អ្វីៗទាំងអស់ដែលខ្លួនកំពុងតែធ្វើខុសនោះទេ ប៉ុន្តែគួរប្រាប់គេពីការប្រែប្រួលជាវិជ្ជមាននៅពេលអនាគតដែលជាប្រយោជន៍ដល់គ្រប់ភាគីទាំងអស់ដែលចូលរួម ។

- **ការកែប្រែលើគោលនយោបាយមិនមែនធានាដល់ការកែប្រែនៅក្នុងការអនុវត្តទេ**

អង្គការមិនមែនរដ្ឋាភិបាលបានដឹងថាបញ្ហាសហគមន៍នេសាទ គឺជារឿងពិបាកពីព្រោះមិនមានច្បាប់ ឬបទបញ្ជាពីមន្ត្រីថ្នាក់ខ្ពស់ដែលអាចបង្ខំឱ្យអាជ្ញាធរខេត្តដោះស្រាយជម្លោះជលផលបានទេ ។ ទោះបីអ្នកនយោបាយមានឆន្ទៈហើយក្ដី ក៏នាយកដ្ឋានជលផលមិនមានមធ្យោបាយសម្រាប់អនុវត្តន៍គោលនយោបាយទាំងនេះដែរ ដោយរួមទាំងកម្មវិធីសហគមន៍នេសាទនោះផង ។ ជម្លោះភាគច្រើនមិនត្រូវបានដោះស្រាយ ហើយទោះបីមានការអនុម័តលើអនុក្រឹត្យនៅក្នុងការកាត់បន្ថយឡូត៍នេសាទក្ដី ក៏សហគមន៍នៅតែមិនបានទទួលអ្វីច្រើនពីធនធានជលផលដែរ ។ បុគ្គលិករបស់អង្គការមិនមែនរដ្ឋាភិបាល និងសកម្មជនរបស់សហគមន៍នៅតែខ្លាចចំពោះសុវត្ថិភាពផ្ទាល់ខ្លួនរបស់គេនៅឡើយ ។

# ករណីសិក្សាទីពីរ

## ភាពក្រីក្រនៅតាមទីក្រុង ៖ សហគមន៍តាមទីក្រុងរួបរួមគ្នាដើម្បីសិទ្ធិរបស់ពួកគេ

### ភាពក្រីក្រនៅតាមទីក្រុងនិងយុទ្ធនាការតស៊ូមតិ

អ្នកក្រនៅក្នុងក្រុងភ្នំពេញដែលមានសរុបចំនួន ២០០ ០០០នាក់ ត្រូវជាមួយភាគប្រាំនៃប្រជាជនដែលរស់នៅក្នុងក្រុងភ្នំពេញ។ ពួកគេភាគច្រើនរស់នៅក្នុងភាព "អណាធិបតេយ្យ" រស់នៅតាមផ្ទះឈើដែលមិនមានសុវត្ថិភាព ឬខុសច្បាប់ ហើយច្រើនតែនៅតំបន់មានលិចទឹកជំនន់។ សាលាក្រុងច្រើនតែចាត់ទុកអ្នកទាំងនេះថា ជាឧបសគ្គចំពោះការអភិវឌ្ឍន៍ទីក្រុងហើយដេញគេឱ្យទៅរស់នៅតាមតំបន់ក្រៅក្រុងដែលមិនមានការរៀបចំបានល្អ ។ កន្លែងទាំងនេះមិនត្រឹមតែនៅឆ្ងាយពីកន្លែងធ្វើការរបស់គេប៉ុណ្ណោះទេ ថែមទាំងជាទីកន្លែងដែលគ្មានហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន និងមិនមានការការពារពីទឹកជំនន់ផង ។ នៅក្នុងល័ក្ខខ័ណ្ឌបែបនេះ សហគមន៍ភាគច្រើនត្រឡប់មករស់នៅតាមកន្លែងមិនស្របច្បាប់នៅទីក្រុងវិញក្នុងរយៈពេលមិនដល់មួយឆ្នាំកន្លះផង ។

- **ការឆ្លើយតបលើកទីមួយ យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រនៅតាមទីក្រុងឆ្នាំ១៩៩៩ [Urban Poverty Reduction Strategy (UPRS)]**

UPRSបែរចេញពីការប្រឈមដាក់គ្នារវាងអង្គការមិនមែនរដ្ឋាភិបាលនិងសាលាក្រុង ហើយធ្វើដំណើរឆ្ពោះទៅរកភាពជាដៃគូគ្នារវាងអង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល សាលាក្រុង និង សហគមន៍ដែលទទួលរងផលប៉ះពាល់។ មន្ត្រីនានាចាប់ផ្តើមមើលឃើញអង្គការមិនមែនរដ្ឋាភិបាលថាជាអង្គការមានប្រយោជន៍នៅក្នុងការងារដោះស្រាយបញ្ហាដែលគេមិនអាចដោះស្រាយចេញ។ ដោយមានការយល់ព្រមថ្មីរបស់រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាលយល់ឃើញថាវាមានភាពងាយស្រួលច្រើនដើម្បីធ្វើការឆ្ពោះទៅរកទិសដៅរបស់គេនៅក្នុងការផ្តល់សេវាដល់សហគមន៍ក្រីក្រនៅតាមទីក្រុង។

- **បរាជ័យរបស់ក្រុមប្រឹក្សាគ្រប់គ្រងការអភិវឌ្ឍន៍សហគមន៍ (CDMCs)**

ផ្នែកមួយនៃ UPRS គឺការបង្កើត CDMC ។ ក្រុមទាំងនេះត្រូវធ្វើជា "ស្ពាន" រវាងសហគមន៍ អង្គការមិនមែនរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋានតាមរយៈ មន្ទីរស្រុក ឬខ័ណ្ឌ ។ ប៉ុន្តែការចាប់ផ្តើមយឺតនៃដំណាក់កាលទីពីររបស់គម្រោងកាត់បន្ថយភាពក្រីក្រនៅក្រុងភ្នំពេញរបស់កម្មវិធីតាំងទីលំនៅនៃមនុស្សរបស់សហប្រជាជាតិ (UN-Habitat) បានធ្វើឱ្យ CDMC មិនមានការតម្រែតម្រង់ការងាររយៈពេលមួយឆ្នាំ ។ គេប្រជុំគ្នាមិនបានញឹកញាប់ ហើយមិនមានអាណត្តិច្បាស់លាស់សម្រាប់ធ្វើការងារ ។ អភិបាលខ័ណ្ឌនីមួយៗដែលតាមការបញ្ជារបស់សាលាក្រុងទទួលខុសត្រូវដោយផ្ទាល់លើការចេញសេចក្តីប្រកាស ភាគច្រើនដែលបង្គាប់ឱ្យរើទីលំនៅក្នុងខ័ណ្ឌរបស់គាត់ ហើយគាត់ក៏ជាប្រធាន CDMC ក្នុងសង្កាត់របស់ខ្លួនផងដែរ។ ករណីនេះបង្កើតឱ្យមានទំនាស់ ( Conflict of interest ) ដែលមិនទាន់ត្រូវបានដោះស្រាយឱ្យបានគ្រប់គ្រាន់នៅឡើយ។

- **អង្គការមិនមែនរដ្ឋាភិបាលហើយនិងការចងក្រងសហគមន៍**

មានអង្គការនៅតាមសហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលយ៉ាងច្រើនដែលកំពុងតែធ្វើការជាមួយនិងអ្នកក្រីក្រនៅតាមទីក្រុងនៅក្នុងប្រទេសកម្ពុជា ។ អង្គការទាំងនោះរួមមាន SUPF, URC, USG, UPWD, Khemera, CSARO, PADEK, UPDF និង ANS ។ យុទ្ធសាស្ត្រដែលអង្គការទាំងនេះយកមកប្រើក៏ប្រហាក់ប្រហែលគ្នាហើយសុទ្ធតែផ្តោតលើការផ្តល់សិទ្ធិអំណាចឱ្យដល់មេដឹកនាំសហគមន៍នៅក្នុងការដោះស្រាយបញ្ហារួម ។ អង្គការមិនមែនរដ្ឋាភិបាលថែមទាំងធ្វើការតស៊ូមតិដើម្បីការកែលំអដល់ហេដ្ឋារចនាសម្ព័ន្ធ ។ ទោះមានឬមិនមានការយល់ព្រមជាផ្លូវការក្តី អង្គការផ្សេងៗបានជួយសហគមន៍ដោយកសាងសាលារៀន និងផ្តល់សេវាអនាម័យតាមតម្រូវការ ។ ការគាបសង្កត់ជាប្រចាំរបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងទសវត្សទី ៩០ បានធ្វើឱ្យមន្ត្រីនានាមានការបន្ធូរបន្ថយ ហើយអនុញ្ញាតឱ្យមានការសាងសង់យ៉ាងហោចណាស់មានមួយករណីដែលនៅក្នុងនោះអ្នកដឹកនាំថ្នាក់ស្រុកបានជួយលើគម្រោងនេះផងដែរ ។

អង្គការមិនមែនរដ្ឋាភិបាលបានលើកទឹកចិត្ត ដល់អ្នកដឹកនាំថ្មីៗរបស់សហគមន៍គិតគូរឱ្យបានជាមុនលើការរើទីលំនៅ ។ ដោយកំណត់បានពីកន្លែងតាំងទីលំនៅថ្មីសហគមន៍បាននិយាយជាមួយនិងសាលាក្រុងស្តីពីការផ្គត់ផ្គង់របស់សាលាក្រុងនៅពេលដែលទីកន្លែងរស់នៅថ្មីបានស្នើឡើងដោយរដ្ឋាភិបាលមានលក្ខណៈមិនគ្រប់គ្រាន់ ។ ទោះបីជាអង្គការមិនមែនរដ្ឋាភិបាលខិតខំរកកន្លែងរស់នៅថ្មីដែលល្អក្តី សហគមន៍ភាគច្រើននៅតែជ្រើសរើសការរស់នៅតាមសំណង់អាណាធិបតេយ្យ ព្រោះកន្លែងថ្មីស្ថិតនៅឆ្ងាយពីទីក្រុងពេកសម្រាប់អ្នកដែលធ្វើដំណើរមកធ្វើការក្នុងទីក្រុង ។

អង្គការជាក់លាក់មួយចំនួននិងយុទ្ធសាស្ត្រនានារបស់គេរួមមាន ៖

- **កម្មវិធីតាំងទីលំនៅសម្រាប់មនុស្សរបស់អង្គការសហប្រជាជាតិ (UN-Habitat)**

UN-Habitat បានមកធ្វើការនៅក្នុងប្រទេសកម្ពុជាតាំងពីឆ្នាំ ១៩៩៥ មកម្ល៉េះ ។ យុទ្ធសាស្ត្ររបស់គេគឺផ្តល់ថវិកានិងចងក្រងសកម្មភាពអភិវឌ្ឍន៍របស់សហគមន៍និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដោយជួយគេនៅក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធដែលសហគមន៍អ្នករស់នៅក្នុងសំណង់អាណាធិបតេយ្យត្រូវការ ។ ក្នុងពេលថ្មីៗនេះចំណុចគួរយកចិត្តទុកដាក់របស់គេគឺ បែរទៅរកគោលការណ៍ណែនាំលើការតាំងទីលំនៅជាថ្មី បើទោះបីជាគេមានផែនការផ្ទេរការងារនេះទៅឱ្យរដ្ឋាភិបាលនៅត្រឹមខែកក្កដាឆ្នាំ២០០៣ក្តី ។

- **សម្ព័ន្ធភាពអាស៊ីដើម្បីសិទ្ធិមានផ្ទះសម្បែង (ACHR)**

បណ្តាញ ACHR រួមមានអង្គការនៅតាម សហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាលដែលអាចប្រើប្រាស់ ម្លប់របស់ ACHR អន្តរជាតិ (ACHR Umbrella) ដើម្បីធ្វើការតស៊ូមតិឱ្យមានការផ្លាស់ប្តូរលើគោលនយោបាយរបស់រដ្ឋាភិបាល ។ ការងាររបស់គេនៅក្នុងប្រទេសអាស៊ីដទៃទៀតក៏ផ្តល់ផងដែរនូវឧទាហរណ៍ដ៏មានប្រយោជន៍ប្រហាក់ប្រហែលគ្នានេះសម្រាប់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងស្រុក ។ ACHR លើកទឹកចិត្តឱ្យធ្វើតាមវិធីរបស់ "ក្រុមសន្សំប្រាក់" ដោយលើកឡើងថាបើសិនជាក្រុមសន្សំដែលរឹងមាំនៅតាមសហគមន៍ចាក់ឫសនោះ សហគមន៍ក្លាយទៅជាមានការចងបាច់ជាមួយគ្នាបានយ៉ាងរឹងមាំហើយអាចធ្វើការនៅក្នុងទម្រង់មួយដែលមានការរួបរួមគ្នាល្អ ។

- **មូលនិធិអភិវឌ្ឍន៍ជនក្រីក្រក្នុងទីក្រុង (UPDF)**

ត្រូវបានបង្កើតឡើងដោយ ACHR សហព័ន្ធសាមគ្គីដើម្បីជនក្រីក្រនៅតាមទីក្រុង (SUPF) និង សាលាក្រុង។ UPDF បានធ្វើការចាប់តាំងពីឆ្នាំ ១៩៩៨ មកដើម្បីផ្តល់កម្ចីសមល្មមដល់អ្នកក្រីក្រនៅតាមទីក្រុងដែលត្រូវបានគេបង្ខំឱ្យរើទីលំនៅ ។ ក្នុងការងារជាមួយនិងម្ចាស់ជំនួយ មន្ត្រីសាលាក្រុង សមាជិកសហគមន៍មូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាលធ្វើការរួមគ្នា UPDF មានបំណងធ្វើជាតំណាងឱ្យភាគីទាំងអស់ដែលមានការពាក់ព័ន្ធ ។ កម្ចីដែលត្រូវបានសម្រាប់យកទៅប្រកបការងាររកចំណូល ជាទូទៅទទួលបានជោគជ័យ។ ទោះជាយ៉ាងណាក៏ដោយ UPDF មានបញ្ហានៅក្នុងការទារមកវិញនូវកម្ចីសម្រាប់ សង់ផ្ទះសម្បែង គឺកម្ចីត្រូវបានផ្តល់ទៅឱ្យគ្រួសារដែលត្រូវបានគេបង្ខំឱ្យរើទីលំនៅ ។ សហគមន៍គិតថាគេមិនគួរត្រូវសងប្រាក់ខ្ចីវិញទេ ពីព្រោះគេមិនយល់ស្របលើការរើទីលំនៅ នោះ ។

## អគ្គីភ័យនៅតំបន់ទន្លេបាសាក់

អគ្គីភ័យចំនួនពីរដងដែលកើតឡើងនៅ ខែ ឧសភា និង ខែ ធ្នូ ឆ្នាំ ២០០១ ធ្វើឱ្យគេមានការចាប់អារម្មណ៍លើបញ្ហានៃការរស់នៅរបស់មនុស្សនៅតាមសំណង់អណាធិបតេយ្យ ។ ដោយសារផ្ទះទាំងអស់ត្រូវបានសង់ជាប់ៗគ្នា ប្រកបដោយគ្រោះថ្នាក់ហើយធ្វើអំពីឈើ ដូច្នេះអគ្គីភ័យឆាបឆេះលឿនណាស់ធ្វើឱ្យមនុស្សចំនួន២ម៉ឺននាក់គ្មានផ្ទះសម្បែង ។ ក្រោយពីមានអគ្គីភ័យភ្លាម អង្គការ USG និងអង្គការដទៃទៀតបានទៅចែកជំនួយនៅនឹងកន្លែង។ សាលាក្រុងបានឆ្លើយតបដោយមិនអនុញ្ញាតិឱ្យអង្គការមិនមែនរដ្ឋាភិបាលចែកអំណោយសង្គ្រោះនៅកន្លែងណាផ្សេងពីទីតាំងលំនៅថ្មីជាផ្លូវការនោះទេ ។ អង្គការមិនមែនរដ្ឋាភិបាលធ្វើតាមការដាក់កំហិតបែបនេះ ដោយគិតថាវាជាវិធីតែមួយគត់ដើម្បីធ្វើឱ្យជនរងគ្រោះអាចទទួលជំនួយបាន ។ ការនេះបង្កើតឱ្យមានបញ្ហាក្រោយពីមានអគ្គីភ័យមួយទៀតកើតឡើងនៅក្នុងខែធ្នូ ។ កាលពីមុនអង្គការមិនមែនរដ្ឋាភិបាលគោរពតាមការខិតខំរបស់រដ្ឋាភិបាលលើការរើទីលំនៅ ហើយគិតថាខ្លួនមិនមានជម្រើសណាផ្សេងទេ គឺត្រូវតែធ្វើតាមម្តងទៀត ។UN-Habitat ក៏បានជួយផងដែរលើការរៀបចំទីតាំងរស់នៅថ្មី ទីមួយសម្រាប់ជនរងគ្រោះ ដែលជាការធ្វើឱ្យរដ្ឋាភិបាលរឹតតែពង្រឹងគោលនយោបាយរបស់ខ្លួន ។ អង្គការមិនមែនរដ្ឋាភិបាល ខិតខំប្រើប្រាស់រឿងអគ្គីភ័យដើម្បីទាក់ទាញការយកចិត្តទុកដាក់ពីប្រព័ន្ធឃោសនាចំពោះបញ្ហារបស់អ្នកក្រីក្រនៅតាមទីក្រុង តែសន្និសីទកាសែតមិនបានទទួលជោគជ័យទេនៅក្នុងការធ្វើឱ្យគេមានការផ្តោតការយកចិត្តទុកដាក់មកលើបញ្ហានោះ ។

## ការសហការគ្នារបស់អង្គការមិនមែនរដ្ឋាភិបាលនិងការពង្រីកផ្លូវជាតិលេខ១

ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានធ្វើការពង្រីកផ្លូវជាតិលេខ ១ ដោយថែងថាអ្នកដែលត្រូវរើទីលំនៅនឹងត្រូវទទួលបានសំណងទូទាត់។ ADBសុំឱ្យមានអ្នកតាមដានឯករាជ្យមួយទៅលើគម្រោង ហើយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលក៏បានបង្កើតក្រុមអង្គការមិនមែនរដ្ឋាភិបាលសម្រាប់ធ្វើការតាមដាន។ ពីដំបូងអង្គការមិនមែនរដ្ឋាភិបាលមិនធ្លាប់ធ្វើការជាមួយគ្នាទេហើយមានការពិបាកនៅក្នុងការសម្របទៅតាមសម្ព័ន្ធយុទ្ធនាការដែលចងជាបណ្តាញ ។ គេត្រូវរៀបចំយុទ្ធសាស្ត្ររបស់គេឡើងវិញដើម្បីឱ្យអង្គការនីមួយៗមានចំណែកនៅក្នុងយុទ្ធនាការទាំងមូលជាជាងបង្កើតឱ្យមានជាកម្មវិធីតូចៗដាច់ៗពីគ្នា ។ ក្នុងលក្ខណៈជាក្រុមមួយដែលមានការសហការគ្នា អង្គការមិនមែនរដ្ឋាភិបាល



ខាងឆ្វេង : ការខូចខាតដោយអគ្គីភ័យនៅថ្ងៃទី ២៦ ខែ មិនា ឆ្នាំ ២០០២ នៅបូ្លកតាន់ប៉ា



ការចរចារបស់គណៈកម្មការសហគមន៍ជាមួយអាជ្ញាធរ ដើម្បីធានាឱ្យមានទីតាំងលំនៅឡើងវិញ មានភាពសមរម្យដែលត្រូវបានជ្រើសរើសយោងតាមលក្ខណៈវិនិច្ឆ័យរបស់សហគមន៍ ។

ទាំងនោះបានរៀបចំការទាមទារមួយដោយសុំឱ្យមានគោលនយោបាយច្បាស់លាស់មួយស្តីពីការរើទីលំនៅ ។ សាលាក្រុងបានចូលរួមនៅក្នុងសន្និសីទរបស់អង្គការទាំងនោះនៅខែ សីហា ឆ្នាំ ២០០១ ស្តីពីបញ្ហានេះ ប៉ុន្តែគេនៅមិនទាន់ឆ្លើយតបលើការទាមទាររបស់អង្គការមិនមែនរដ្ឋាភិបាល និង ADB ដែលសុំឱ្យមានគោលនយោបាយថ្នាក់ជាតិមួយស្តីពីការរើទីលំនៅ ។

## ការអភិវឌ្ឍន៍ជាវិជ្ជមានក្រោយពេលមានអគ្គីភ័យនៅប្លុកតាន់ប៉ា

នៅថ្ងៃទី ២៦ ខែមិនា ឆ្នាំ២០០២ សហគមន៏មួយដែលរស់នៅលើដីបូលប្លុកតាន់ប៉ាត្រូវបានភ្លើងឆេះ ហើយមនុស្សចំនួន៣០០គ្រួសារត្រូវជម្លៀសចេញ ។ នៅពេលនោះសាលាក្រុងបានអនុវត្តន៏នយោបាយពីមុនរបស់គេ ដោយបង្ខំឱ្យធ្វើការរើទៅនៅកន្លែងផ្សេង ។ សំណាងល្អអង្គការ UNDP នៅពេលនោះកំពុងតែពិនិត្យមើលឡើងវិញនូវការផ្តល់ថវិកាសម្រាប់យុទ្ធសាស្ត្រ UPRS ហើយអង្គការមិនមែនរដ្ឋាភិបាលអាចប្រើប្រាស់ឥទ្ធិពលនេះ ដើម្បីជំរុញរដ្ឋាភិបាលឱ្យរងចាំ ។ អង្គការបានធ្វើឱ្យមានការយកចិត្តទុកដាក់តាមរយៈប្រព័ន្ធឃោសនា ហើយទូរស័ព្ទជាច្រើនសារទៅកាន់សាលាក្រុងដើម្បីបន្ថែមការគាបសង្កត់របស់ម្ចាស់ជំនួយ ។ ទីជម្រកបណ្តោះអាសន្នត្រូវបានសង់ឡើងដរាបណារកបានកន្លែងសមស្របមួយដែលសហគមន៏នោះព្រមរើទៅនៅ ។ រយៈពេលរងចាំនេះបានបន្ធូរបន្ថយភាពតានតឹងរវាងសហគមន៏ និង រដ្ឋាភិបាល ហើយធ្វើឱ្យអង្គការមិនមែនរដ្ឋាភិបាលអាចគ្រោងផែនការបានសមស្របលើទីតាំងថ្មីនោះ ដោយធ្វើឱ្យមានហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ។ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការនៅតាមសហគមន៏ អាចប្រើប្រាស់បទពិសោធន៏ល្អនេះធ្វើជាគំរូមួយទុកសម្រាប់ដោះស្រាយជាមួយនិងរដ្ឋាភិបាល លើរឿងបណ្តេញមនុស្សចេញនៅពេលអនាគត ។

## យុទ្ធសាស្ត្រនៅក្នុងការតស៊ូមតិ

- **ការចងក្រងសហគមន៍**

ការចងក្រងសហគមន៍គឺជាយុទ្ធសាស្ត្រយ៉ាងសំខាន់ដែលបានប្រើប្រាស់ដោយអង្គការមិនមែនរដ្ឋាភិបាលជាច្រើនដោយធ្វើការលើរឿងភាពក្រីក្រនៅតាមទីក្រុង ។ ទិសដៅគឺចង់ធ្វើឱ្យមេដឹកនាំសហគមន៍ និងអាជ្ញាធរបានជួបគ្នាដើម្បីបង្កើតជាដំណោះស្រាយដែលភាគីទាំងសងខាងយល់ព្រមទៅវិញទៅមក ។ អ្នកតស៊ូមតិប្រើប្រាស់បច្ចេកទេសពីរជាសំខាន់ ចងក្រងសហគមន៍នៅជុំវិញការព្រួយបារម្ភ ឬបញ្ហា និងបង្កើតក្រុមសន្សំប្រាក់ដើម្បីលើកទឹកចិត្តឱ្យមានការចេះរួបរួមគ្នា ។ បច្ចេកទេសទាំងពីរនេះមានប្រសិទ្ធភាពនៅក្នុងការធ្វើឱ្យសហគមន៍បានចូលរួមគ្រប់ជំហានទាំងអស់នៃដំណើរការ ដើម្បីឱ្យគេគិតថាលទ្ធផលគឺជាជម្រើសរបស់គេជាជាងជម្រើសរបស់ស្ថាប័នខាងក្រៅ ។

- **ការបញ្ចុះបញ្ចូល**

អង្គការមិនមែនរដ្ឋាភិបាលភាគច្រើនគិតថាមានប្រសិទ្ធភាពខ្លាំងជាង បើគេធ្វើការបញ្ចុះបញ្ចូលមន្ត្រីមូលដ្ឋានជាជាងមន្ត្រីថ្នាក់ខ្ពស់ ។ ដូច្នេះគេផ្តោតការយកចិត្តទុកដាក់របស់គេទៅលើមន្ត្រីរាជការនៅនឹងមូលដ្ឋាន និងអាជ្ញាធរស្រុក ។ អង្គការមិនមែនរដ្ឋាភិបាលប្រើប្រាស់ការប្រជុំប្រចាំសប្តាហ៍របស់ UN-Habitat ជាមួយនិងផ្នែកទទួលបន្ទុកលើការកាត់បន្ថយភាពក្រីក្រនៅតាមទីក្រុងរបស់សាលាក្រុងភ្នំពេញដើម្បីធ្វើការបញ្ចុះបញ្ចូលលើបញ្ហាផ្សេងៗ និងចេញធ្វើការតស៊ូមតិដោយផ្ទាល់ជាមួយនិងមន្ត្រីខ័ណ្ឌនិងក្រុង ។ ទិសដៅចុងបញ្ចប់គឺផ្តល់សិទ្ធិអំណាចដល់មេដឹកនាំសហគមន៍នៅក្នុងការបន្តការងារបញ្ចុះបញ្ចូលដោយគ្មានវត្តមានរបស់អង្គការមិនមែនរដ្ឋាភិបាល ។

- **ប្រព័ន្ធឃោសនា**

អង្គការមិនមែនរដ្ឋាភិបាលមានការយឺតយ៉ាវនៅក្នុងការប្រើប្រាស់ប្រព័ន្ធឃោសនាឱ្យបានសមស្រប ។ ស្ថានភាពនៅប្លុកតាន់ប៉ា (នៅទីនោះសហគមន៍ត្រូវបានគេហាមមិនឱ្យសង់ឡើងវិញលើជម្រករបស់គេដែលត្រូវបានបំផ្លាញ) បានទាក់ទាញការយកចិត្តទុកដាក់គ្រប់គ្រាន់ដល់អ្នកកាសែតល្មមធ្វើឱ្យសាធារណៈជនមានការចាប់អារម្មណ៍ ។ ក្រោយពីមានបទពិសោធន៍ល្អបែបនេះមក អង្គការមិនមែនរដ្ឋាភិបាលបានចាប់ផ្តើមយកចិត្តទុកដាក់ទៅលើអំណាចនៃការផ្សព្វផ្សាយតាមប្រព័ន្ធឃោសនា ។ ឥឡូវនេះបុគ្គលិករបស់អង្គការមិនមែនរដ្ឋាភិបាលមានលេខទូរស័ព្ទរបស់អ្នកកាសែត ហើយតែងតែប្រាប់គេនៅពេលមានវិបត្តិអ្វីមួយកើតឡើង ។ ក្រៅពីនេះអង្គការមិនមែនរដ្ឋាភិបាលនៅមានព្រឹត្តិប័ត្រឯករាជ្យដែលបានចែកចាយទៅឱ្យសហគមន៍និងសាលាក្រុង ប៉ុន្តែដោយសារតែមានការបោះពុម្ពផ្សាយមានចំនួនតិចនោះវាមិនអាចយកធ្វើជាតំណាងឱ្យកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមទាំងឡាយនៅទីក្រុងបានឡើយ ។

## មេរៀនដែលបានរៀនសូត្រពីយុទ្ធនាការតស៊ូមតិ

- **ការផ្លាស់ប្តូរគោលនយោបាយនិងកម្មវិធី**

ទោះបីជាមានការជឿនលឿនច្រើននៅក្នុងទំនាក់ទំនងរបស់សហគមន៍នីមួយៗជាមួយនិងអាជ្ញាធរស្រុកក្តី តែចលនាការតស៊ូមតិមានទ្រង់ទ្រាយធំដើម្បីអ្នកក្រនៅតាមទីក្រុងបានឆ្លងកាត់នូវការតស៊ូដែរ ។ ទំនាក់ទំនងរវាងអ្នកតស៊ូមតិ និងមន្ត្រីរដ្ឋាភិបាលជាទូទៅមានភាពតានតឹង ។ តាំងពីឆ្នាំ ១៩៩៩ មកសាលាក្រុងកាន់តែប្រកាន់ជំហរតឹងតែងប្រឆាំងនិងការខិតខំរបស់អង្គការមិនមែនរដ្ឋាភិបាល ហើយស្ថានភាពដូចជាការរើទីលំនៅជាថ្មីក្រោយមានអគ្គីភ័យនៅឆ្នាំ ២០០១ បង្ហាញពីការមិនមានឆន្ទៈធ្វើការសម្រុះ

សម្រួល ។ ការមិនទទួលជោគជ័យលើការរៀបចំគោលនយោបាយសម្រាប់រយៈពេលយូរអង្វែង ដែលជាការបង្ខំឱ្យបញ្ហានេះត្រូវបានពិនិត្យដោះស្រាយទៅតាមករណីមួយៗដោយឡែកៗ ហើយធ្វើឱ្យសហគមន៍មិនមានឱកាសរួបរួមគ្នាដើម្បីបង្កើនកំលាំងនៅក្នុងការតស៊ូមតិ ។

- **កសាងសមត្ថភាពរបស់អង្គការនៅតាមមូលដ្ឋាន និង អង្គការមិនមែនរដ្ឋាភិបាល**

ក្រុមនានានៅក្នុងមូលដ្ឋានបានទទួលអត្ថប្រយោជន៍ពីការធ្វើទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក ដោយប្រើប្រាស់បណ្តាញរបស់គេដើម្បីរៀនសូត្រពីដំណោះស្រាយផ្សេងទៀតចំពោះបញ្ហារួម ។ សមាជិកសហគមន៍ក៏ត្រូវបានគេបង្រៀនដែរថា ការប្រឹងប្រែងរួមគ្នាមានប្រសិទ្ធភាពជាងយុទ្ធនាការដែលធ្វើទៅមិនស្រុះគ្នា ។ ទោះបីយ៉ាងណាក៏ដោយ អង្គការមិនមែនរដ្ឋាភិបាលភាគច្រើននៅតែមើលឃើញថា តំបន់ភូមិសាស្ត្រគឺជាលក្ខណៈកំណត់របស់សហគមន៍ ដូច្នេះគេមិនធ្វើការតស៊ូមតិដើម្បីបញ្ហារួមដែលសហគមន៍ផ្សេងៗអាចមានការពាក់ព័ន្ធគ្នាឡើយ ។ កម្មវិធីដូចជា កម្មវិធីស្តីពីសិទ្ធិលើផ្លូវច្បាប់ និងសិទ្ធិនារីរបស់អង្គការ USG មានបទពិសោធន៍ទទួលជោគជ័យគ្រប់គ្រាន់ជាមួយនិងកម្មវិធីជួបអ្នកលក់ដូរតូចតាចដើម្បីបង្ហាញថាការតស៊ូមតិដែលផ្តោតទៅលើបញ្ហាមួយ មានប្រសិទ្ធភាពជាងការតស៊ូមតិដែលផ្តោតលើតំបន់ភូមិសាស្ត្រ ។ ដូច្នេះអ្នកតស៊ូមតិដើម្បីអ្នកក្រីក្រនៅតាមទីក្រុងគួរតែចាប់ផ្តើមសម្របសម្រួលយុទ្ធសាស្ត្ររបស់គេដើម្បីបញ្ចូលឱ្យបានច្រើននូវអ្នកក្រីក្រនៅតាមទីក្រុងដែលទទួលការប៉ះពាល់ ។

- **បណ្តាញការងារ**

ទោះបីជាការងាររបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីការពង្រីកផ្លូវជាតិលេខ ១ ត្រូវបានគេមើលឃើញថាបានទទួលជោគជ័យដោយសារមានការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលច្រើនក្តី តែជាទូទៅគេមានការសម្របសម្រួលការងារតិចតួច ។ នៅក្នុងចំណោមក្រុមបណ្តាញការងារ គេបានដាក់ចេញនូវគោលបំណងតស៊ូមតិជាក់លាក់តិចតួចដែលត្រូវកំណត់ ហើយថែមទាំងគោលបំណងជាក់លាក់ទាំងនោះមិនច្បាស់លាស់ទៀតផង ។ ការប្រជុំរបស់ក្រុមការងារត្រូវបានគេមើលឃើញថាមិនសូវមានប្រយោជន៍ ដោយមិនមានចេញសកម្មភាពអ្វីក្រៅពីការពិភាក្សាទេ ។ អង្គការមិនមែនរដ្ឋាភិបាលនីមួយៗគួរតែប្រើប្រាស់ភាពដូចគ្នានៃយុទ្ធនាការតស៊ូមតិ ដើម្បីរួមបញ្ចូលការខិតខំប្រឹងប្រែងរបស់គេ ។ គួរឱ្យស្តាយ អង្គការមិនមែនរដ្ឋាភិបាលច្រើនតែគិតគូរតែនៅតំបន់តូចៗដោយមិនដឹងពីជោគជ័យ ឬបរាជ័យរបស់សហគមន៍នៅក្បែរខាងទេ ។ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការនៅតាមសហគមន៍គួរតែមើលឃើញពីចំណុចខ្លាំងនិងចំណុចខ្សោយរបស់គេផ្ទាល់ ហើយផ្តោតទៅលើយុទ្ធសាស្ត្រខ្លះដែលឆ្លើយតបបានល្អទៅនឹងអ្វីដែលគេធ្វើ ហើយមានដំណើរការល្អ។ ឧទាហរណ៍ ក្រុមដែលមានសមាជិកច្រើនមានបុគ្គលិកជំនាញបច្ចេកទេសអាចជួយបង្កើតហេដ្ឋារចនាសម្ព័ន្ធ ហើយជួយបណ្តុះបណ្តាលសមាជិកសហគមន៍ ចំណែកឯក្រុមដែលមានជំនាញច្បាស់លាស់លើការតស៊ូមតិអាចធ្វើការលើផ្នែកនយោបាយ ។ ការបែងចែកការងាររបៀបនេះនឹងជួយឱ្យក្រុមមានអ្នកផ្តល់ជំនួយ ដោយមិនចាំបាច់ទៅប្រកួតប្រជែងគ្នារកជំនួយសម្រាប់កិច្ចការប្រហាក់ប្រហែលគ្នានោះទេ ។

# ឧបសម្ព័ន្ធ ក : សេចក្តីប្រកាសព័ត៌មាន និង ប្រភពព័ត៌មាន

គោលបំណងនៃសេចក្តីប្រកាសពត៌មានគឺចង់ជម្រាបសារពត៌មានពីព្រឹត្តិការណ៍ ឬបញ្ហាអ្វីមួយតាមរយៈពាក្យពេជន៏សំខាន់ៗដែលអាចធ្វើទៅបាន ។ សម្រាប់ប្រទេសកម្ពុជាអ្នកត្រូវផ្ញើច្បាប់ចម្លងទាំងឡាយទៅកាន់សារពត៌មានជាភាសាខ្មែរ ឬអង់គ្លេស អាស្រ័យទៅតាមសារពត៌មាននោះ ។ សេចក្តីប្រកាសពត៌មានគួរមាន :

- មិនលើសពីមួយទំព័រ
- មានពត៌មានទាំងអស់ទាក់ទងនឹងព្រឹត្តិការណ៍ឬបញ្ហា អ្នកណា អ្វី នៅពេលណា (ទាំងម៉ោងទាំងថ្ងៃខែ) ទីកន្លែងណា និង ហេតុអ្វីក៏វាមានសារៈសំខាន់ ។
- មានចំណងជើងដែលបញ្ជាក់យ៉ាងខ្លីនិងលំអិតពីហេតុផលដែលសារពត៌មានធ្វើឱ្យមានការចាប់អារម្មណ៍("មានមនុស្សក្រីក្រនៅភ្នំពេញ" ចំណងជើងនេះមិនធ្វើឱ្យប្រព័ន្ធឃោសនាមានការចាប់អារម្មណ៍ច្រើនដូចចំណងជើងថា "ភាពក្រីក្រនៅតាមទីក្រុងធ្វើឱ្យអត្រាអ្នកកើតជំងឺអេដស៍ឡើងខ្ពស់" នោះទេ) ។
- គូសបញ្ជាក់លើចំណុចសំខាន់ៗ ដោយសរសេរអក្សរឱ្យដិតខ្លាំង ឬធ្វើយ៉ាងណាឱ្យមានលក្ខណៈលេចខុសពីអក្សរដទៃទៀត ។
- ផ្តល់ពត៌មានច្បាស់លាស់សម្រាប់ធ្វើការទាក់ទងដល់នរណាម្នាក់ដែលដឹងច្បាស់ពីបញ្ហាដោយរួមទាំងលេខទូរស័ព្ទ និងភាសាដែលចេះ ។

ការណែនាំខ្លះៗដទៃទៀតដែលអ្នកគួរចាំទុកនៅក្នុងចិត្ត :

- កុំបញ្ជូនសេចក្តីប្រកាសពត៌មានច្រើនពេកទៅកាន់មនុស្សដដែលៗ ។ ប្រសិនបើអ្នកចាប់ផ្តើមផ្ញើចំនួន ៤ ឬ ៥ ក្នុងមួយអាទិត្យ នោះនឹងមិនមានអ្នកមើលទេ ។ ផ្ញើសេចក្តីប្រកាសពត៌មាននៅពេលណាដែលមានហេតុផលច្បាស់លាស់នៅក្នុងការជម្រាបឱ្យគេដឹង ពោលគឺរង់ចាំព្រឹត្តិការណ៍មួយដែលប្រព័ន្ធឃោសនាអាចផ្តោតការយកចិត្តទុកដាក់ទៅលើ ។
- ចូរផ្ញើសេចក្តីប្រកាសពត៌មានជាមុន (យ៉ាងហោចណាស់ ៤-៥ ថ្ងៃមុន) តែកុំឱ្យមុនយូរពេករហូតនាំឱ្យគេភ្លេច ។ ការ រំលឹកមុនមួយថ្ងៃ ឬ ក្នុងថ្ងៃព្រឹត្តិការណ៍ក៏ជាការល្អដែរ ។ ចូរចាំថាកាសែតមិនមែនចេះតែចេញរាល់ថ្ងៃនោះទេ ។ ពេលខ្លះអ្នកត្រូវផ្ញើសេចក្តីផ្សាយនោះទៅដល់កាសែតឱ្យបានមុនពេល ដើម្បីគេអាចយកវាទៅចុះនៅក្នុងកាសែតរបស់គេ ហើយឱ្យគេផ្សាយមុនពេលព្រឹត្តការណ៍របស់អ្នក ។ យកល្អអ្នកគួរតែកំណត់ពេលវេលានៃការរៀបចំរបស់អ្នក ឱ្យត្រូវនឹងថ្ងៃខែរបស់កាសែតខ្មែរធំៗ ។
- មិនត្រូវផ្សាយតែតាមកាសែតខ្មែរប៉ុណ្ណោះទេ ចូរផ្ញើពត៌មានទាំងនោះតាមប្រព័ន្ធអេឡិចត្រូនិច ដែលភាគច្រើនពួកគេមានការិយាល័យនៅទីនេះ ។
- អ្នកអាចសុំឱ្យកាសែតរង់ចាំចុះផ្សាយពត៌មាន បើអ្នកចង់ផ្ញើសេចក្តីប្រកាសពត៌មានទៅបានឆាប់ដើម្បីធ្វើការសម្របសម្រួលលើការចាប់អារម្មណ៍របស់ប្រព័ន្ធឃោសនា និងសម្របសម្រួលព្រឹត្តិការណ៍ដែលរៀបចំពិសេសណាមួយ ។ នៅប្រទេសកម្ពុជា អ្នកអាចសុំឱ្យការសែត Cambodia Daily រង់ចាំរហូតដល់ថ្ងៃសុក្រដើម្បីអាចឱ្យសេចក្តីប្រកាសនោះត្រូវបានយកទៅចុះផ្សាយនៅក្នុងកាសែត Cambodia Daily និង Phnom Penh Post នៅថ្ងៃជាមួយគ្នា ។

- អ្នកអាចដកស្រង់សម្តីរបស់អ្នកឯកទេស នៅក្នុងសេចក្តីប្រកាសពត៌មានរបស់អ្នក ដែលបង្ហាញពីភាពមានមានទំនាក់ទំនងនៃបញ្ហា ព្រមទាំងប្រាប់ទៅឱ្យអ្នកកាសែតដឹងពីអ្នកដែលត្រូវធ្វើការសម្ភាសជាមួយ ។ អ្នកយកពត៌មានល្អមិនមែនគ្រាន់តែទទួលយកសេចក្តីដកស្រង់សេចក្តីប្រកាសពត៌មានរបស់អ្នកដោយមិនផ្ទៀងផ្ទាត់ប្រភពរបស់វានោះទេ ។ អ្នកសារពត៌មាននិងស្វែងរកមនុស្សដែលអ្នកចង់ឱ្យគេរាយការណ៍អំពីស្ថានការណ៍ ។

ខាងក្រោមនេះគឺជាសេចក្តីប្រកាសពត៌មានបីជាគំរូ ។ គំរូពីរដំបូងគឺជាសេចក្តីប្រកាសពត៌មានដែលល្អធ្វើតាមការណែនាំដូចដែលនិយាយមកខាងលើ ។ សេចក្តីប្រកាសពត៌មានចុងក្រោយបង្ហាញពីសេចក្តីប្រកាសពត៌មានដែលមិនល្អ ។



លោក សុខ សំអឿន ឆ្លើយសំនួររបស់អ្នកយកពត៌មានបន្ទាប់ពីសន្និសិទ្ទកាសែត

# គំរូនៃសេចក្តីប្រកាសពត៌មានដើម្បីជម្រាបអំពីព្រឹត្តការណ៍

ផ្លាកសញ្ញាអង្គការរបស់អ្នក

ទីកន្លែងរបស់អង្គការ

ទូរស័ព្ទ :......................ទូរសារ :......................

អាស័យដ្ឋាននៅក្នុងវែបសៃ

## ការផ្សព្វផ្សាយពត៌មាន

(ឈ្មោះអង្គការ)

(ចំណងជើងព្រឹត្តិការណ៍) កាលបរិច្ឆេទ:........................

កម្មវត្ថុនៃសេចក្តីប្រកាសពតិមាន

## សេចក្តីពន្យល់បន្ថែមស្តីអំពីព្រឹត្តិការណ៍

**(ខ្លីហើយច្បាស់ មិនវែងជាងបួនបន្ទាត់រាប់ទាំងពត៌មានដូចជាតំបន់ដែលគ្របដណ្តប់ដោយព្រឹត្តិការណ៍និងទង្វើទាំងឡាយដែលកំពុងត្រូវបានប្រារព្ធឡើង)**

(ខែ ថ្ងៃ ឆ្នាំ)

(ទីកន្លែង)

(អ្នកសារពតិមានត្រូវបានគេអញ្ជើញដើម្បីយកពតិមាននិងថតរូបភាពផ្សេងៗ)

កថាខ័ណ្ឌដំបូងគួរតែរាយឈ្មោះអ្នកចូលរួមសំខាន់ៗដែលចូលរួមក្នុងព្រឹត្តិការណ៍ណាមួយរបស់អ្នក ។ ឧទាហរណ៍ ដូចជា: ***នាមនិងមុខនាទីសម្រាប់មន្ត្រីថ្នាក់ក្រសួង***ផ្សេងៗ និង***អ្នកមានមុខនាទីខ្ពស់*** ព្រមទាំង***មុខតំណែង*** ដែលមកពីអង្គការចាត់តាំងរបស់លោក-អ្នក និងសមាជិកផ្សេងទៀតនៃសាខាដែលនឹងមកចូលរួមនៅក្នុងព្រឹត្តិការណ៍នោះ ។

សូមនិយាយពន្យល់រៀបរាប់ឱ្យបានច្បាស់លាស់អំពីអ្នកដែលបានគាំទ្រចំពោះសកម្មភាពរបស់អ្នក ។ ប្រសិនបើអាច សូមបង្ហាញទាំងឈ្មោះស្ថាប័នផ្តល់ជំនួយទាំងឡាយ ព្រមទាំងបង្ហាញឱ្យដឹងអំពីចំនួនទឹកប្រាក់ដែលពួកគេបានចូលរួមធ្វើវិភាគទាននោះផង ។ ត្រូវបង្ហាញនូវហេតុផលឱ្យបានច្រើនហើយច្បាស់លាស់ថា តើលុយត្រូវបានយកទៅសម្រេចធ្វើអ្វីខ្លះ ។ បើអ្នកអាច គួរបង្ហាញឈ្មោះអ្នកជួយគាំទ្រផ្សេងៗទៀតនៅក្នុងគម្រោងនេះផង ។

ការពិពណ៌នាសង្ខេបរបស់អង្គការលោក-អ្នក, ដោយរួមនូវសេចក្តីថ្លែងការណ៍បេសកកម្ម, តួអង្គសំខាន់ៗ, កាលបរិច្ឆេទនៃការចាប់ផ្តើមនិងការពិពណ៌នាសង្ខេបនៃគម្រោងផ្សេងៗទៀតដែលលោក-អ្នកពាក់ព័ន្ធជាមួយ ហើយដែលគាំទ្របេសកកម្មរបស់លោក-អ្នកផងដែរ ។ ធ្វើយ៉ាងណាឱ្យកថាខ័ណ្ឌនេះខ្លី, តែវាជាឱកាសល្អសម្រាប់ជម្រាបតួអង្គដែលមានឥទ្ធិពលរបស់លោក-អ្នកឱ្យបានដឹងអំពីការងារ និងកម្លាំងបណ្តាញរបស់លោក-អ្នក ។

# គំរូសេចក្តីប្រកាស់ពត៌មាន : ការប្រកាសនូវការជួបប្រជុំ និង ការបញ្ចុះបញ្ចូលថ្នាក់មន្ត្រី

រូបសញ្ញាសំគាល់ ឬ ឈ្មោះអង្គការទាំងឡាយដែលបង្កើតបណ្តាញ

ទីតាំងរបស់អង្គការ

ទូរស័ព្ទ.......................ទូរសារ....................

អាស័យដ្ឋាននៅក្នុងវែបសៃ

## សេចក្តីប្រកាសពត៌មាន

(ឈ្មោះអង្គការទាំងឡាយដែលចូលរួម)

កាលបរិច្ឆេទ :..........................

កម្មវត្ថុនៃសេចក្តីប្រកាសពតិមាន

បណ្តាញការងារ HIV/AIDS នឹងដើរក្បួនដើម្បីប្រឆាំងនឹងកង្វះយន្តការក្នុងការទទួលថ្នាំពេទ្យ និងដាក់ស្នើនូវការទាមទារមួយចំនួនទៅក្រសួងសុខាភិបាល ។

(ថ្ងៃ, ខែ, ឆ្នាំ)

(ទីតាំងដែលដំណើរក្បួននឹងចាប់ផ្តើម និង បញ្ចប់)

បន្ទាប់ពីដំណើរក្បួនរួច, ក្រុមសកម្មជននឹងប្រមូលគ្នានៅ .................. ដើម្បីដាក់ជូននូវសំណើនៃការទាមទារនានាមួយចំនួនសំដៅទៅរកឯកឧត្តម .......................... និងមន្ត្រីរាជរដ្ឋាភិបាលសំខាន់ៗនៅទីនោះ។ នាយកអង្គការ ...................... ព្រមទាំងនាយកអង្គការ.................... និងអង្គភាព .............................................. និងអំពាវនាវ ជម្រាបមន្ត្រីថ្នាក់ខ្ពស់នានាអំពីបញ្ហាដែល បណ្តាញចង់ជួយដោះស្រាយឱ្យប្រសើរឡើង។

អង្គការ (សរសេរគ្រប់ឈ្មោះអង្គការដែលចូលរួមគាំទ្រ) រៀបចំដំណើរក្បួន, និងបញ្ចុះបញ្ចូលមន្ត្រីរដ្ឋាភិបាលដែលជាកំលាំង ស្រួចក្នុងចលនាដើម្បីនាំយកនូវបញ្ហា HIV/AIDS ដើម្បីដាក់ឱ្យទៅជាគោលនយោបាយអាទិភាពរបស់រដ្ឋាភិបាល ។ ផ្នែកសារពតិមានត្រូវបានអញ្ជើញដើម្បីចូលរួមក្នុងជំនួបរវាង NGOs និងក្រសួងនៅ............ ថ្ងៃទី............... នៅម៉ោង ......... ដើម្បីជាឱកាសក្នុងការថតរូប និង សំណួរ-ចំលើយ។

សេចក្តីពិពណ៌នាសង្ខេបរបស់អង្គការលោក-អ្នក សេចក្តីថ្លែងការបេសកកម្ម តួអង្គសំខាន់ៗ កាលបរិច្ឆេទនៃការចាប់ផ្តើម និងការពិពណ៌នាសង្ខេបនៃគម្រោងផ្សេងៗទៀតដែលលោក-អ្នកពាក់ព័ន្ធជាមួយ ហើយដែលគាំទ្របេសកកម្មរបស់ លោក-អ្នក ផងដែរ។

# ឧទាហរណ៍ ចំពោះទង្វើដែលពុំគួរធ្វើ

## ការបង្ហាញព័ត៌មានដំបូង
## ភាពក្រីក្រនៅតែជាបញ្ហាសម្រាប់ទីក្រុងភ្នំពេញ

១០ សីហា ២០០២

អ្នកជំនាញជាច្រើនមកពីអង្គការក្រៅរដ្ឋាភិបាលចំនួន ៥ នៅក្នុងស្រុកដែលបានឧទ្ទេសនាមការស្រាវជ្រាវបានផ្តល់នូវសំណើរក្នុងឱកាសសន្និសីទកាលពីពេលថ្មីៗនេះថា ភាពក្រីក្រនៅក្នុងទីក្រុងនៅតែជាបញ្ហាសម្រាប់ទីក្រុងភ្នំពេញ ។ បន្ទាប់មកពួកគេបានបង្ហាញអំពីអ្វីដែលអង្គការរបស់ពួកគេបាននិងកំពុងធ្វើលើបញ្ហា និងបានស្នើសុំបង្កើនការជួយគាំទ្រពីសំណាក់ម្ចាស់ផ្តល់ជំនួយលើសកម្មភាពទាំងនេះ ។ ពួកគេមានអារម្មណ៍ថាការស្វែងរកនូវការជួយគាំទ្រពីម្ចាស់ជំនួយគឺមានភាពងាយស្រួល ដោយសារព្រឹត្តិការណ៍ថ្មីៗនេះបានធ្វើឱ្យភាពក្រីក្រនៅទីក្រុងកាន់តែមានកំណើនឡើងចំពោះការសំគាល់ឃើញរបស់សាធារណជន ។

នៅប៉ុន្មានថ្ងៃទៀត អង្គការមិនមែនរដ្ឋាភិបាលជាច្រើននឹងមានការប្រជុំជាមួយមន្ត្រីក្នុងស្រុកមួយចំនួនដើម្បីធ្វើការពិភាក្សាអំពីសន្និសីទនិងសមិទ្ធផលស្រាវជ្រាវរបស់ពួកគេ ។ ក្រោយពីកិច្ចពិភាក្សាទាំងនេះអង្គការទាំងអស់រំពឹងថានឹងបានរៀបចំគម្រោងផែនការសកម្មភាពដែលរួមបញ្ចូលនូវការគាំទ្រនៅក្នុងស្រុក ។ លោក.......................... ប្រធានផ្នែកកម្មវិធីរបស់អង្គការក្នុងស្រុកមួយបាននិយាយថា " ការបញ្ចូលសហគមន៍ឱ្យចូលរួមគឺមានសារៈសំខាន់ណាស់ " ។ អង្គការរបស់លោក ............................ កំពុងឈានមុខគេក្នុងកិច្ចខិតខំប្រឹងប្រែងទៅលើការងារអភិវឌ្ឍន៍សហគមន៍ដើម្បីដោះស្រាយភាពក្រីក្រនៅទីក្រុង ។ ពួកគេជឿថាសហគមន៍ទាំងឡាយគួរមានសិទ្ធិជ្រើសរើសនូវទីតាំងដើម្បីតាំងទីលំនៅរបស់ពួកគេឡើងវិញ ។

ដោយសារកម្មវិធីទាំងនេះត្រូវការការគាំទ្រជាសាធារណៈ យើងចង់ឱ្យលោកមានការកត់ត្រាបញ្ហាខ្លះៗក្នុងកំណត់ត្រារបស់លោក ។

អរគុណចំពោះការគាំទ្រកន្លងមករបស់អ្នក ។

លោក ( ឈ្មោះ................................. )

**សំគាល់ :**

នេះគឺជាឧទាហរណ៍នៃសេចក្តីប្រកាសព័ត៌មានដែលគ្មានប្រសិទ្ធភាពដោយមូលហេតុមួយចំនួន ។ ទីមួយ ខ្វះនូវព័ត៌មានទាក់ទងទៅនឹងព្រឹត្តិការណ៍ ឬ សកម្មភាពជាក់លាក់ណាមួយ ។ បន្ថែមពីលើនេះទៅទៀត វាមានលក្ខណៈទូលំទូលាយពេកមិនទាក់ទាញចំណាប់អារម្មណ៍ពីសារព័ត៌មាន ឬម្ចាស់ជំនួយនោះទេ ។

# ឧបសម្ព័ន្ធ ២ : ដំណើរការតាក់តែងច្បាប់

## សេចក្តីពន្យល់ទៅលើរចនាសម្ព័ន្ធនៃដំណើរការតាក់តែងច្បាប់

**I. ធ្វើពង្រាងឬដាក់ស្នើច្បាប់**

**ក. ពង្រាងច្បាប់ដែលរៀបចំដោយផ្នែកនីតិប្រតិបត្តិ**

១. ក្រសួងដែលមានការពាក់ព័ន្ធ( ក្រុមការងារផ្នែកច្បាប់ និងនាយកដ្ឋានដែលមានការពាក់ព័ន្ធក្នុង ក្រសួង) របស់រាជរដ្ឋាភិបាលកម្ពុជាផ្តួចផ្តើមពង្រាងច្បាប់មួយជាក់លាក់ ។ ( ចំណាំ : សំណៅផ្សេងៗនៃពង្រាងច្បាប់នានា គួរត្រូវបានផ្ញើទៅវិញទៅមករវាងក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធ ( ក្រុមការងារតាក់តែងច្បាប់) ។ នៅពេលដែលពង្រាងច្បាប់ត្រូវបានធ្វើហើយ ក្រសួងដាក់ស្នើច្បាប់ដែលព្រាងមកនោះទៅឱ្យក្រុមប្រឹក្សាអង្គចៅក្រមរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី។

២. ក្រុមប្រឹក្សាអង្គចៅក្រមពិនិត្យពង្រាងច្បាប់ដែលដាក់ស្នើឡើងដោយក្រសួងដែលមានការពាក់ព័ន្ធ។ ( ចំណាំ : ពង្រាងនោះអាចត្រូវបានផ្ញើឱ្យគ្នាទៅវិញទៅមករវាងក្រុមប្រឹក្សាអង្គចៅក្រមនិងក្រសួងដែលមានការពាក់ព័ន្ធ) ។

៣. គណៈកម្មាធិការអន្តរក្រសួងពិភាក្សាលើច្បាប់ព្រាងដែលនៅក្នុងនោះប្រធាននៃស្ថាប័នដែលមានការពាក់ព័ន្ធ( ជាទូទៅរដ្ឋមន្ត្រីឬរដ្ឋលេខាធិការ) ត្រូវបានអញ្ជើញឱ្យមករាយការណ៍ពីពង្រាងច្បាប់នោះ ។

៤. ក្រុមប្រឹក្សារដ្ឋមន្ត្រីពិនិត្យឡើងវិញទៅលើពង្រាងច្បាប់ ហើយអនុម័ត ។ បន្ទាប់មកដាក់សំណើរទៅជាមួយនិងសេចក្តីបញ្ជាក់ពីមូលហេតុទៅគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភានិងតំណាងទាំងអស់ ។

**ខ. ច្បាប់ដែលស្នើឡើងដោយផ្នែកនីតិបញ្ញត្តិ (សមាជិកសភានិងសមាជិកព្រឹទ្ធសភា)**

៥. សមាជិកសភាជាតិអាចធ្វើការស្នើច្បាប់ ។ យោលទៅតាមជំពូកទី៦នៃបទបញ្ជាផ្ទៃក្នុងរបស់សភាជាតិ សមាជិកសភាម្នាក់អាចធ្វើការស្នើច្បាប់បានដែលគេហៅថាសេចក្តីស្នើ "ច្បាប់ស្នើ" ។ ច្បាប់ដែលស្នើនោះត្រូវមានសរសេរជាលាយលក្ខណ៍អក្សរបែងចែកទៅតាមមាត្រា ហើយមានភ្ជាប់មកជាមួយនូវសេចក្តីពន្យល់ពីបុព្វហេតុថាចាំបាច់ត្រូវតែមានច្បាប់នោះ។ ច្បាប់ស្នើឡើងនោះបន្ទាប់មកត្រូវបានបញ្ជូនជាបន្តទៅឱ្យគណៈកម្មការដែលមាននាទីពិនិត្យមើលច្បាប់នោះ ។ សមាជិកសភាដែលជាអ្នកស្នើច្បាប់នេះអាចរាយការណ៍ទៅគណៈកម្មការដែលមានការពាក់ព័ន្ធ។

៦. យោលទៅតាមជំពូកទី៦នៃបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា សមាជិកព្រឹទ្ធសភាអាចស្នើច្បាប់ ។ ក្រោយពីគណៈកម្មការបច្ចេកទេសធ្វើអនុសាសន៍ គណៈកម្មការអចិន្ត្រៃយ៍របស់ព្រឹទ្ធសភាផ្ញើច្បាប់ស្នើនោះទៅសភាជាតិ។

**II.ឆ្លងច្បាប់**

៧. សភាជាតិពិភាក្សាដេញដោលហើយអនុម័តលើពង្រាងច្បាប់។

៧.១ គណៈកម្មការនៃគណៈកម្មាធិការអចិន្ត្រៃយ៍ពិនិត្យមើលលើពង្រាងច្បាប់ ឬច្បាប់ស្នើ ហើយបញ្ជូនជាបន្តទៅគណៈកម្មការទទួលបន្ទុក។

៧.២ នៅពេលដែលពង្រាងច្បាប់ ធ្លាក់ទៅដល់គណៈកម្មការវដ្ឋសភាហើយ ជំហានជាបន្ទាប់មកទៀតគឺដូចគ្នា មិនថាអ្នកណាជាអ្នកធ្វើពង្រាង ឬដាក់ស្នើច្បាប់នោះទេ ។ ក្រោយពីគណៈកម្មការបានទទួលសំណើសុំ ឬពង្រាងហើយ ជំពូកទី៦នៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាផ្តល់ជម្រើសបីយ៉ាង ។ គណៈកម្មការអាច ៖

- ធ្វើអនុសាសន៍ទៅកាន់សភាទាំងមូលសូមកុំឱ្យពិចារណាលើពង្រាងច្បាប់នោះ ។
- សុំឱ្យសភាទាំងមូលសម្រេចថាតើគួរលើកយកពង្រាងច្បាប់នោះមកពិចារណាឬទេ ។
- សុំឱ្យសភាទាំងមូលពិចារណាលើពង្រាងច្បាប់ "នៅក្នុងភាពបន្ទាន់" ។

៧.៣ សភាជាតិអនុម័តលើពង្រាងច្បាប់ ហើយដាក់ស្នើទៅព្រឹទ្ធសភាដើម្បីសុំការពិនិត្យឡើងវិញ ។

៨. ព្រឹទ្ធសភាពិនិត្យឡើងវិញនូវច្បាប់អនុម័តដោយសភាជាតិ ។

៨.១ គណៈកម្មការនៃគណៈកម្មការអចិន្ត្រៃយ៍ពិនិត្យឡើងវិញលើពង្រាងច្បាប់ ឬច្បាប់ស្នើសុំ ហើយបញ្ជូនច្បាប់នោះទៅគណៈកម្មការទទួលបន្ទុក ។

៨.២ នៅពេលដែលពង្រាងច្បាប់ធ្លាក់ដល់គណៈកម្មការរបស់ព្រឹទ្ធសភា ជំហានជាបន្ទាប់ទៀតគឺដូចគ្នា មិនថាអ្នកណាជាអ្នកព្រាងឬស្នើច្បាប់ទេ ។ ក្រោយពេលដែលគណៈកម្មការបានទទួលពង្រាងឬសំណើហើយជំពូកទី៦នៃបទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា ផ្តល់ជម្រើសបីយ៉ាង ។ គណៈកម្មការអាច ៖

- ធ្វើអនុសាសន៍ទៅកាន់សភាទាំងមូលសូមកុំឱ្យពិចារណាលើពង្រាងច្បាប់នោះ ។
- សុំឱ្យសភាទាំងមូលសម្រេចថាតើគួរលើក យកពង្រាង ច្បាប់នោះមកពិចារណាឬទេ ។
- សុំឱ្យសភាទាំងមូលពិចារណាលើពង្រាងច្បាប់ "នៅក្នុងភាពបន្ទាន់" ។

៨.៣ ព្រឹទ្ធសភាពិនិត្យនិងអនុម័តលើពង្រាងច្បាប់ ឬច្បាប់ ស្នើឡើង ។ (ចំណាំ ៖ ព្រឹទ្ធសភាអាចបញ្ជូនអនុសាសន៍របស់ខ្លួនទៅកាន់សភាជាតិ ហើយសុំឱ្យសភាពិនិត្យមើលឡើងវិញលើពង្រាង ឬច្បាប់ ស្នើនោះ) ។
សភាជាតិនៅតែអាចអនុម័តវាដដែលហើយ ដាក់ថ្វាយ ទៅព្រះមហាក្សត្រដើម្បីសុំការប្រកាសឱ្យប្រើ) ។

៩. ក្រុមប្រឹក្សាធម្មនុញ្ញមានអំណាចស្របទៅតាមរដ្ឋធម្មនុញ្ញនៅក្នុងការបកស្រាយច្បាប់ មិនថាច្បាប់ដែលអនុម័តដោយសភាជាតិឬច្បាប់ដែលពិនិត្យឡើងវិញដោយព្រឹទ្ធសភាទេ ទាំងពីរត្រូវតែមានភាពស្របទៅនឹងរដ្ឋធម្មនុញ្ញ ។ ពង្រាងច្បាប់ឬច្បាប់ដែលស្នើឡើង គឺគេមិនអាចទទួលយកបានទេបើច្បាប់នោះសំដៅកាត់បន្ថយទ្រព្យសម្បត្តិសាធារណៈហើយបង្កើនបន្ទុកទៅលើពលរដ្ឋ ។ (ចំណាំ ៖ នៅមុនពេលអនុម័តច្បាប់ សភាជាតិ ឬព្រឹទ្ធសភាអាចស្នើសុំទៅក្រុមប្រឹក្សាធម្មនុញ្ញឱ្យពិនិត្យមើលឡើងវិញលើពង្រាងច្បាប់ ។ នៅក្នុងករណីច្បាប់ទាក់ទងនឹងការបង្កើតអង្គការនិងបទបញ្ជាផ្ទៃក្នុងទាំងឡាយរបស់សភាជាតិ និងព្រឹទ្ធិសភានោះ សភាជាតិនិងព្រឹទ្ធសភាអាចសុំទៅក្រុមប្រឹក្សាធម្មនុញ្ញឱ្យពិនិត្យមើលលើរដ្ឋធម្មនុញ្ញភាពនៃច្បាប់នោះមុនពេលអនុម័ត) ។

១០. សភាជាតិថ្វាយច្បាប់ដែលអនុម័តរួចជូនព្រះមហាក្សត្រដើម្បីសុំការប្រកាសឱ្យប្រើប្រាស់ ព្រះមហាក្សត្រឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យ ដើម្បីប្រកាសឱ្យប្រើច្បាប់នេះ ។ ច្បាប់ដែលបានអនុម័តនេះក្លាយជាកម្មវត្ថុសម្រាប់ធ្វើឱ្យមានសុពលភាព ។

# រចនាសម្ព័ន្ធនៃដំណើរការតាក់តែងច្បាប់




ឧបសម្ព័ន្ធ ១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ញត្តិផ្ញើជូនសាលាក្រុងភ្នំពេញ

យើងខ្ញុំជាហត្ថលេខីខាងក្រោមមានអារម្មណ៍ថា សហគមន៍ក្រីក្រនៅក្នុងទីក្រុងភ្នំពេញត្រូវបានគេបោះបង់ចោលជាយូរមកហើយ ។ យើងចង់បង្ហាញនូវការគាំទ្ររបស់ពួកយើងចំពោះគោលនយោបាយដែលហៅថា " សហគមន៍តាំងទីលំនៅអាណាធិបតេយ្យ " ដោយការបង្កើតឱ្យមានហេដ្ឋារចនាសម្ព័ន្ធចាំបាច់ដូចជា សេវាកម្មខាងអនាម័យ សាលារៀន និង ការការពារសិទ្ធិរបស់សហគមន៍ក្នុងការជ្រើសរើសនូវការតាំងទីលំនៅឡើងវិញ ប្រសិនបើការតាំងទីលំនៅឡើងវិញនោះជាការចាំបាច់ ។ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះការងាររបស់លោកកន្លងមក ហើយសង្ឃឹមថាលោកនឹងបន្តការងារជាមួយអ្នកដឹកនាំសហគមន៍ នៅទីនោះ និងអង្គការក្រៅរដ្ឋាភិបាលទាំងឡាយនៅពេលខាងមុខ ។

សូមអរគុណ ។

| ឈ្មោះ | អាសយដ្ឋាន | ហត្ថលេខា |
|---|---|---|
| ១. | | |
| ២. | | |
| ៣. | | |
| ៤. | | |
| ៥. | | |
| ៦. | | |
| ៧. | | |
| ៨. | | |
| ៩. | | |
| ១០. | | |
| ១១. | | |
| ១២. | | |
| ១៣. | | |
| ១៤. | | |

# លិខិតគំរូផ្ញើជូនទៅរដ្ឋាភិបាល

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

(ឈ្មោះអង្គការ:)

(ផ្នែក)

ខ្ញុំបាទឈ្មោះ .................. , មុខនាទីជា ...................... មកពី..................................ដែលមានអាស័យដ្ឋាននៅ
................................................................................................................................................................................................ ។

**សូមគោរពជូន**

ឯកឧត្តម រដ្ឋមន្ត្រីក្រសួង...................................................

"ជាទីគោរពដ៏ខ្ពង់ខ្ពស់"

**កម្មវត្ថុ** : "កម្មវត្ថុនៃលិខិត"

**មូលហេតុ :** ខ្ញុំបាទសុំធ្វើសេចក្ដីស្នើដល់ឯកឧត្តមដោយសេចក្ដីគោរព ដើម្បីមេត្តាឯកឧត្តមជួយគាំទ្រនូវ (ឈ្មោះ ច្បាប់ និងលេខ) ។សកម្មជនសហគមន៍ជាច្រើននៅខេត្ត.............. បាននិងកំពុងធ្វើការតស៊ូចំពោះបញ្ហានេសាទ ខុសច្បាប់ដែលរំលោភលើច្បាប់ខាងលើនេះ ។ ប្រជាជនកម្ពុជាត្រូវការរាជរដ្ឋាភិបាលដើម្បីមេត្តាបង្កើននូវសុពលភាពច្បាប់នានាដែលការពារសិទ្ធិពួកគេ ។ ខ្ញុំបាទមានបំណងប្រាថ្នាចង់ឃើញនូវការបញ្ចប់ការរងទុក្ខលំបាករបស់គ្រួសារទាំងឡាយដែលកំពុងធ្វើការតស៊ូលើបញ្ហានេសាទនេះ ។

ដូច្នេះអង្គការ (ឈ្មោះអង្គការ) របស់យើងខ្ញុំសូមអំពាវនាវដល់ក្រសួងកសិកម្មសូមមេត្តា ជួយធ្វើឱ្យមានសុពលភាពច្បាប់ដែលបានជម្រាបជូនដូចខាងលើនៅក្នុងខេត្ត.................................. ដោយសេចក្ដីអនុគ្រោះបំផុត ។ ខ្ញុំសង្ឃឹមថា ឯកឧត្តមឈរលើស្មារតីប្រឆាំងនឹងសកម្មភាពខុសច្បាប់ ហើយជំរុញអ្នកមានមកពីអំពើរំលោភច្បាប់ដើម្បីឱ្យពួកគេមានការគោរពច្បាប់ឡើងវិញ ។ ជាពិសេសបុគ្គលដែលប្រើប្រាស់សម្ភារៈខុសច្បាប់ដូចជាម៉ាស៊ីនបូមទឹក និង ឧបករណ៍ចាប់ត្រីដោយប្រើថាមពលអគ្គិសនី ។

ខ្ញុំបាទសូមជូនពរដល់ឯកឧត្តមមានសុខភាពល្អ និង ជោគជ័យលើគ្រប់ការងាររបស់ឯកឧត្តម ។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

ធ្វើនៅ........ ថ្ងៃទី .... ខែ .... ឆ្នាំ........

ហត្ថលេខា និង ឈ្មោះ

លោក-អ្នកស្រី ................................

# ឧបសម្ព័ន្ធ ឃ : ប្រភពផ្សព្វផ្សាយពត៌មាន និង អ៊ិនធឺណេត

***គម្រោង "A" សម្រាប់ការតស៊ូមតិ***

*http://www.huccp.org/pr/advocacay/index.stm*

***យុទ្ធសាស្ត្រសកម្មនិយមបង្ហាញនៅលើ វេប សាយ***

*http://www.netaction.org/training/*

***ការគិតគូរជាយុទ្ធសាស្ត្រនៅក្នុងយុទ្ធនាការតស៊ូមតិទាំងឡាយ***

*http://www.comminit.com/strategic.html*

***ការកសាងឧបករណ៍ប្រើប្រាស់និង គ្រឿងជំនួយផ្សេងៗ***

*http://www.comminit.com/materials.html*

***មជ្ឈមណ្ឌលសម្រាប់ការផ្លាស់ប្តូរសហគមន៍ ការតស៊ូមតិ (IOI)***

*http://www.communitychange.org/advocacy.htm*

***ការផ្តល់យោបល់នៃការតស៊ូមតិសម្រាប់របៀបវារៈធំៗ***

*http://www.massagenda.com/prodshow/*

***របៀបចាប់ផ្តើមក្នុងការរៀបចំសហគមន៍***

*http://comm-org.utoledo.edu/papers97/startco.htm*

***ការផ្តល់ជាយោបល់សម្រាប់សកម្មភាពនៃសកម្មភាពផ្ទាល់និងអហិង្សា***

*http://www.actupny.org/documents/CDdocuments/CDindex.html*

***សៀវភៅណែនាំប្រជាពលរដ្ឋស្តីអំពីការបង្កើតសហគមន៍***

*http://www.vcn.bc.ca/citizens-handbook/*

***សេចក្តីណែនាំរបស់វិទ្យាស្ថានតស៊ូមតិសម្រាប់សរសេរករណីសិក្សាអំពីការតស៊ូមតិ***

*http://www.advocacy.org/publications/pdf/tellingyourstory.pdf*

***យុទ្ធសាស្ត្រតស៊ូមតិរបស់ OXFAM អាមេរិច***

*http://www.oxfamamerica.org/publications/art1106.html*

***សេចក្តីណែនាំរបស់ធនាគារពិភពលោកក្នុងការប្រមូលនូវប្រភពទុនទាំងឡាយ***

*http://lnweb18.worldbank.org/essd/essd.nsf/GlobalView/cs-mobilizefunding.pdf/ $File/cs-bilizefunding.pdf*

***សេចក្តីណែនាំសម្រាប់អប់រំអ្នកតស៊ូមតិទាំងឡាយ( សម្រាប់អង្គការអាមេរិចប៉ុន្តែអាចអនុវត្តន៍បានដោយប្រទេសដទៃៗទៀត)***

*http://www.ascd.org/advocacykit/*

*ខាងក្រោមនេះជាចំណុចជាក់លាក់តែអាចជំនួយដល់អ្នកតស៊ូមតិទាំងឡាយ*

***សេចក្តីណែនាំអំពីការគាំទ្រចំពោះ HIV/AIDS***

*http://www.ippf.org/hivaids/advocacyguide/index.htm*

***សេចក្តីណែនាំអំពីការគាំទ្រចំពោះសុខភាពបន្តពូជ***

*http://www.ippf.org/pubs/advocacyguide.htm*

Additional copies of this document are available at:

Pact Cambodia
Hong Kong Center, Ground Floor
108-112 Preah Sothearos Blvd.
Phnom Penh, (P.O. Box 149)
Kingdom of Cambodia
Tel/Fax: (855-23) 217-820, 217-855, 217-856
E-mail: pact@pactcam.org